Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

54413

IFC International Finance Corporation
World Bank Group

The Asia Foundation

# ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា

## ការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិ

## របាយការណ៍សង្ខេប



ខែ មេសា ឆ្នាំ ២០០៩

# ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា[១]

## ការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិ

## របាយការណ៍សង្ខេប

ខែ មេសា ឆ្នាំ ២០០៩

១ ការវាយតម្លៃបរិយាសអាជីវកម្មតាមខេត្ត (PBES) គឺជាកិច្ចសហប្រតិបត្តិការរវាងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងមូលនិធិអាស៊ី (ដោយមានជំនួយឧបត្ថម្ភពី Danida, DFID និង NZAID តាមរយៈកម្មវិធីលើកកម្ពស់ជីវភាពរស់នៅរបស់ម្ចាស់ជំនួយពហុភាគី) ។

# មាតិកា


អក្សរកាត់ ........ vi

បញ្ជីតារាង ........ vii

បញ្ជីរូបភាព ........ vii

សេចក្ដីថ្លែងអំណរគុណ........ viii

១. **សេចក្ដីផ្ដើម**........ ៩

២. **ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត និងសន្ទស្សន៍**........ ១១

២.១ យុទ្ធសាស្ត្រទូទៅនៃការផ្ដល់ពិន្ទុ ........ ១១

២.២ សន្ទស្សន៍ ........ ១១

២.៣ យុទ្ធសាស្ត្រនៃការអង្កេត ........ ១២

៣. **លក្ខណៈរបស់អាជីវកម្មក្នុងប្រទេសកម្ពុជា**........ ១៥

៣.១ អាជីវកម្មក្នុងប្រទេសកម្ពុជាជាសហគ្រាសខ្នាតតូចបំផុត ........ ១៦

៣.២ អាជីវកម្មខ្នាតតូច និងមធ្យមក្នុងប្រទេសកម្ពុជា មានការកើនឡើង ........ ១៧

៣.៣ ចំនួនអាជីវកម្មដែលប្រមូលផ្ដុំក្នុងទីក្រុងភ្នំពេញកំពុងថយចុះ ........ ១៨

៣.៤ អាជីវកម្មភាគច្រើនធ្វើសកម្មភាពតែក្នុងខេត្ត ដែលខ្លួនកំពុងរស់នៅប៉ុណ្ណោះ ........ ១៩

៣.៥ អាជីវកម្មភាគច្រើន ស្ថិតក្នុងវិស័យសេវាកម្ម ឬពាណិជ្ជកម្ម ........ ១៩

៣.៦ ស្ត្រីមានភាពសកម្មក្នុងដំណើរការអាជីវកម្ម........ ១៩

៣.៧ អាជីវកម្មភាគច្រើនទើបតែចាប់ផ្ដើមដំណើរការ ........ ២០

៣.៨ កំណើនអាជីវកម្មទំនងជានៅតែបន្ត ........ ២០

៤. **ការផ្ដល់ចំណាត់ថ្នាក់របស់** PBES **ឆ្នាំ២០០៩ : ការពន្យល់ និងការវិភាគ** ........ ២៣

៤.១ ចំណាត់ថ្នាក់ ........ ២៣

៤.២ ខេត្តមួយចំនួនមានពិន្ទុល្អជាងមុនក្នុងរយៈពេលកន្លងមក ........ ២៦

៤.៣ ចំណាត់ថ្នាក់ខ្ពស់ ក៏ប៉ុន្តែមិនទាន់ទទួលបានពិន្ទុល្អឥតខ្ចោះ ........ ២៨

៤.៤ ឥទ្ធិពលនៃការកែលម្អអភិបាលកិច្ច ........ ៣០

៤.៥ គោលនយោបាយនីមួយៗ ........ ៣១

៥. **សេចក្ដីសន្និដ្ឋាន**........ ៣៧

ឧបសម្ព័ន្ធ ក១ : វិធីសាស្ត្រ ........ ៣៩

ឧបសម្ព័ន្ធ ក២ : ការបង្កើត **PBES** ........ ៤៣

ឧបសម្ព័ន្ធ ក៣ : ទំនាក់ទំនងរវាងលទ្ធផល **PBES** ឆ្នាំ២០០៦ និង **PBES** ឆ្នាំ២០០៩........ ៤៦

# អក្សរកាត់

| | |
|---|---|
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **DANIDA** | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក |
| **DFID** | ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស |
| **DIME** | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល |
| **DOC** | មន្ទីរពាណិជ្ជកម្ម |
| **DOT** | មន្ទីរទេសចរណ៍ |
| **ICA** | ការវាយតម្លៃបរិយាសកាសវិនិយោគដោយធនាគារពិភពលោក |
| **IFC** | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| **MDLF** | កម្មវិធីលើកកម្ពស់ជីវភាពរស់នៅឧបត្ថម្ភដោយម្ចាស់ជំនួយពហុភាគី |
| **MIME** | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| **MOC** | ក្រសួងពាណិជ្ជកម្ម |
| **MOT** | ក្រសួងទេសចរណ៍ |
| **MSME** | សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម |
| **NZAID** | ទីភ្នាក់ងារជំនួយអន្តរជាតិ និងអភិវឌ្ឍន៍នៃប្រទេសញូវហ្សីលែន |
| **PBES** | ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត |
| **VAT** | អាករលើតម្លៃបន្ថែម |
| **WB** | ធនាគារពិភពលោក |

## បញ្ជីតារាង


**តារាងទី១:** ការប្រែប្រួលនៃការបែងចែកទំហំសហគ្រាសរបស់ស្ថិតិអាជីវកម្ម PBES (ឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៩) ......... ១៧

**តារាងទី២:** ការប្រៀបធៀបបរិយាកាសអាជីវកម្មនៅទីក្រុងភ្នំពេញ ជាមួយបណ្តាខេត្តក្រុងផ្សេងៗទៀត ........................ ២៦

**តារាងទី៣:** ឥទ្ធិពលនៃសន្ទស្សន៍នីមួយៗ ទៅលើឱកាសដែលអាជីវករអាចពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួន ................. ៣០

**តារាងទី៤:** កម្រិតនៃការចុះបញ្ជីពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ............................................................................... ៣៣

**តារាង ក១:** តើអ្នកណាជាអ្នកឆ្លើយសំណួរសម្រាប់ការអង្កេតរបស់ PBES ឆ្នាំ២០០៩ ?................................................ ៤១

**តារាង ក២:** សេចក្តីអធិប្បាយលំអិតអំពីសន្ទស្សន៍ និងសូចនាករដែលជាសមាសភាគនានា ............................................... ៤៨


## បញ្ជីរូបភាព


**រូបទី១:** ការបែងចែកសហគ្រាសតាមទំហំ - តាមចំនួននិយោជិត ដោយមិនរាប់បញ្ចូលម្ចាស់អាជីវកម្ម .......................... ១៦

**រូបទី២:** ស្ថិតិអាជីវកម្ម PBES ឆ្នាំ២០០៩ - សហគ្រាសបែងតាមទីតាំងភូមិសាស្ត្រ ................................................. ១៨

**រូបទី៣:** ស្ថិតិអាជីវកម្ម PBES ឆ្នាំ២០០៩ - សហគ្រាសបែងចែកតាមវិស័យ ....................................................... ១៩

**រូបទី៤:** ស្ថិតិអាជីវកម្មPBES ឆ្នាំ២០០៩ - ភាគរយនៃសហគ្រាសបែងចែកតាមភេទរបស់ម្ចាស់អាជីវកម្ម .................... ២០

**រូបទី៥:** ស្ថិតិអាជីវកម្មPBES ឆ្នាំ២០០៩ - ភាគរយនៃសហគ្រាសបែងចែកតាមចំនួនឆ្នាំនៃដំណើរការអាជីវកម្ម ............ ២១

**រូបទី៦:** ចំណាត់ថ្នាក់របស់ PBES ឆ្នាំ២០០៩ ............................................................................................ ២៤

**រូបទី៧:** ចំណាត់ថ្នាក់របស់ PBES ឆ្នាំ២០០៦ ............................................................................................ ២៥

**រូបទី៨:** ពិន្ទុលើសន្ទស្សន៍នីមួយៗ ........................................................................................................ ២៨

**រូបទី៩:** ទំនាក់ទំនងរវាងអភិបាលកិច្ច និងការពង្រីកអាជីវកម្ម ............................................................................ ២៩

**រូបទី១០:** ទំនាក់ទំនងរវាងចំណាត់ថ្នាក់ ឆ្នាំ២០០៦ និងឆ្នាំ២០០៩ ........................................................................ ៤៧

# សេចក្តីថ្លែងអំណរគុណ

គម្រោងការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជាឆ្នាំ ២០០៩ (២០០៩ **PBES**) គឺជាការខិតខំប្រឹងប្រែងរួមគ្នារបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ **(IFC)** ជាមួយនិង មូលនិធិអាស៊ី **(The Asia Foundation)** ។យើងសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងមូលនិធិអាស៊ី ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុ ។

ដំណើរការទាំងមូលនៃការវាយតម្លៃបរិយាកាសអាជីវកម្មនៅតាមខេត្តក្នុងឆ្នាំ ២០០៩ រួមទាំងការស្រង់ស្ថិតិអាជីវកម្ម នឹងមិនអាចដំណើរការបានទេ បើពុំមានការគាំទ្រពីសំណាក់ **ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល **ឯកឧត្តម បណ្ឌិត ហង់ជួន ណារ៉ុន** អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង អគ្គលេខាធិការបានចេញលិខិតនានាដើម្បីផ្តល់ការគាំទ្រដល់គំរោងនេះ ។

ដូចគ្នានឹងកិច្ចខិតខំធ្វើការស្រាវជ្រាវដទៃទៀតដែរ ការវាយតម្លៃបរិយាកាសអាជីវកម្ម គឺជាលទ្ធផលនៃកិច្ចខំប្រឹងប្រែងរួមគ្នារបស់បុគ្គលជាច្រើននាក់ ។ លោកបណ្ឌិត **Edmund Malesky** ជាទីប្រឹក្សាបច្ចេកទេសរបស់គម្រោង និងជាអ្នកនិពន្ធរបាយការណ៍នេះ ដោយមានការជ្រោមជ្រែងផ្នែកបច្ចេកទេសពីក្រុមការងារដែលមានលោក **Paul Schuler** និងលោក **Krislert Samphantharak** ។ លោក **Charles Schneider** លោក **ហោ សុនាថ** និងលោកស្រី **Véronique Salze-Lozac'h** បានផ្តល់គំនិតយោបល់ និងការគ្រប់គ្រងទូទៅលើគម្រោងនេះ ។ លោក **ឌុ ឃី** និង លោក **សាក់ សម្បត្តិ** បានដឹកនាំការរៀបចំ និងគ្រប់គ្រងដំណើរការនៃការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តឆ្នាំ២០០៩នេះ ។ កញ្ញា **សុខ ឡាច** និង លោកស្រី **ឌា សាន** បានរៀបចំចងក្រងទិន្នន័យរបាយការណ៍ និងត្រួតពិនិត្យលើគុណភាពបទសំភាសន៍ដើម្បីធានាថា ព័ត៌មានដែលប្រមូលបានពីតាមមូលដ្ឋានមានភាពត្រឹមត្រូវ ។ លោក **Kent Helmers** គ្រប់គ្រងការប្រមូលព័ត៌មានតាមខេត្ត ដោយមាន លោក **គិត ស៊ីនីន** និង លោក **ប៊ុន ឧុទ្ធី** ជួយក្នុងការស្រាវជ្រាវនៅមូលដ្ឋាន ។ លោកស្រី **Ann Bishop** គឺជាអ្នកពិនិត្យផ្ទៀងផ្ទាត់បច្ចេកទេស និងអត្ថបទ ។ លោកស្រី **គា គន្ធា** ជាអ្នករៀបចំរចនារបាយការណ៍សំរាប់ការបោះពុម្ព ។ លោកស្រី **តាន់ តូនី** បានផ្តល់ការជ្រោមជ្រែងផ្នែករដ្ឋបាល ។

# ១. សេចក្តីផ្តើម

ម្ចាស់ហាងលក់បង្អួច និងទ្វារមួយនៅខេត្តក្រចេះ បាននិយាយថា "ក្នុងខេត្តរបស់ខ្ញុំ មន្ត្រីរាជការក្នុងខេត្ត មិនផ្តល់ការគាំទ្រចំពោះសកម្មភាពអាជីវកម្មទេ។ មន្ត្រីទាំងនោះ មិនធ្លាប់ចុះពិនិត្យមើលសកម្មភាពអាជីវកម្ម ឬអញ្ជើញយើងទៅពិភាក្សា អំពីបញ្ហាបរិយាកាសអាជីវកម្មម្តងណាឡើយ"។ ប៉ុន្តែ នៅក្នុងខេត្តកំពង់ចាមដែលស្ថិតនៅជាប់ខេត្តក្រចេះវិញ ម្ចាស់សិប្បកម្មឡឥដ្ឋតូចមួយ យល់ឃើញថា បរិយាកាសអាជីវកម្មនៅខេត្ត របស់គាត់មានការរីកចម្រើន ដោយលោកនិយាយថា "ជាការពិតណាស់ ការបង់សំណូកមានការថយចុះយ៉ាងខ្លាំង។ ការកាត់បន្ថយនីតិវិធីរដ្ឋបាលបានជួយកាត់បន្ថយអំពើពុករលួយ"។

សាច់រឿងទាំងពីរខាងលើបង្ហាញថា បទពិសោធន៍របស់សហគ្រិនជាមួយអាជ្ញាធរមូលដ្ឋាន អាចមានភាពខុសៗគ្នាយ៉ាងខ្លាំងពីខេត្តមួយទៅខេត្តមួយទៀត ក្នុងប្រទេសកម្ពុជា។ ទោះបីរដ្ឋាភិបាលថ្នាក់ជាតិជាអ្នកសម្រេចអនុម័តច្បាប់ និងបទបញ្ញត្តិក៏ដោយ ក៏ការយល់ដឹង និងការអនុវត្តន៍ច្បាប់ បទបញ្ញត្តិទាំងនេះ អាស្រ័យទៅលើអាជ្ញាធរថ្នាក់ខេត្ត។ ភាពខុសគ្នានៃគុណភាពអភិបាលកិច្ចសេដ្ឋកិច្ច[២] ពីខេត្តមួយទៅខេត្តមួយទៀត រួមចំណែកធ្វើឱ្យកំណើនសេដ្ឋកិច្ច មានកម្រិតមិនស្មើគ្នាពីខេត្តមួយ ទៅខេត្តមួយទៀតក្នុងប្រទេសកម្ពុជា។

ដើម្បីយល់បានថាតើបណ្តាខេត្តនានា បានរួមវិភាគទាន ឬបង្កឧបសគ្គដល់កំណើនអាជីវកម្មដោយរបៀបណានោះ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងមូលនិធិអាស៊ី (The Asia Foundation) បានសហការគ្នាបង្កើតគម្រោងវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត (PBES) ឆ្នាំ ២០០៩ ដោយផ្តល់ចំណាត់ថ្នាក់ខេត្តក្រុងទាំង ២៤ យោងទៅតាមគុណភាពនៃអភិបាលកិច្ចសេដ្ឋកិច្ច។

PBES ផ្តល់នូវទិន្នន័យគួរឱ្យជឿជាក់បាន ដើម្បីជួយដល់អាជីវកម្ម និងរដ្ឋាភិបាលថ្នាក់ខេត្ត ក្នុងការកំណត់អំពីការងារអភិបាលកិច្ច ដែលចាំបាច់ត្រូវកែលម្អ។ ការវាយតម្លៃអភិបាលកិច្ចតាមខេត្តនេះ ពិតជាមានសារៈសំខាន់ជាពិសេស ពីព្រោះការវាយតម្លៃនេះ នឹងជួយដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម (MSMEs) នៅកម្ពុជា ដែលតំណាងឱ្យសហគ្រាសឯកជនជាង ៩៥ភាគរយ ឱ្យសម្រេចបាននូវសក្តានុពលរបស់ខ្លួន ក្នុងការបង្កើតការងារតាមតំបន់ជនបទ ដែលមានប្រជាជនកម្ពុជាភាគច្រើនរស់នៅ និងមានអត្រាភាពក្រីក្រខ្ពស់បំផុត។ ការបង្កើតការងារនេះមានសារៈសំខាន់ណាស់សំរាប់តំបន់ជនបទ ព្រោះជារៀងរាល់ឆ្នាំមានយុវជនវ័យក្មេង ២៣០ ០០០នាក់ ស្វែងរកការងារ។[៣]

PBES បានចាប់ផ្តើមធ្វើការសិក្សាជាលើកដំបូងនៅឆ្នាំ ២០០៦ ក្នុងខេត្តចំនួន ១០ ហើយក្រោយមក

---

[២] អភិបាលកិច្ចសេដ្ឋកិច្ច សំដៅដល់ទិដ្ឋភាព និងការប្រតិបត្តិនៃសកម្មភាពគ្រប់គ្រងបទបញ្ញត្តិ និងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ឬបរិយាកាសស្ថាប័ន ដែលគ្រប់គ្រងអភិបាលកិច្ចសេដ្ឋកិច្ចទាំងនោះ។

[៣] ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (ខែ មេសា ឆ្នាំ ២០០៥)

នៅឆ្នាំ ២០០៩ បានគ្របដណ្តប់ទូទាំង ២៤ ខេត្តក្រុង។ PBESពឹងផ្អែកយ៉ាងខ្លាំងទៅលើការយល់ឃើញរបស់ម្ចាស់អាជីវកម្មដើម្បីធ្វើការវាយតម្លៃមួយ សម្រាប់ជួយឱ្យគេអាចផ្តល់ចំណាត់ថ្នាក់ដល់ខេត្តនីមួយៗ លើគុណភាពបរិយាកាសអាជីវកម្ម។ ដោយប្រើមធ្យោបាយនេះ PBES ជួយមន្ត្រីរដ្ឋាភិបាល ឱ្យរកឃើញនូវវិស័យជាក់លាក់មួយចំនួនដែលត្រូវធ្វើការកែទម្រង់។

PBES ក៏បង្ហាញពីភ័ស្តុតាងដែលម្ចាស់អាជីវកម្មត្រូវការចាំបាច់ ក្នុងការតស៊ូមតិឱ្យមានប្រសិទ្ធិភាព ដើម្បីជំរុញឱ្យមានការកែទម្រង់ និងធ្វើឱ្យមន្ត្រីរដ្ឋាភិបាលចូលរួមក្នុងការពិភាក្សាអំពីរបៀបធ្វើកំណែទម្រង់។ ឧបសគ្គនានាជាច្រើនដូចជា កង្វះខាតព័ត៌មានអំពីបទបញ្ញត្តិ នីតិវិធីដែលធ្វើឱ្យអាជីវករចំណាយពេលវេលាច្រើន ចំណាយក្រៅផ្លូវការ និងការផ្តល់សេវាសាធារណៈមិនល្អជាដើម នាំឱ្យរាំងស្ទះដល់ការរីកចំរើនរបស់អាជីវកម្ម។

លើសពីការចង្អុលបង្ហាញវិស័យសម្រាប់ធ្វើកំណែទម្រង់PBESក៏បង្ហាញពីខេត្តក្រុងដែលបានអនុវត្តការងារល្អ ដើម្បីឱ្យខេត្តក្រុងដទៃទៀតអាចរៀនសូត្រ និងយកគំរូតាម។ លើសពីនេះ លទ្ធផលរបស់ PBES ឆ្នាំ២០០៦ និង ឆ្នាំ២០០៩ ក៏អាចផ្តល់ជាទិន្នន័យគោល សម្រាប់ឱ្យអ្នករៀបរៀងគោលនយោបាយ និងអ្នកបង្កើតបទបញ្ញត្តិអាចត្រួតពិនិត្យលើលទ្ធផលនៃការកែទម្រង់ដែលគេបានអនុវត្តកន្លងមក។

# ២. ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត និងសន្ទស្សន៍

## ២.១ យុទ្ធសាស្ត្រនៅនៃការផ្តល់ពិន្ទុ

ពិន្ទុ **PBES** បង្កើតឡើងតាមរយៈការបូកបញ្ចូលគ្នានៃចម្លើយរបស់សំណួរអង្កេត និងទិន្នន័យ "រឹង" ដែលប្រមូលបានពីប្រភពរដ្ឋាភិបាល និងឯកសារបោះពុម្ពជាច្រើនទៀត។ យើងប្រើទិន្នន័យទាំងនេះ ដើម្បីបង្កើតសន្ទស្សន៍ ១០ (ប្រភេទ) ដែលសន្ទស្សន៍នីមួយៗអាចទទួលបានពិន្ទុពី ១ ដល់ ១០។ បន្ទាប់ពីការបូកពិន្ទុសន្ទស្សន៍ទាំង ១០ នេះបញ្ចូលគ្នា គេអាចទទួលបានពិន្ទុសរុប ១០០ពិន្ទុ។ តាមលក្ខណៈបច្ចេកទេស ខេត្តមួយអាចទទួលបានពិន្ទុសរុបឥតខ្ចោះ គឺ១០០ពិន្ទុ ប្រសិនបើខេត្តនោះទទួលបានពិន្ទុខ្ពស់ជាងខេត្តផ្សេងទៀត លើគ្រប់សូចនាករទាំង១០។ ប៉ុន្តែការទទួលបានពិន្ទុល្អឥតខ្ចោះនេះ ជាការពិបាកណាស់។ ការពិតខេត្តណាក៏ដូចជាខេត្តណាដែរ សុទ្ធតែទទួលបានពិន្ទុទាបនៅលើផ្នែក ឬវិស័យមួយចំនួន។

មុនពេលឈានទៅដល់ការពិពណ៌នាអំពីសន្ទស្សន៍ និងយុទ្ធសាស្ត្រនៃការអង្កេត ប្រការសំខាន់ត្រូវចាំថា ការផ្តល់ចំណាត់ថ្នាក់សន្ទស្សន៍ ពឹងផ្អែកទៅលើលទ្ធផលរបស់ខេត្តមួយ ធៀបនឹងខេត្តដទៃទៀត ដោយប្រើប្រាស់ចម្លើយនៃសំណួរអង្កេតណាមួយ និងទិន្នន័យពីប្រភពដទៃទៀត។ ហេតុដូច្នេះ គេមិនអាចប្រៀបធៀបពិន្ទុសរុបនេះ ជាមួយនឹងពិន្ទុសរុបរបស់ប្រទេសដទៃ ឬ ការវាស់ស្ទង់ដ៏ល្អឥតខ្ចោះនៃអភិបាលកិច្ចឡើយ។ ទោះជាយ៉ាងនេះក៏ដោយ គេគួរចាត់ទុកសន្ទស្សន៍ទាំងនេះជាការវាស់ស្ទង់ សមិទ្ធផលប្រៀបធៀបរបស់បណ្តាខេត្តនានា ក្នុងបរិបទនៃប្រទេសកម្ពុជា។ សម្រាប់សេចក្តីលម្អិតបន្ថែមស្តីពីការពន្យល់អំពី យុទ្ធសាស្ត្រនៃការផ្តល់ពិន្ទុ សូមមើលឧបសម្ព័ន្ធក២ នៃរបាយការណ៍នេះ។

## ២.២ សន្ទស្សន៍

សន្ទស្សន៍ទាំង ១០ ខាងក្រោមនេះ ត្រូវបានប្រើសម្រាប់ដាក់ពិន្ទុខេត្តក្រុងទាំង ២៤ នៅប្រទេសកម្ពុជា៖

*១.ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម:* ការវាស់ស្ទង់ពេលវេលាដែលក្រុមហ៊ុនត្រូវចំណាយក្នុងការចុះបញ្ជីអាជីវកម្ម និងទទួលបានអាជ្ញាប័ណ្ណចាំបាច់ទាំងអស់ សម្រាប់ការចាប់ផ្តើមអាជីវកម្ម ចំនួនអាជ្ញាប័ណ្ណចាំបាច់ និងការចំណាយផ្លូវការសម្រាប់ការចុះបញ្ជី និងទទួលបានអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតនានា។

*២.កម្មសិទ្ធិលើទ្រព្យសម្បត្តិ:* ការវាស់ស្ទង់កម្មសិទ្ធិស្របច្បាប់របស់ម្ចាស់អាជីវកម្ម ក្នុងការកាន់កាប់ដីធ្លី និងអគារសម្រាប់ធ្វើអាជីវកម្ម និងសុវត្ថិភាពនៃកម្មសិទ្ធិទាំងនោះ បន្ទាប់ពីម្ចាស់អាជីវកម្មទទួលបានដី និងប័ណ្ណកម្មសិទ្ធិលើដីនោះ។

*៣.តម្លាភាព:* ការវាស់ស្ទង់ថាតើអាជីវកម្មទទួលបានព័ត៌មានដែលខ្លួនចង់បាន អំពីបទបញ្ញត្តិ និងនីតិវិធី

រដ្ឋាភិបាល ក៏ដូចជាឯកសារច្បាប់ចាំបាច់ផ្សេងៗទៀត សម្រាប់ដំណើរការអាជីវកម្មដែរឬទេ ថាតើអាជីវករគ្រប់គ្នា អាចទទួលបានព័ត៌មានស្តីពីបទបញ្ញត្តិ និងឯកសារច្បាប់ នៅពេលស្នើសុំ និងថាតើគោលនយោបាយ និងច្បាប់ថ្មីៗ ត្រូវបានផ្សព្វផ្សាយទៅដល់អាជីវកម្ម ហើយការអនុវត្តនីគោលនយោបាយ និងច្បាប់ទាំងនោះ អាចឱ្យពួកគេព្យាករណ៍បានដែរឬទេ។

*៤.ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ:* ការវាស់ស្ទង់ថាតើអាជីវកម្មត្រូវចំណាយពេលវេលាប៉ុន្មាន ក្នុងការប្រតិបត្តិតាមបទបញ្ញត្តិ ច្បាប់ ថាតើត្រូវចំណាយពេលវេលាប៉ុន្មានក្នុងការរង់ចាំដើម្បីគោរពតាមនីតិវិធីនានារួចរាល់ និងថាតើស្ថាប័នជំនាញត្រូវចុះធ្វើអធិការកិច្ចញឹកញាប់កម្រិតណា។

*៥. ចំណាយក្រៅផ្លូវការ/ប្រាក់សំណូក:* ការវាស់ស្ទង់ថាតើអាជីវកម្មធ្វើការចំណាយក្រៅផ្លូវការញឹកញាប់ ឬ យ៉ាងណា ដូចជា សំណូក និងប្រាក់សគុណមិនស្របច្បាប់ ដើម្បីទទួលបានកិច្ចសន្យាពីរដ្ឋាភិបាល ថាតើចំណាយក្រៅផ្លូវការនាំឱ្យមានឧបសគ្គកម្រិតណាដល់ការធ្វើអាជីវកម្ម និងថាតើគេអាចព្យាករណ៍ទុកនូវចំណាយក្រៅផ្លូវការ និងទទួលបានលទ្ធផលតាមការរំពឹងទុក ឬយ៉ាងណា។

*៦. ការចូលរួម:*ការវាស់ស្ទង់ថាតើមានការពិគ្រោះយោបល់ជាមួយអាជីវកម្ម អំពីគោលនយោបាយដែលស្នើឡើង នៅថ្នាក់ខេត្តដែរឬទេ និងថាតើសមាគមអាជីវកម្ម ឬក្រុមដែលមានអាជីពដទៃទៀត បានធ្វើការតស៊ូមតិក្នុងនាមជាម្ចាស់អាជីវកម្មដែរឬទេ។

*៧. ការទប់ស្កាត់បទឧក្រិដ្ឋ:* ការវាស់ស្ទង់ថាតើអំពើចោរកម្មធ្វើឱ្យអាជីវកម្មត្រូវចំណាយប៉ុន្មាន និងតើក្រុមហ៊ុនត្រូវចំណាយប៉ុន្មាន លើសេវាសន្តិសុខ និង/ឬ "ថ្លៃការពារ" ដើម្បីទប់ស្កាត់បទឧក្រិដ្ឋ។

*៨. រដ្ឋបាលពន្ធដារ:* ការវាស់ស្ទង់នីតិវិធីរដ្ឋបាលដែលទាក់ទងនឹងការបង់ពន្ធ និងការចំណាយសម្រាប់ការបង់ពន្ធក្នុងខេត្ត។

*៩.កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំខេត្ត:* ការវាស់ស្ទង់គំនិតច្នៃប្រឌិត និងឆន្ទៈរបស់អាជ្ញាធរខេត្តនានា ក្នុងការបកស្រាយគោលនយោបាយជាតិ និងបទបញ្ញត្តិ ដើម្បីជួយដល់អាជីវកម្មឯកជនក្នុងខេត្ត និងក្នុងការបង្កើតគំនិតផ្តួចផ្តើមក្នុងខេត្ត ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍វិស័យឯកជន។

*១០. ការដោះស្រាយជម្លោះ:* ការវាស់ស្ទង់ការពេញចិត្តរបស់អាជីវកម្មទៅលើលទ្ធផលនៃការដោះស្រាយជម្លោះ ក្នុងខេត្តតាមយន្តការផ្លូវការ និងក្រៅផ្លូវការ។

## ២.៣ យុទ្ធសាស្ត្រនៃការអង្កេត

សន្ទស្សន៍នីមួយៗ ពឹងផ្អែកជាចម្បងលើចម្លើយរបស់ម្ចាស់អាជីវកម្មនៅកម្ពុជា ក្នុងឆ្នាំ២០០៩។ ដើម្បីធានាថា លទ្ធផលនេះពិតជាឆ្លុះបញ្ចាំងអំពីស្ថានភាពជាក់ស្តែងនៅទូទាំងប្រទេសនោះ យើងប្រើប្រាស់បច្ចេកទេសនៃការអង្កេតដែលមានលក្ខណៈស៊ីជម្រៅ និងបច្ចេកទេសជ្រើសរើសសំណាកសហគ្រាស ដែលជួយឱ្យគេជឿជាក់បានថា មិនមានខេត្ត ឬប្រភេទអាជីវកម្មណាមួយ ដែលមានតំណាងលើសលុប ឬតិចហួសហេតុនោះឡើយ ហើយដើម្បីធានាថា សំណួរអង្កេតអាចផ្តល់នូវចម្លើយដ៏មានអត្ថន័យគ្រប់គ្រាន់។ ជាសរុប ការអង្កេតនេះ បានធ្វើទៅលើម្ចាស់អាជីវកម្មចំនួន ១ ២៣៤នាក់ នៅទូទាំងប្រទេស។

ក្នុងចំណោមអ្នកឆ្លើយសំណួរចំនួន ១ ២៣៤នាក់ ដែលបានជ្រើសរើសដោយចៃដន្យ PBES ក៏បានសម្ភាសជាមួយតំណាងរបស់អាជីវកម្មចំនួន ១៩២ ដែលធ្លាប់បានចូលរួមក្នុងការអង្កេតរបស់ PBES ឆ្នាំ២០០៦។ សហគ្រិន

ដែលយើងបានសម្ភាសកាលពីលើកមុនទាំងនេះមានសារៈសំខាន់ចាំបាច់សម្រាប់ PBES ឆ្នាំ២០០៩ ពីព្រោះពួកគេមានបទពិសោធន៍អំពីបរិយាកាសអាជីវកម្មឆ្នាំ២០០៦ ថែមទាំងអាចធ្វើការប្រៀបធៀបដោយផ្ទាល់រវាងបទពិសោធន៍របស់អាជីវកម្មនាពេលកន្លងមក ជាមួយនឹងស្ថានភាពអាជីវកម្មឆ្នាំ២០០៩។ ការធ្វើដូចនេះ ផ្តល់ឱកាសប្រសើរបំផុត សម្រាប់ជួយឱ្យគេធ្វើការប្រៀបធៀបការផ្លាស់ប្តូរអភិបាលកិច្ចសេដ្ឋកិច្ចក្នុងរយៈពេលកន្លងមក។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីរបៀបនៃការធ្វើអង្កេត និងការជ្រើសរើសសំណាកសហគ្រាស និងរបៀបនៃការជ្រើសរើសអ្នកធ្លាប់បានសម្ភាសពីមុន សូមមើលឧបសម្ព័ន្ធក១។

# ៣. លក្ខណៈរបស់អាជីវកម្មក្នុងប្រទេសកម្ពុជា

ដើម្បីជាជំនួយដល់ការយល់ដឹងអំពីលទ្ធផលនៃការអង្កេតរបស់ PBES គេគួរពិនិត្យមើលស្ថិតិអាជីវកម្មដែលសំណាកសហគ្រាសត្រូវបានជ្រើសរើសសម្រាប់សួរសំណួរក្នុងការអង្កេតនេះ។ ដោយសារពុំទាន់មានស្ថិតិលំអិត និងអាចប្រៀបធៀបគ្នាបាន អំពីអាជីវកម្មក្នុង ២៤ ខេត្តក្រុង ក្រុមអ្នកស្រាវជ្រាវ PBES បានប្រមូលព័ត៌មានជាមូលដ្ឋានអំពីសហគ្រាស ខ្នាតតូចបំផុត តូច និងមធ្យម MSMEs នៅទីរួមខេត្តក្រុងនីមួយៗ ។ លើសពីនោះទៅទៀត នៅក្នុងខេត្តក្រុងចំនួន ១០ ដែលមានសកម្មភាពសេដ្ឋកិច្ចសស្រាក់សស្រាំបំផុត យើងបានប្រមូលព័ត៌មានជាមូលដ្ឋានទាំងនេះពីស្រុកមួយថែមទៀត។ ក្រុមអ្នកស្រាវជ្រាវបានចុះស្រង់ស្ថិតិអាជីវកម្មទាំងអស់ ក្នុងទីតាំង ៣គីឡូម៉ែត្រជុំវិញទីរួមខេត្តក្រុងនីមួយៗ និងបណ្តាស្រុកទាំងនោះ។ គេបានស្រង់ស្ថិតិអាជីវកម្មសរុបបានចំនួន ៦៣ ៥០៧ អាជីវកម្ម។ ដោយសារម្ចាស់អាជីវកម្ម ៩៥,៥ ភាគរយ បានយល់ព្រមផ្តល់ព័ត៌មានតាមការសាកសួររបស់ក្រុមអ្នកស្រាវជ្រាវនោះ ទិន្នន័យក្នុងស្ថិតិអាជីវកម្ម គឺពិតជាអាចឱ្យគេជឿជាក់បាន។

យើងមិនអាចចាត់ទុកថា ទិន្នន័យនេះ គឺជាជំរឿនពេញលក្ខណៈមួយនៃសកម្មភាពអាជីវកម្មទាំងអស់បានឡើយ ពីព្រោះយើងបានស្រង់តែស្ថិតិអាជីវកម្មក្នុងទីរួមខេត្តក្រុង និងស្រុកមួយចំនួន ដែលបានជ្រើសរើសប៉ុណ្ណោះ។ ដោយសារតែស្ថិតិអាជីវកម្មនេះ រួមបញ្ចូលសកម្មភាពអាជីវកម្មក្នុង១០ ស្រុកនិងទីរួមខេត្តទាំងអស់នោះទិន្នន័យនេះទំនងជាមានភាពលំអៀងបន្តិចទៅខាងតំបន់ទីប្រជុំជន។ លើសពីនេះទៅទៀត ក្រុមអ្នកស្រាវជ្រាវយើង ក៏ទំនងជាមើលរំលងទិន្នន័យពីក្រុមហ៊ុនកម្មន្តសាលខ្នាតធំមួយចំនួន ដែលស្ថិតនៅចម្ងាយលើសពី៣គីឡូម៉ែត្រពីទីរួមខេត្ត (ជាពិសេសសិប្បកម្មផលិតចំណីអាហារ)។ ទោះជាយ៉ាងណា ស្ថិតិអាជីវកម្មរបស់ PBES ពិតជាស្ថិតិដែលមានលក្ខណៈលម្អិតបំផុតនាបច្ចុប្បន្ននេះ ហើយការប្រើប្រាស់នីតិវិធីនៃការប្រមូលទិន្នន័យ ដែលមានលក្ខណៈជាប្រព័ន្ធបែបនេះ មានន័យថា ទិន្នន័យនេះអាចយកមកប្រៀបធៀបខេត្តទាំងអស់ក្នុងប្រទេសកម្ពុជាបាន។ ស្ថិតិអាជីវកម្ម ៦៣ ៥០៧ ក្នុង ២៤ ខេត្តក្រុងនេះ ជាក្របខ័ណ្ឌស្ថិតិសហគ្រាសដ៏ប្រសើរមួយ សម្រាប់ជ្រើសរើសសហគ្រិនចំនួន១២៣៤នាក់ដោយចៃដន្យសម្រាប់ការអង្កេតរបស់PBES ឆ្នាំ២០០៩។

មុននឹងពិនិត្យមើលអំពីរបៀបនៃការបង្កើតសន្ទស្សន៍ ការពិនិត្យឡើងវិញទៅលើចំណុចសំខាន់ៗមួយចំនួនលើវិស័យឯកជន នៅប្រទេសកម្ពុជា ពិតជាមានប្រយោជន៍ណាស់។ ទីមួយ ទោះបីជាការអភិវឌ្ឍន៍វិស័យឯកជនធ្វើឱ្យមានការទាក់ទាញយ៉ាងច្រើនក៏ដោយ ក៏ព័ត៌មាន

ស្ថិតិអំពីអាជីវកម្មឯកជនក្នុងប្រទេសកម្ពុជា មានតិចតួចបំផុតនាពេលបច្ចុប្បន្ននេះ។ តើអាជីវកម្មនៅប្រទេសកម្ពុជាមានលក្ខណៈបែបណា? តាមរយៈការផ្តល់ព័ត៌មានដ៏មានតម្លៃស្តីពីស្ថានភាពរបស់ផ្នែកឯកជននៅកម្ពុជា ការស្រង់ស្ថិតិអាជីវកម្ម និងព័ត៌មានអំពីអាជីវកម្មដែលទទួលបានពីការអង្កេតនេះ គឺបានផ្តល់ចម្លើយទូទៅជាច្រើនអំពីលក្ខណៈរបស់អាជីវកម្មនៅកម្ពុជា។ ទីពីរ ទិដ្ឋភាពដ៏ត្រឹមត្រូវច្បាស់លាស់ជាងមុន អំពីបរិយាកាសអាជីវកម្មនៅកម្ពុជា នឹងផ្តល់ឱ្យមានក្របខ័ណ្ឌមួយ សម្រាប់ការយល់ដឹងអំពីតម្រូវការជាក់លាក់នៃបរិយាកាសអាជីវកម្ម។ ចំណុចសំខាន់បំផុតសម្រាប់របាយការណ៍នេះ គឺជា ចំណុចទី៣ ដែលបង្ហាញថា លក្ខណៈនៃអាជីវកម្មក្នុងប្រទេសកម្ពុជា នឹងជួយឱ្យគេយល់បន្ថែមទៀតអំពីបរិបទនៃអាជីវកម្ម ដោយផ្អែកលើអ្នកឆ្លើយសំណួរនៃការអង្កេតនេះ ដែលត្រូវបានយកមកប្រើសម្រាប់ធ្វើការវាយតម្លៃរបស់ PBES។

## ៣.១ អាជីវកម្មក្នុងប្រទេសកម្ពុជាជាសហគ្រាសខ្នាតតូចបំផុត

លទ្ធផលរកឃើញដ៏គួរឱ្យចាប់អារម្មណ៍បំផុតនៃស្ថិតិអាជីវកម្មដែលមានអាជីវកម្មចំនួនជិត ៦៤ ០០០ នៅទូទាំងប្រទេសកម្ពុជានោះ គឺអាជីវកម្មភាគច្រើនមានទំហំតូចបំផុត។ អាជីវកម្មប្រមាណជា ៦៩ ភាគរយ មាននិយោជិតតែម្នាក់គត់ ពោលគឺម្ចាស់អាជីវកម្មតែម្តង។សហគ្រាសចំនួន៩០,៤ភាគរយ ដែលមានក្នុងស្ថិតិអាជីវកម្មនេះ មាននិយោជិតតិចជាង ៤នាក់ និងសហគ្រាស ៩៦ ភាគរយ មាននិយោជិតតិចជាង ១០នាក់។ ប្រសិនបើគេផ្តល់និយមន័យទូទៅមួយ សម្រាប់សហគ្រាសខ្នាតតូចបំផុត ថាជាសហគ្រាស ដែលមាននិយោជិតក្រោម ១០នាក់[៤] នោះសហគ្រាសប្រមាណជា ៩៦ ភាគរយនៃសហគ្រាសក្នុងប្រទេសកម្ពុជា គឺជាប្រភេទសហគ្រាសខ្នាតតូចបំផុត។

**រូបទី១ : ការបែងចែកសហគ្រាសតាមទំហំ**

*(តាមចំនួននិយោជិត ដោយមិនរាប់បញ្ចូលម្ចាស់អាជីវកម្ម)*




[៤] និយមន័យដែលប្រើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

### តារាងទី១: ការប្រែប្រួលនៃការបែងចែកទំហំសហគ្រាសរបស់ស្ថិតិអាជីវកម្ម PBES (ឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៩)

| ទំហំសហគ្រាស (និយោជិត) | ឆ្នាំ២០០៦ | ឆ្នាំ២០០៦ % | ខេត្ត១០ដំបូង នៅឆ្នាំ២០០៩ | ភាគរយនៃ ខេត្ត១០ដំបូង នៅឆ្នាំ ២០០៩ | ខេត្តទាំងអស់ នៅឆ្នាំ២០០៩ | ភាគរយនៃ ខេត្តទាំងអស់ នៅឆ្នាំ២០០៩ | កំណើន-នៅក្នុង ខេត្ត១០ដំបូង |
|---|---|---|---|---|---|---|---|
| ០ ( មានតែម្ចាស់អាជីវកម្ម) | ២៩ ៨៤១ | ៧១,៤% | ៣៥ ៧៧៨ | ៦៧,៣% | ៤៣ ៧០៩ | ៦៨,៨% | ១៩,៩% |
| ១ ទៅ ៤នាក់ | ៨ ៧០៣ | ២០,៨% | ១១ ៧៥៥ | ២២,១% | ១៣ ៦៨៩ | ២១,៦% | ៣៥,១% |
| ៥ ទៅ ៩ នាក់ | ២ ១២៦ | ៥,១% | ៣ ២៧០ | ៦,២% | ៣ ៥៩៧ | ៥,៧% | ៥៣,៨% |
| ១០ ទៅ ២០ នាក់ | ៧៣៣ | ១,៨% | ១ ៣០៤ | ២,៥% | ១ ៤២៤ | ២,២% | ៧៧,៩% |
| ចាប់ពី ២០ នាក់ ឡើង | ៣៧២ | ០,៩% | ១ ០២១ | ១,៩% | ១ ០៨៨ | ១,៧% | ១៧៤,៥% |
| សរុប | ៤១ ៧៧៥ | ១០០% | ៥៣ ១២៨ | ១០០% | ៦៣ ៥០៧ | ១០០% | ២៧,២% |
| ចំនួនបុគ្គលិកសរុបក្នុងអាជីវកម្មនីមួយៗ | ២,០១ | | ២,៣២ | | ២,០៨ | | ១៥,៤% |

ស្ថិតិអាជីវកម្មលំអិតឆ្នាំ២០០៦ និងឆ្នាំ២០០៩ មានភាពខុសគ្នាបន្តិចបន្តួច ក្នុងការជ្រើសរើសសំណាកសហគ្រាស ។ នៅឆ្នាំ២០០៦ ក្រុមអ្នកស្រាវជ្រាវយើងបានរាប់ស្រុកចំនួនបី ដែលមានចំនួនប្រជាជនច្រើនជាងគេ នៅក្នុងខេត្តនីមួយៗ ។ នៅឆ្នាំ២០០៩ ក្រុមការងារស្រាវជ្រាវយើងបានរាប់តែទីរួមខេត្ត និងស្រុកមួយនៅក្នុងខេត្តទាំង ១០ ដែលមានសេដ្ឋកិច្ចដំណើរការទៅយ៉ាងសកម្ម ។

ថ្វីបើរបាយការណ៍នេះ ប្រើពាក្យមួយចំនួនផ្លាស់ប្តូរគ្នាទៅវិញទៅមក ដូចជាសហគ្រាសធុនតូចបំផុត តូច និង មធ្យម ឬ "ក្រុមហ៊ុន" ឬ "សហគ្រាស" ឬ "អាជីវកម្ម" ក៏ដោយ ក៏ចំណុចដែលគួរចងចាំនោះគឺថា អាជីវកម្មទាំង ៩៦ ភាគរយនេះ គឺជាសហគ្រាសខ្នាតតូចបំផុត។ តារាងទី ១ បង្ហាញអំពីការប្រៀបធៀបស្ថិតិអាជីវកម្មរបស់ PBES ឆ្នាំ ២០០៦ និងឆ្នាំ២០០៩ ដើម្បីសិក្សាការប្រែប្រួលរបស់សហគមន៍អាជីវកម្ម នាពេលកន្លងមកនេះ។ ជារួម ការបែងចែកប្រភេទនៃទំហំសហគ្រាស បានផ្លាស់ប្តូរបន្តិចបន្តួចប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ២០០៦ មក។ អាជីវកម្មដែលមាននិយោជិតតិចជាង ៤នាក់ នៅតែជាសហគ្រាស ដែលមានចំនួនច្រើនបំផុត (៩០,៤ ភាគរយ ក្នុងឆ្នាំ២០០៦ និងមានចំនួន ៨៩ ភាគរយនាពេលបច្ចុប្បន្ន)។

## ៣.២ អាជីវកម្មខ្នាតតូច និងមធ្យម ក្នុងប្រទេសកម្ពុជា មានការកើនឡើង[៥]

ជារួម អាជីវកម្មកាន់តែច្រើន កំពុងចាប់ផ្តើមដំណើរការនៅក្នុងប្រទេសកម្ពុជា។ ប្រសិនបើយើងគ្រាន់តែពិនិត្យមើលលើអាជីវកម្មដែលបានអង្កេតក្នុងខេត្តទាំង១០ដែលបានស្រង់ស្ថិតិអាជីវកម្មឆ្នាំ២០០៦ (ចាប់ពីពេលនេះទៅ ហៅថា "ខេត្តដំបូងទាំង ១០") យើងឃើញថា ចំនួនអាជីវកម្មសរុបមានការកើនឡើងត្រឹម ២៧ភាគរយ ក្នុងអំឡុងពេល២ឆ្នាំ

[៥] ចំពោះការវិភាគកាន់តែលំអិតទៅលើការប្រែប្រួលក្នុងអាជីវកម្ម និងចំនួនអាជីវកម្មដែលត្រូវបានជ្រើសរើសសាជាថ្មី ដើម្បីដឹងពីភាពខុសៗគ្នានៃអាជីវកម្មក្នុងខេត្តទាំងអស់ សូមមើលឧបសម្ព័ន្ធទីក ១ និង តារាង ក១។

កន្លងទៅនេះ។ ថ្វីបើមានភាពខុសគ្នាក្នុងវិធីសាស្ត្រដែលប្រើដើម្បីស្រង់ស្ថិតិអាជីវកម្ម[៦] ឆ្នាំ២០០៦ និងឆ្នាំ២០០៩ ក៏ដោយ ក៏ភាពខុសគ្នានេះប្រហែលជាធ្វើឱ្យយើងប៉ាន់ស្មានកំណើនអាជីវកម្មទាបជាងកំរិតជាក់ស្តែង។ ស្ថានភាពជាក់ស្តែងបង្ហាញថា សហគ្រិនកាន់តែច្រើន កំពុងប្រថុយ ក្នុងការចាប់ផ្តើមអាជីវកម្ម ហើយជាងនេះទៅទៀត អត្រាកំណើនអាជីវកម្មនេះមានកម្រិតខ្ពស់បំផុតសម្រាប់អាជីវកម្មខ្នាតតូច និងមធ្យម។ចំនួនអាជីវកម្មដែលមាននិយោជិតពី១០ទៅ២០នាក់កើនឡើងស្ទើរតែទ្វេរដង ក្នុងអំឡុងពេលបីឆ្នាំកន្លងទៅនេះ ក្នុងខណៈនោះដែរ អាជីវកម្មដែលមាននិយោជិតច្រើនជាង២០នាក់ បានកើនឡើងជិត ២០០ ភាគរយ។ ទោះបីស្ថិតក្នុងដំណាក់កាលកំពុងចាប់ផ្តើមក៏ដោយ ក៏ការកើនឡើងនៃចំនួនអាជីវកម្មទាំងនេះ នឹងចូលរួមឱ្យមានកំណើនការងារ និងការកាត់បន្ថយភាពក្រីក្រ ក្នុងរយៈពេលយូរអង្វែង។

## ៣.៣ ចំនួនអាជីវកម្មដែលប្រមូលផ្តុំក្នុងទីក្រុងភ្នំពេញ កំពុងថយចុះ

ដូចមានបង្ហាញក្នុងរូបទី ២ ស្ថិតិអាជីវកម្មបង្ហាញថា សហគ្រាសយ៉ាងច្រើន ប្រមូលផ្តុំក្នុងទីក្រុងភ្នំពេញ និងតាមខេត្តស្ថិតនៅជុំវិញទីក្រុងភ្នំពេញ។ ទីក្រុងភ្នំពេញ មានសហគ្រាសរហូតដល់ទៅ ៤៥ ភាគរយនៃសហគ្រាសទាំងអស់។ ទោះបីនេះជាចំណែក ដ៏ច្រើនក៏ដោយ ប៉ុន្តែតួលេខនេះតិចជាងឆ្នាំ២០០៦ ច្រើនណាស់ ដែលនៅពេលនោះទីក្រុងភ្នំពេញមានអាជីវកម្ម ៦០ ភាគរយ នៃអាជីវកម្មទាំងអស់។ ក្នុងស្ថិតិអាជីវកម្មនាពេលបច្ចុប្បន្ននេះ ខេត្តបាត់ដំបងមានអាជីវកម្មតិចជាងទីក្រុងភ្នំពេញយ៉ាងច្រើន ពោលគឺមានអាជីវកម្ម ១០ ភាគរយនៃចំនួនអាជីវកម្មក្នុងស្ថិតិអាជីវកម្មចំណែកខេត្តកណ្តាលដែលនៅជាប់ទីក្រុងភ្នំពេញមាន

**រូបទី២ : ស្ថិតិអាជីវកម្ម PBES ឆ្នាំ២០០៩ :**

*សហគ្រាសបែងចែកតាមទីតាំងភូមិសាស្ត្រ*




៦ PBES ឆ្នាំ២០០៦ បានស្រង់ស្ថិតិអាជីវកម្មទាំងអស់ក្នុងស្រុកធំបំផុតចំនួន៣ និងទីរួមខេត្ត រីឯ PBES ឆ្នាំ២០០៩ បានស្រង់ស្ថិតិតែអាជីវកម្មក្នុងទីរួមខេត្ត និងស្រុកមួយទៀតនៃខេត្ត១០ ដែលមានសកម្មភាពសេដ្ឋកិច្ចសស្រាក់សស្រាំជាងគេប៉ុណ្ណោះ។

អាជីវកម្មចំនួន៧ភាគរយ ។ ភាគរយដ៏ច្រើននៃអាជីវកម្មដែលប្រមូលផ្តុំក្នុងទីក្រុងភ្នំពេញ គឺមានលក្ខណៈដូចគ្នានឹងទីក្រុងដទៃទៀតនៃប្រទេសកំពុងអភិវឌ្ឍន៍ ទាំងនៅតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសផ្សេងៗទៀតដែរ ។

## ៣.៤ អាជីវកម្មភាគច្រើនធ្វើសកម្មភាពតែក្នុងខេត្ត ដែលខ្លួនកំពុងរស់នៅប៉ុណ្ណោះ

អាជីវកម្ម មិនត្រឹមតែមានទំហំតូចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើសកម្មភាពតែក្នុងខេត្តរបស់ខ្លួនទៀតផង ។អាជីវកម្មដែលបានអង្កេតចំនួន ៩0 ភាគរយ មានសកម្មភាពតែក្នុងខេត្តកំណើតរបស់ខ្លួនប៉ុណ្ណោះ ហើយមានតែ ១0 ភាគរយប៉ុណ្ណោះដែលជាអាជីវកម្មនាំចេញ ។ អាជីវកម្មក្នុងទីក្រុងភ្នំពេញ មានលក្ខណៈទូលំទូលាយជាងតំបន់ផ្សេងៗទៀតក្នុងប្រទេស ដោយសារមានអាជីវកម្ម ១៦ ភាគរយ ធ្វើសកម្មភាពទាក់ទងនឹងការនាំចេញ ។[៧]

## ៣.៥ អាជីវកម្មភាគច្រើន ស្ថិតនៅក្នុងវិស័យសេវាកម្ម ឬពាណិជ្ជកម្ម

ប្រសិនបើយើងបែងចែកក្រុមហ៊ុនតាមវិស័យ ស្ថិតិអាជីវកម្ម និងការអង្កេត PBES បង្ហាញថា សហគ្រាស ៩៣,៥ ភាគរយ ផ្តោតលើសេវាកម្ម ឬពាណិជ្ជកម្ម ( សេវា ៤៨,២ ភាគរយ និង ពាណិជ្ជកម្ម ៤៥,៣ ភាគរយ) រីឯក្រុមហ៊ុនកម្មន្តសាល និងក្រុមហ៊ុនសំណង់ មានត្រឹមតែ ៥,៤ ភាគរយ ហើយការធ្វើអាជីវកម្មលើធនធានធម្មជាតិ មានប្រហែលជា ១ ភាគរយប៉ុណ្ណោះ ។ រូបទី៣ បង្ហាញអំពីទិន្នន័យទទួលបានពីស្ថិតិអាជីវកម្មលម្អិត ។

## ៣.៦ ស្ត្រីមានភាពសកម្មក្នុងដំណើរការអាជីវកម្ម

តួនាទីសំខាន់របស់ស្ត្រីក្នុងវិស័យឯកជន មានបង្ហាញក្នុងរូបទី៤ ។ ដោយសារម្ចាស់អាជីវកម្មជាស្ត្រី មានចំនួន ៦២

**រូបទី៣ : ស្ថិតិអាជីវកម្ម PBES ឆ្នាំ២00៩**

*សហគ្រាសបែងចែកតាមវិស័យ*




[៧] ដោយសារតែភាពខុសគ្នាផ្នែកតួលេខពីទីក្រុងភ្នំពេញ និងភាពតំណាងឱ្យក្រុមហ៊ុនថ្នាក់ជាតិ មិនបានគ្រប់គ្រាន់ យើងឃើញថា សំណាកសហគ្រាសថ្នាក់ជាតិ មានភាពខុសគ្នាបន្តិចបន្តួចពីសំណាកសហគ្រាសក្នុង PBES ។ សូមមើលតារាង ក១ សម្រាប់សេចក្តីលំអិតបន្ថែម ។

**រូបទី៤ ៖ ស្ថិតិអាជីវកម្ម PBES ឆ្នាំ២០០៩**

*ភាគរយនៃសហគ្រាសបែងចែកតាមភេទរបស់ម្ចាស់អាជីវកម្ម*




ភាគរយ នៃអាជីវកម្មដែលបានស្រង់ស្ថិតិ ដូចនេះ ស្ត្រីមានតួនាទីសំខាន់ក្នុងការជួយឱ្យមានកំណើនសេដ្ឋកិច្ច។ ទោះជាយ៉ាងនោះក្ដី ពីខេត្តមួយទៅខេត្តទៀត តួយ៉ាងដូចជា ខេត្តព្រៃវែង មានម្ចាស់សហគ្រាសជាស្ត្រីយ៉ាងច្រើនលើសលប់ (ស្មើរតែ ៧៥ ភាគរយ)។

### ៣.៧ អាជីវកម្មភាគច្រើនទើបតែចាប់ផ្ដើមដំណើរការ

ចុងក្រោយនេះ ស្ថិតិអាជីវកម្មបង្ហាញថា អាជីវកម្មភាគច្រើន ទើបតែចាប់ផ្ដើមដំណើរការ។ អាជីវកម្មចំនួន ៤២ ភាគរយ បានដំណើរការតិចជាង២ឆ្នាំ ចំណែកឯសហគ្រាសចំនួន ២២ ភាគរយទៀត បានធ្វើសកម្មភាពតិចជាង ៥ឆ្នាំ (រូបទី៥)។ តួលេខនេះបង្ហាញថា សកម្មភាពអាជីវកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ២-៣ឆ្នាំកន្លងមកនេះ។ លទ្ធផលនេះ មានឥទ្ធិពលយ៉ាងខ្លាំងសម្រាប់ការវិភាគលើលទ្ធផលអង្កេតនេះ។ កំណើនយ៉ាងឆាប់រហ័សនៃការចាប់ផ្ដើមសហគ្រាសថ្មីៗក្នុងរយៈពេល ២-៣ឆ្នាំកន្លងមកនេះ មានន័យថា អាជីវកម្មជាច្រើនទើបតែដំណើរការ ហើយមិនទាន់បានចុះបញ្ជីពាណិជ្ជកម្ម និងចូលរួមក្នុងវិស័យជំនួញផ្លូវការនៅឡើយទេ។

### ៣.៨ កំណើនអាជីវកម្មទំនងជានៅតែបន្ត

ដោយផ្អែកលើទិន្នន័យទទួលបានពីការអង្កេតរបស់ PBES ចំនួនអាជីវកម្មក្នុងវិស័យឯកជន ទំនងជានឹងបន្ត

កើនឡើង។ ៤៩ ភាគរយ នៃសហគ្រាសដែលបានចូលរួមក្នុងការអង្កេតរបស់ PBES មានបំណងពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួន ក្នុងរយៈពេលពីរឆ្នាំខាងមុខទៀត។ ទោះជាយ៉ាងនោះក្តី គេគួរតែធ្វើការពិចារណាដោយប្រុងប្រយ័ត្ន អំពីតួលេខទាំងនេះ ពីព្រោះការអង្កេតនេះ បានធ្វើឡើងមុនពេលមានវិបត្តិហិរញ្ញវត្ថុអន្តរជាតិ នៅចុងឆ្នាំ ២០០៨។

**រូបទី៥ : ស្ថិតិអាជីវកម្ម PBES ឆ្នាំ២០០៩** – *ភាគរយនៃសហគ្រាសបែងចែកតាមចំនួនឆ្នាំនៃដំណើរការអាជីវកម្ម*



# ៤. ការផ្តល់ចំណាត់ថ្នាក់របស់ PBES ឆ្នាំ២០០៩ : ការពន្យល់ និង ការវិភាគ[៨]

ផ្នែកខាងក្រោមទាំងនេះ បង្ហាញអំពីការផ្តល់ចំណាត់ថ្នាក់របស់ PBES ហើយពិភាក្សាអំពីចំណាត់ថ្នាក់ទាំងនេះតាមបរិបទនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។

## ៤.១ ចំណាត់ថ្នាក់

រូបទី៦ បង្ហាញអំពីលទ្ធផលរបស់ PBES ក្នុងប្រទេសកម្ពុជានាឆ្នាំ២០០៩។ លទ្ធផលនេះជាផលបូកពិន្ទុសន្ទស្សន៍នីមួយៗនៃសន្ទស្សន៍ទាំង១០ តាមខេត្តក្រុង។ ដោយសារសន្ទស្សន៍នីមួយៗអាច មានពិន្ទុរហូតដល់ ១០ ដូចនេះចំណាត់ថ្នាក់ចុងក្រោយ អាចមានកម្រិតពិន្ទុ ១០០។ ដើម្បីទទួលបានពិន្ទុល្អឥតខ្ចោះនោះ ខេត្តមួយគួរតែមានចំណាត់ថ្នាក់លេខ១ លើសូចនាករទាំងអស់របស់ PBES។ សំខាន់នោះ គឺត្រូវចាំថាចំណាត់ថ្នាក់នេះផ្អែកលើការអនុវត្តន៍ដែលមានលក្ខណៈប្រសើរបំផុតក្នុងប្រទេសកម្ពុជា។ ខេត្តទាំងនេះ មិនត្រូវបានយកមកប្រៀបធៀបជាមួយនឹងការវាស់ស្ទង់ដែលមានលក្ខណៈឥតខ្ចោះ ហើយដែលជាអ្វីដែលគេពុំអាចសម្រេចបាននោះឡើយ។

ភ័ស្តុតាងស្តីពីចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម ដែលបានពីខេត្តកោះកុង ដែលជាខេត្តមួយ បានទទួលចំណាត់ថ្នាក់ខ្ពស់ក្នុង PBES ឆ្នាំ២០០៩។

**ប្រធានគ្រប់គ្រងសហគ្រាសកម្មន្តសាលៈ** "ខ្ញុំមិនចាំបាច់ទៅកាន់ការិយាល័យរដ្ឋាភិបាលដើម្បីដាក់ពាក្យសុំធ្វើអាជីវកម្មឡើយ។ ផ្ទុយទៅវិញ មន្ត្រីទាំងនោះបានមករកខ្ញុំវិញ។ ខ្ញុំរង់ចាំ ១ សប្តាហ៍ដើម្បីទទួលបានប័ណ្ណប៉ាតង់ និង៣ថ្ងៃ ដើម្បីទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្ម ពីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត។"

**ម្ចាស់ហាងលក់សម្ភារៈអគ្គិសនីៈ** មន្ត្រីរដ្ឋាភិបាលបានមកកាន់ហាងរបស់ខ្ញុំដោយមាន ទាំងពាក្យសុំការអនុញ្ញាតធ្វើអាជីវកម្មមកជាមួយផងដែរ។ តែក្នុងរយៈពេល ១សប្តាហ៍ប៉ុណ្ណោះខ្ញុំទទួលបានប័ណ្ណប៉ាតង់ និង១សប្តាហ៍ទៀតខ្ញុំទទួលបានលិខិតអនុញ្ញាតធ្វើអាជីវកម្មពីមន្ទីរពាណិជ្ជកម្មខេត្ត។

**ម្ចាស់ភោជនីយដ្ឋាន :** ប័ណ្ណប៉ាតង់ចំណាយពេលធ្វើតែ ១ថ្ងៃប៉ុណ្ណោះបន្ទាប់ពីយើងបានរៀបចំឯកសារចាំបាច់ទាំងអស់ដាក់ជូនទៅប្រធានភូមិ និងមេឃុំ ហើយទៅយកឯកសារទាំងនោះមកវិញ បន្ទាប់ពីមន្ត្រីទាំងនោះសម្រេចរួច។ ខ្ញុំត្រូវចរចាអំពីថ្លៃពាក្យសុំ ដោយសារមន្ត្រីទាំងនោះ មិនមានតារាងតម្លៃជាផ្លូវការឡើយ។ សេវាច្រកចេញចូលតែមួយពិតជាប្រសើរណាស់ដើម្បីដោះស្រាយការងារស្តីពីការបើកអាជីវកម្ម។

៨ សម្រាប់ការពន្យល់លំអិតពីរបៀបបូកសរុបពិន្ទុ សូមមើលឧបសម្ព័ន្ធក ២ និងរបាយការណ៍បច្ចេកទេស (ឆ្នាំ ២០០៦ និង ឆ្នាំ ២០០៩)។

## ៤.១.១ ខេត្តកំពង់ចាម នៅតែរក្សាចំណាត់ថ្នាក់ខ្ពស់បំផុត

ដូចគ្នានឹងឆ្នាំ២០០៦ ដែរ ខេត្តកំពង់ចាមនៅតែរក្សាតំណែងរបស់ខ្លួនជាខេត្តមានចំណាត់ថ្នាក់ខ្ពស់បំផុត ថ្វីបើនៅឆ្នាំ ២០០៩ ខេត្តដែលបានចំណាត់ថ្នាក់ទី១ និងទី២មានគម្លាតពីគ្នាកាន់តែតូចទៅក៏ដោយ។ ក្នុងឆ្នាំ២០០៦ ខេត្តកំពតមានចំណាត់ថ្នាក់លេខ៤ តែនៅពេលនេះ បានឡើងមកចំណាត់ថ្នាក់លេខ២។ បច្ចុប្បន្ននេះ ខេត្តកំពត និងខេត្តកំពង់ចាម មានគម្លាតពីគ្នាតែ២ពិន្ទុប៉ុណ្ណោះ ប៉ុន្តែនៅឆ្នាំ ២០០៦ វិញ ខេត្តកំពង់ចាម និងខេត្តស្វាយរៀងដែលជាខេត្តជាប់ចំណាត់ថ្នាក់ទី២ មានគម្លាតពីគ្នាជិត៩ពិន្ទុ។

ទោះបីជាខេត្តកំពង់ចាមនៅតែឈរក្នុងតំណែងទីមួយក៏ដោយ ក៏ខេត្តនេះនៅតែមានវិស័យអភិបាលកិច្ចមួយចំនួន ដែលតម្រូវឱ្យមានការកែលម្អជាចាំបាច់។ ទោះជាមន្ត្រីខេត្តបន្តទទួលបានពិន្ទុខ្ពស់លើកិច្ចខិតខំប្រឹងប្រែងក្នុងការជួយវិស័យឯកជន និងការដោះស្រាយជម្លោះក៏ដោយ ក៏ពិន្ទុសន្ទស្សន៍ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម ការទទួលបានដីធ្លី តម្លាភាព និងចំណាយក្រៅផ្លូវការ មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់។

ខេត្តព្រះសីហនុ និងខេត្តចំនួន៥ថ្មីៗទៀត (កោះកុង ពោធិ៍សាត់ ឧត្តរមានជ័យ រតនគិរី និងព្រៃវែង) ចូលក្នុងបញ្ជីខេត្ត ដែលមានពិន្ទុលើសពី៦០។ ទីក្រុងភ្នំពេញ ជារាជធានី និងជាបេះដូងនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា មានចំណាត់ថ្នាក់ទាបជាងគេបំផុត។ ទីក្រុងភ្នំពេញ មានគម្លាតជាង៦ពិន្ទុពីខេត្តដែលទទួលបានពិន្ទុទាបដទៃទៀត។

**រូបទី៦ : ចំណាត់ថ្នាក់របស់ PBES ឆ្នាំ២០០៩**




**ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្ត ឆ្នាំ២០០៩**

**រូបទី ៧ : ចំណាត់ថ្នាក់របស់ PBES ឆ្នាំ២០០៦**




## ៤.១.២ ករណីទីក្រុងភ្នំពេញ

ការទទួលបានពិន្ទុយ៉ាងទាបរបស់ទីក្រុងភ្នំពេញ តម្រូវឱ្យមានការបកស្រាយជាពិសេស។ ក្នុងស្ថានភាពមួយចំនួន ទីក្រុងភ្នំពេញរងឥទ្ធិពលមិនល្អពីការពង្រីកក្រុង និងដង់ស៊ីតេប្រជាជនខ្ពស់ ដែលបញ្ហានេះមិនកើតឡើងច្រើននៅតាមខេត្តក្រុងដទៃទៀតទេ។ មន្ត្រីរាជការក្នុងទីក្រុងភ្នំពេញខំប្រឹងតាមលទ្ធភាពដែលគេអាចធ្វើទៅបាន ដើម្បីផ្តល់សេវាដល់ប្រជាពលរដ្ឋដ៏ច្រើននេះ និងដើម្បីបំពេញតម្រូវការជាច្រើនយ៉ាង និងស្មុគស្មាញរបស់ប្រជាជន។ គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលនោះទេ ដែលថាការចំណាយពេលរង់ចាំឯកសារអាជីវកម្ម និងប័ណ្ណកម្មសិទ្ធិដីធ្លី យូរជាងខេត្តក្រុងដទៃទៀត។ ជាធម្មតា មន្ត្រីរាជរដ្ឋាភិបាល និងធនធាននានា (ជាពិសេសដីធ្លី) មានចំនួនមិនគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការនានា។ ក្រៅពីកង្វះមន្ត្រីរាជការ ការពង្រីកក្រុង ក៏នាំមកនូវបញ្ហាផ្សេងៗដែរ (ដូចជា បទឧក្រិដ្ឋ ការបំពុលបរិស្ថាន ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធហួសកម្រិត និងតម្រូវការចំណាយក្នុងការថែទាំហេដ្ឋារចនាសម្ព័ន្ធទាំងនោះ)។ បញ្ហាទាំងនេះ បង្កឱ្យមានបញ្ហាប្រឈមនានា ដែលតំបន់ដទៃទៀតពុំជួបប្រទះ។ ដូច្នេះការទទួលពិន្ទុទាបរបស់ទីក្រុងភ្នំពេញ អាចបញ្ជាក់ពីការពិតមួយផ្នែកបានដោយសារ ក្រុងភ្នំពេញមានស្ថានភាពពិសេសដោយឡែក ដែលជាមជ្ឈមណ្ឌលសម្រាប់ជីវភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសកម្ពុជា។

ប៉ុន្តែពិន្ទុនៃសន្ទស្សន៍ជាច្រើនរបស់ទីក្រុងភ្នំពេញ មិនអាចលើកមកពន្យល់បានទេ ដោយសារស្ថានភាពស្មុគស្មាញ នៃទីប្រជុំជននៅទីក្រុងភ្នំពេញ។ អ្នកផ្តល់ចំលើយសំភាសន៍ក្នុងទីក្រុងភ្នំពេញបានបង្ហាញថា គុណភាពនៃការផ្តល់សេវារបស់មន្ត្រីរាជការមានកំរិតទាប។ ទិន្នន័យ PBES ឆ្នាំ២០០៩ បង្ហាញថាមិនមានស្ថានភាពដូចនេះក្នុងខេត្តផ្សេងទៀតទេ។ ដូចមានបង្ហាញក្នុងតារាងទី២ ម្ចាស់អាជីវកម្មក្នុងទីក្រុងភ្នំពេញ ហាក់ដូចជាមានទំនោរខ្ពស់ជាងខេត្តក្រុងផ្សេងទៀតក្នុងការ : ១) ផ្តល់សំណូកបន្ថិចបន្តួចដល់មន្ត្រីមូលដ្ឋាន ២) ផ្តល់កម្រៃជើងសារដើម្បីទទួលបានកិច្ចសន្យាពីរដ្ឋាភិបាល ៣) បង់ថ្លៃការពារដល់ មន្ត្រីប៉ូលីសមូលដ្ឋាន ដើម្បីជៀសផុតពីបទឧក្រិដ្ឋ និង ៤) ចរចាអំពីការបង់ពន្ធដារជាមួយមន្ត្រីមូលដ្ឋាន។

**តារាងទី២ ៖ ការប្រៀបធៀបបរិយាកាសអាជីវកម្មនៅទីក្រុងភ្នំពេញ ជាមួយបណ្ដាខេត្តក្រុងផ្សេងៗទៀត**

| សូចនាករ | ភ្នំពេញ | ខេត្តក្រុងផ្សេងៗ |
|---|---|---|
| ភាគរយនៃសហគ្រាសដែលបដិសេធមិនផ្ដល់សំណូក | ៤៥% | ៦៨% |
| ភាគរយនៃសហគ្រាសដែលបដិសេធមិនផ្ដល់កម្រៃជើងសារដើម្បីទទួលបានកិច្ចសន្យាពីរដ្ឋាភិបាល | ១៣% | ៣២% |
| ភាគរយនៃសហគ្រាសដែលបង់ថ្លៃការពារដល់មន្ត្រីប៉ូលិសមូលដ្ឋាន | ៣០% | ៥% |
| ភាគរយនៃសហគ្រាសដែលចរចាលើការបង់ពន្ធជាមួយមន្ត្រីមូលដ្ឋាន | ៦៧% | ៥៧% |

វាជាការណ៍ដែលនាំឱ្យមានចម្ងល់តិចតួចទេដែលថា ម្ចាស់អាជីវកម្មក្នុងក្រុងភ្នំពេញ ហាក់ដូចជាបន្ទោសរាជរដ្ឋាភិបាល ចំពោះការលំបាករបស់ពួកគេ (មន្ត្រីរាជការមានឥរិយាបទវិជ្ជមានមានតែ ៣២ ភាគរយប៉ុណ្ណោះ) និងម្ចាស់អាជីវកម្មជាច្រើនខ្វះទំនុកចិត្តលើស្ថាប័នរដ្ឋ (ម្ចាស់អាជីវកម្មចំនួន ១៨ ភាគរយប៉ុណ្ណោះ ដែលមានជំនឿថាអាជ្ញាធរមូលដ្ឋាននឹងការពារកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួន)។ ធ្ងន់ធ្ងរជាងនេះទៅទៀត អភិបាលកិច្ចមិនល្អ បានជះឥទ្ធិពលដល់ឥរិយាបទរបស់សហគ្រិនមូលដ្ឋានក្នុងទីក្រុងភ្នំពេញ។ ដោយឡែក សហគ្រិនចំនួន ៦០ ភាគរយ នៅតាមខេត្តក្រុងមានផែនការពង្រីកអាជីវកម្មរបស់ខ្លួនក្នុងអំឡុងពេល ២ឆ្នាំខាងមុខទៀត ប៉ុន្តែសហគ្រិននៅទីក្រុងភ្នំពេញ អាជីវកម្មតែ ៤៥ ភាគរយប៉ុណ្ណោះ មានផែនការពង្រីកអាជីវកម្មរបស់ខ្លួន។ តាមពិតក្រុមហ៊ុនក្នុងទីក្រុងភ្នំពេញ ៣,៦ ភាគរយកំពុងតែមានផែនការបិទអាជីវកម្មក្នុងរយៈ ពេល២ឆ្នាំខាងមុខទៀត។ នៅខេត្តផ្សេងៗទៀតមានក្រុមហ៊ុនតែ១ភាគរយប៉ុណ្ណោះ ដែលបង្ហាញពីក្ដីអស់សង្ឃឹមបែបនេះ។

ទីក្រុងភ្នំពេញ នឹងនៅតែជាមជ្ឈមណ្ឌលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្នុងពេលអនាគតខាងមុខ។ ទីក្រុងនេះនឹងនៅតែជា ទីកន្លែងសំខាន់បំផុតនៃសកម្មភាពអាជីវកម្មធំៗ ដែលទាក់ទាញវិនិយោគច្រើនបំផុត និងទាក់ទាញមនុស្សដែលមានទេពកោសល្យ និងសមត្ថភាពខ្ពស់ជាងគេ។ ភាពជោគជ័យទាំងនេះពុំមែនបណ្ដាលមកពីអភិបាលកិច្ចល្អទេ ប៉ុន្តែមកពីអំណោយផលដែលមានស្រាប់របស់ទីក្រុងភ្នំពេញ រួមមានផ្សារធំៗក្នុងទីប្រជុំជន ដែលសម្បូរដោយទំនិញ និងសេវា ប្រជាជនដែលមានការអប់រំខ្ពស់បំផុត ហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរជាងគេ តម្លៃថាមពលទាបជាងគេ ហើយស្ថិតនៅជិតរដ្ឋាភិបាល ដែលផ្ដល់ឱកាសឱ្យអាជីវករនៅក្នុងក្រុងនេះមានលទ្ធភាពទទួលបានកិច្ចសន្យាដែលផ្ដល់ប្រាក់ចំណេញពីរដ្ឋាភិបាលថ្នាក់ជាតិ។ ទោះជាយ៉ាងនោះក្ដី អភិបាលកិច្ចក្នុងទីក្រុងភ្នំពេញ នឹងបន្តបង្កការលំបាកដល់កំណើនទូទៅ។ ទីក្រុងភ្នំពេញ នឹងមិនអាចសម្រេចបានសក្ដានុពលសេដ្ឋកិច្ចពេញលេញទៅតាមអំណោយផលដែលមានស្រាប់របស់ខ្លួនឡើយ លុះត្រាតែមានការកែលម្អគុណភាពសេវាដែលផ្ដល់ឱ្យដោយរបស់មន្ត្រីរាជការមួយចំនួននិងកាត់បន្ថយហានិភ័យនៃការធ្វើអាជីវកម្ម។

## ៤.២ ខេត្តមួយចំនួនមានពិន្ទុល្អជាងមុនក្នុងរយៈពេលកន្លងមក

ចាប់តាំងពីការអង្កេតរបស់ PBES ឆ្នាំ២០០៦មក ខេត្តក្រុងមួយចំនួន បានចាត់វិធានការសំខាន់ៗដើម្បីកែលម្អបរិយាកាសអាជីវកម្ម។ ខេត្តព្រះសីហនុ និងខេត្តសៀមរាបមានការកែលម្អបានប្រសើរបំផុត។ ខេត្តទាំងពីរ មានចំណាត់ថ្នាក់ស្មើរតែក្រោមគេបំផុតក្នុងឆ្នាំ២០០៦ ប៉ុន្តែចាប់តាំងពី

### ការកែលម្អវិស័យមួយនៃអភិបាលកិច្ចខេត្តសៀមរាប

ម្ចាស់ផ្ទះសំណាក់ម្នាក់បាននិយាយថា គាត់បានដឹងអំពីច្បាប់ និងបទបញ្ញត្តិថ្មីៗ ដែលប៉ះពាល់ដល់អាជីវកម្មរបស់គាត់តាមរយៈកាសែតការផ្សព្វផ្សាយ របស់បណ្តាញព័ត៌មាន និងក្រសួងមន្ទីរនានារបស់រដ្ឋាភិបាល គាត់បាននិយាយៈ "មន្ត្រីពន្ធដារខេត្តបានចុះផ្ទាល់ដល់ទីកន្លែងរបស់ខ្ញុំ៤ដងក្នុងមួយឆ្នាំ ដើម្បីផ្តល់ព័ត៌មានអំពីបញ្ហាពន្ធដារ "។ "មន្ត្រីទេសចរណ៍ខេត្តផ្តល់ព័ត៌មានអំពីស្ថានភាពវិស័យទេសចរណ៍ ច្បាប់ និងបទបញ្ញត្តិផ្សេងៗ "។

ពេលនោះមក ខេត្តទាំងពីរបានកែលម្អរហូតដល់ទទួលបានចំណាត់ថ្នាក់ខ្ពស់ និងកណ្តាលរៀងៗខ្លួន។ ខេត្តសៀមរាបបង្ហាញពីការកែលំអសន្ទស្សន៍ស្ទើរតែ ៩ ក្នុងចំណោមសន្ទស្សន៍សរុបទាំង១០។ ខេត្តព្រះសីហនុ ធ្វើការកែលំអមិនបានគ្រប់សន្ទស្សន៍នោះទេ ដោយមានការរីកចម្រើនយ៉ាងខ្លាំងលើសន្ទស្សន៍៥ ប៉ុន្តែសន្ទស្សន៍ដ៏ទៃទៀតមានការធ្លាក់ចុះបន្តិចបន្តួច ហើយខ្លះទៀតមិនមានការផ្លាស់ប្តូរ។ ជាទូទៅការរីកចម្រើនរបស់ខេត្តព្រះសីហនុ មានច្រើនជាងភាពអន់ថយ។ ខេត្តទាំងពីរ បង្ហាញពីការរីកចម្រើនដ៏គួរឱ្យកត់សម្គាល់ក្នុងការទប់ស្កាត់បទឧក្រិដ្ឋ ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម ការការពារកម្មសិទ្ធិលើទ្រព្យសម្បត្តិ និងការលើកកម្ពស់តម្លាភាព។

ជាការប្រសើរ គេគួរពិចារណាអំពីពីការរីកចម្រើនយ៉ាងលឿនលើអភិបាលកិច្ចក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុ ធៀបទៅនឹងការធ្លាក់ចុះនៅរាជធានីនៃប្រទេសកម្ពុជា។ ដូចគ្នានឹងទីក្រុងភ្នំពេញដែរ ខេត្តទាំងពីរនេះមានលក្ខណៈអំណោយផលដែលមានស្រាប់។ ខេត្តសៀមរាបទាក់ទាញអ្នកទេសចរណ៍ជារៀងរាល់ឆ្នាំ ដោយសារតែអច្ឆរិយវត្ថុដ៏អស្ចារ្យនៃប្រាសាទអង្គរវត្ត ចំណែកឯខេត្តព្រះសីហនុវិញ ទទួលបានការវិនិយោគ ដោយសារខេត្តនេះមានកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់ក្នុងប្រទេសកម្ពុជា ជាកន្លែងទេសចរណ៍យ៉ាងមានសក្តានុពល និងអាចមានធនធានប្រេងនៅឯនាយនៃឆ្នេរសមុទ្រ។ ខេត្តទាំងពីរនេះ អាចពឹងផ្អែកលើលក្ខណសម្បត្តិគ្រប់គ្រាន់របស់ខ្លួនយ៉ាងងាយស្រួលក្នុងការទាក់ទាញវិនិយោគជារៀងរាល់ឆ្នាំ ទោះជាមានការកែលម្អលើអភិបាលកិច្ច និងបទបញ្ញត្តិតិចតួចក៏ដោយ។ ប៉ុន្តែក្នុងអំឡុងពេលពីរឆ្នាំកន្លងទៅនេះ ខេត្តទាំងពីរបានវិនិយោគធនធានយ៉ាងច្រើនក្នុងការបង្កើតបទបញ្ញត្តិដែលមានប្រសិទ្ធិភាព និងមានតម្លាភាពច្រើនជាងមុន។ ជាពិសេសខេត្តសៀមរាបគឺជាខេត្តមួយ ក្នុងចំណោមខេត្តតិចតួចនៅក្នុងប្រទេស ដែលមានបែបបទចុះបញ្ជីពាណិជ្ជកម្មដ៏សាមញ្ញនៅកន្លែងទទួលភ្ញៀវរបស់មន្ទីរ ឬអង្គភាពរបស់ខ្លួន។

### ប័ណ្ណកម្មសិទ្ធិដីក្នុងខេត្តបាត់ដំបង

ស្ត្រីជាអាជីវករម្នាក់ បានពិពណ៌នាអំពីបទពិសោធន៍របស់ខ្លួនក្នុងការដាក់ពាក្យសុំធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី។ ជាដំបូង គាត់បានទៅស្នាក់ការ ភូមិ និងសាលាឃុំ ដើម្បីដាក់ពាក្យសុំ ហើយត្រូវបង់ប្រាក់សម្រាប់ការដាក់ពាក្យសុំ និងសម្រាប់ការចុះហត្ថលេខាមួយលើកៗ។ នៅការិយាល័យ ពន្ធដារ គាត់ត្រូវចរចាអំពីថ្លៃបង់ពន្ធ។ ដំបូងមន្ត្រីពន្ធដារចង់ឱ្យគាត់បង់ពន្ធលើដីរបស់គាត់ស្មើនឹង២,៥ដងនៃតម្លៃដីជាក់ស្តែងលើទីផ្សារ។ "ដីរបស់ខ្ញុំ មានតម្លៃ ១០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយម៉ែត្រការ៉េ នៅលើទីផ្សារ ប៉ុន្តែមន្ត្រីរាជរដ្ឋាភិបាល បានដាក់តម្លៃ ២៥ដុល្លាសហរដ្ឋអាមេរិកក្នុងមួយម៉ែត្រការ៉េ។ ខ្ញុំបានស្នើសុំឱ្យមន្ត្រីទាំងនោះ ទិញដីរបស់ខ្ញុំវិញទៅប្រសិនបើមន្ត្រីនោះដឹងច្បាស់អំពីតម្លៃដី។ ខ្ញុំត្រូវចរចាអំពីតម្លៃពន្ធដារ ៣លើក និងបង់ថ្លៃសេវាគ្រប់ប្រភេទ រួមទាំងថ្លៃក្រដាស ថ្លៃទឹកប៊ិក ថ្លៃបិទតែម និងថ្លៃបំពេញពាក្យសុំ។ ខ្ញុំឆ្ងល់ក្នុងចិត្តថាតើមន្ត្រីទាំង នេះទទួលប្រាក់ខែ សម្រាប់ធ្វើកិច្ចការអ្វី។ ចុងក្រោយខ្ញុំបានទៅកាន់មន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់។ ការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីរបស់ខ្ញុំ នឹងចំណាយពេល ២ ទៅ ៣ខែ ហើយចំណាយអស់ ៥ 000 ដុល្លាសហរដ្ឋអាមេរិក សម្រាប់ដីទំហំ ៣0ម៉ែត្រ x ៨0ម៉ែត្រ"។

ខេត្តព្រះសីហនុ លេចធ្លោលើតម្លាភាពក្នុងការផ្ដល់ព័ត៌មានអាជីវកម្មបានយ៉ាងល្អប្រសើរ ។ តាមរយៈទស្សនកិច្ចរបស់ក្រុមអ្នកស្រាវជ្រាវទៅកាន់ខេត្តក្រុងទាំង ២៤ ស្ថាប័នជាច្រើននៅខេត្តព្រះសីហនុ ស្ថិតក្នុងចំណោមក្រុមស្ថាប័នដែលមានបិទផ្សាយព័ត៌មានស្ដីពីបទបញ្ញត្តិច្បាស់លាស់ និងមានផែនទីស្ដីពីគម្រោងហេដ្ឋារចនាសម្ព័ន្ធនាអនាគត ដោយពុំចាំបាច់ធ្វើសំណើសុំ ឬ ការទាក់ទងពិសេសៗ ដើម្បីទទួលបានព័ត៌មានទាំងនោះឡើយ ។

ផ្ទុយទៅវិញ នៅក្នុងខេត្តក្រុងផ្សេងទៀត (ភ្នំពេញ បាត់ដំបង និងបន្ទាយមានជ័យ) មានការអន់ថយក្នុងអំឡុងពេលកន្លងមកនេះ ។ កត្តាចម្បងនៃការធ្លាក់ចុះនេះ បណ្ដាលមកពីខេត្តក្រុងទាំងនេះទទួលបានពិន្ទុទាប លើសន្ទស្សន៍ការទទួលបានដីធ្លី ចំណាយក្រៅផ្លូវការ និងរដ្ឋបាលពន្ធដារ ។

## ៤.៣ ចំណាត់ថ្នាក់ខ្ពស់ ក៏ប៉ុន្តែមិនធានាទទួលបានពិន្ទុល្អឥតខ្ចោះ

ខុសពីប្រទេសផ្សេងទៀត ដែលមានការបង្កើតសន្ទស្សន៍ថ្នាក់ខេត្តឬតំបន់[៩] ពិន្ទុរបស់បណ្ដាខេត្តនានា ក្នុងប្រទេសកម្ពុជាត្រូវដាក់ជាចង្កោម ហើយពិន្ទុសរុបមានប្រកិតៗគ្នា ។ គ្មានខេត្តណាមួយ មានពិន្ទុអភិបាលកិច្ចល្អដាច់ឆ្ងាយជាងខេត្តដទៃឡើយ ។ ដូច្នេះបើខេត្តដែលមានចំណាត់ថ្នាក់ទាបគេ អាចបង្កើនពិន្ទុខ្ពស់របស់ខ្លួនបានយ៉ាងឆាប់រហ័ស នៅពេលធ្វើអង្កេតលើកក្រោយ ដោយគ្រាន់តែធ្វើការកែទំរង់ដ៏តិចតួច ។ សូម្បីតែខេត្តដែលមានចំណាត់ថ្នាក់ខ្ពស់បំផុត ដូចជា ខេត្តកំពង់ចាម និងខេត្តកំពត ក៏នៅមានចំណុចជាច្រើនដែលត្រូវកែលម្អដែរ ។ ចំណុចទាំងនេះមានបង្ហាញយ៉ាងច្បាស់

រូបទី៨ : ពិន្ទុលើសន្ទស្សន៍នីមួយៗ




[៩] សន្ទស្សន៍នៃភាពប្រកួតប្រជែងរបស់ខេត្តនានានៃប្រទេសវៀតណាម សន្ទស្សន៍អភិបាលកិច្ចសេដ្ឋកិច្ចនៃប្រទេសស្រីលង្កា និង សន្ទស្សន៍ស្រដៀងគ្នានេះ ក្នុងប្រទេសឥណ្ឌូនេស៊ី ឬភីលីពីន សំរាប់ព័ត៌មានបន្ថែមសូមមើល http://www.youtube.com/watch?v=7UPgfRTtkm0

**រូបទី៩ : ទំនាក់ទំនងរវាងអភិបាលកិច្ច និងការពង្រីកអាជីវកម្ម**




ក្នុងរូបទី៨ ដោយកាំនីមួយៗនៃក្រាហ្វិកនោះតំណាងឱ្យពិន្ទុលើសន្ទស្សន៍នីមួយៗ។ ការប៉ាន់ស្មានពីភាពល្អឥតខ្ចោះរបស់ខេត្តដែលទទួលបានពិន្ទុ ១០ លើសន្ទស្សន៍នីមួយៗមានបង្ហាញនៅជ្រុងខាងឆ្វេងផ្នែកខាងលើនៃរូបទី៨។ គំនូសតាងផ្សេងទៀត ក្រៅពីគំនូសពិន្ទុល្អឥតខ្ចោះគឺជាគំនូសតំណាងឱ្យខេត្តនីមួយៗ ដោយយោងតាមពិន្ទុរបស់ PBES។ ការសំខាន់គឺត្រូវចាំថា គ្មានខេត្តណាមួយមានពិន្ទុក្បែរពិន្ទុល្អឥតខ្ចោះឡើយ។

### បទឧក្រិដ្ឋក្នុងខេត្តកំពង់ចាម

ម្ចាស់សិប្បកម្មទ្វារ និងបង្អួចដែកតូចមួយ បានមានប្រសាសន៍ថា ប្រជាពលរដ្ឋមិនរាយការណ៍ការប្លន់ប្រដាប់អាវុធនិងការលួចគាស់ផ្ទះ មិនត្រូវបានរាយការណ៍ ទៅកាន់អាជ្ញាធរមានសមត្ថកិច្ចឡើយ ដោយសារកង្វះទំនុកចិត្ត : "ជនរងគ្រោះមិនបានរាយការណ៍អំពីបទឧក្រិដ្ឋនានាទៅអាជ្ញាធរមានសមត្ថកិច្ចឡើយ ពីព្រោះអ្នកទាំងនោះ ពុំមានការជឿជាក់ថា អាជ្ញាធរអាចដោះស្រាយករណីទាំងនេះបាន និងប្រគល់ជូនជនរងគ្រោះវិញនូវអ្វី ដែលចោរបានលួចទៅនោះឡើយ... ប្រជាជន ជាពិសេសម្ចាស់អាជីវកម្ម បានព្យាយាមការពារទ្រព្យសម្បត្តិ ដោយខ្លួនឯង..."។

លើសពីនោះទៀត ការពិតបង្ហាញថានៅមានចំណុចខ្វះខាតយ៉ាងច្រើន សូម្បីតែក្នុងខេត្តដែលមានចំណាត់ថ្នាក់ខ្ពស់បំផុតក៏ដោយ។ ឧទាហរណ៍ ចំណាយក្រៅផ្លូវការ និងរដ្ឋបាលពន្ធដារ នៅតែជាឧបសគ្គដល់ម្ចាស់អាជីវកម្មក្នុងខេត្តកំពង់ចាម។ ស្រដៀងគ្នានេះដែរ មន្ត្រីខេត្តកំពតមានកិច្ចការជាច្រើនដែលត្រូវបំពេញ ដើម្បីលើកកម្ពស់តម្លាភាព និងកិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន។ ផ្ទុយទៅវិញ ខេត្តនានាដែលមានចំណាត់ថ្នាក់ទាបបែរជាទទួលបានជោគជ័យលើផ្នែកដោយឡែកៗមួយចំនួន។ គោលនយោបាយរបស់ខេត្តទាំងនោះក្នុងការឈានទៅទទួលពិន្ទុគួរតែលើកយកមកសិក្សា និងយកគំរូតាម។ ឧទាហរណ៍

ខេត្តកណ្តាល (ចំណាត់ថ្នាក់ទី១៦) ទទួលបានចំណាត់ខ្ពស់ក្នុងចំណោមខេត្តមានពិន្ទុខ្ពស់ផ្សេងទៀតលើសន្ទស្សន៍កម្មសិទ្ធិលើទ្រព្យសម្បត្តិ និងពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ។

## ៤.៤ ឥទ្ធិពលនៃការកែលម្អអភិបាលកិច្ច

តាមរយៈការកែលម្អអភិបាលកិច្ចលើវិស័យនានាដែលបានពិន្ទុទាបបំផុត មន្ត្រីថ្នាក់ខេត្ត អាចជួយឱ្យ MSMEs រីកចម្រើន។ នៅពេលដែលការចំណាយលើការអនុវត្តតាមបទបញ្ញត្តិមានការថយចុះ សហគ្រិនអាចហ៊ានប្រថុយប្រើប្រាស់ប្រាក់ទុន និងចំណាយកម្លាំងកាយចិត្តជាច្រើនរបស់ខ្លួនដើម្បីពង្រីកអាជីវកម្ម។ កំណើន១០ពិន្ទុផ្នែកអភិបាលកិច្ចនៃ PBES ដែលស្មើនឹង គម្លាតនៃពិន្ទុរបស់ខេត្តក្រចេះ និងកំពង់ចាម នាំឱ្យមានកំណើនឱកាសនៃការពង្រីកអាជីវកម្មរបស់សហគ្រិនរហូតដល់ ៩.៩ ភាគរយ។ ទំនាក់ទំនងនេះ មានបង្ហាញយ៉ាងច្បាស់ដោយបន្ទាត់ខ្សែវក្នុងរូបទី៩។

តារាងទី៣ បង្ហាញថា សន្ទស្សន៍៥ មានសារៈសំខាន់ជាចម្បងសម្រាប់ឱ្យខេត្តនីមួយៗធ្វើការពិចារណាកែលម្អដើម្បីលើកទឹកចិត្តសហគ្រិនឱ្យពង្រីកអាជីវកម្មរបស់ខ្លួនៈ ចំណាយក្រៅផ្លូវការ ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម ការទប់ស្កាត់បទឧក្រិដ្ឋ និងរដ្ឋបាលពន្ធដារ។ឧទាហរណ៍កំណើនមួយពិន្ទុលើសន្ទស្សន៍ចំណាយក្រៅផ្លូវការ នាំឱ្យមានកំណើនឱកាសពង្រីកអាជីវកម្ម៣.៣ភាគរយ។ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ នីតិវិធីចាប់ផ្តើមអាជីវកម្ម ការទប់ស្កាត់បទឧក្រិដ្ឋ និងពន្ធដារ ក៏នាំឱ្យមានការពង្រីកអាជីវកម្ម ប្រហាក់ប្រហែលគ្នា។ សន្ទស្សន៍ដទៃទៀតពុំសូវមានឥទ្ធិពលខ្លាំងទៅលើការពង្រីកអាជីវកម្មទេ។

**តារាងទី ៣ : ឥទ្ធិពលនៃសន្ទស្សន៍នីមួយៗ នៅលើឱកាសដែលអាជីវករអាចពង្រីកសកម្មភាពអាជីវកម្មរបស់ខ្លួន**

| សន្ទស្សន៍ | ឱកាសបន្ថែមក្នុងការពង្រីកអាជីវកម្ម (ផ្អែកលើកំណើន១ពិន្ទុ តាមសន្ទស្សន៍) | ឥទ្ធិពល |
|---|---|---|
| ចំណាយក្រៅផ្លូវការ | ៣.៥ %* | ខ្ពស់ |
| ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ | ៣.៣ %* | ខ្ពស់ |
| នីតិវិធីចាប់ផ្តើមអាជីវកម្ម | ៣.១%* | ខ្ពស់ |
| ការទប់ស្កាត់បទឧក្រិដ្ឋ | ២.៧%* | មធ្យម |
| ពន្ធដារ | ២.២ %* | មធ្យម |
| ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ | ០.៤ % | ទាប |
| កម្មសិទ្ធិលើទ្រព្យសម្បត្តិ | ០.២ % | ទាប |
| ការចូលរួម | ០.០ % | ទាបខ្លាំង |
| តម្លាភាព | -១.០ % | ទាបខ្លាំង |
| ការដោះស្រាយជម្លោះ | -១.៨ | ទាបខ្លាំង |

សញ្ញា * បង្ហាញថា មេគុណអាចប្រែប្រួលក្នុងកម្រិត ០.១ ឬទាបជាង ០.១។

ការសម្រេចចិត្តលើគោលនយោបាយ តែងតែពាក់ព័ន្ធដល់ការចំណេញ និងការលះបង់។ ជាទូទៅ ការចំណាយពេលវេលា កម្លាំង និងធនធានហិរញ្ញវត្ថុ ទៅលើគោលដៅគោលនយោបាយណាមួយ នាំឱ្យមានការខកខានមិនបានផ្តោតទៅលើកិច្ចការផ្សេងៗទៀត។ ការយល់ដឹងអំពីជម្រើសគោលនយោបាយនានាដែលជួយជំរុញដល់សកម្មភាពពង្រីកអាជីវកម្មបានខ្លាំងបំផុតនោះ អាចជាកត្តាសំខាន់ ដើម្បីជួយបំពេញជម្រើសនៃគំនិតផ្តួចផ្តើម ដែលមន្ត្រីថ្នាក់ខេត្តត្រូវពិចារណា។ តារាងទី៣ គួរតែជាវិធានមួយដ៏សំខាន់សម្រាប់ឱ្យអាជ្ញាធរខេត្តប្រើប្រាស់ក្នុងការជ្រើសជ្រើសរើសគោលនយោបាយសំខាន់ៗមកអនុវត្ត។

.

## ៤.៥ គោលនយោបាយនីមួយៗ

តារាង ក២ មានបង្ហាញព័ត៌មានលម្អិតអំពីសន្ទស្សន៍ និងសូចនាករខុសៗគ្នាដែលត្រូវបូកបញ្ចូលគ្នា ដើម្បីទទួលបានពិន្ទុសរុប។ ខាងក្រោមនេះ ជាផ្នែកសំខាន់មួយចំនួនបានពីសូចនាកររបស់ PBES។

### ៤.៥.១ ភាពប្រសើរឡើងនៃបរិយាកាសអាជីវកម្មជារួម

*ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម :* ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម : ជាទូទៅ ចំណាយដើម្បីចាប់ផ្តើមអាជីវកម្មមានភាពប្រសើរឡើងនៅទូទាំងប្រទេស។ ក្រៅពីខេត្តដែលមានការិយាល័យ "ច្រកចេញចូលតែមួយ" សម្រាប់នីតិវិធីចុះបញ្ជីចាប់តាំងពីការវាយតម្លៃរបស់ PBES លើកមុន យើងអាចដឹងដែរថា ចំនួនឯកសារសរុបសម្រាប់រៀបចំចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់បានថយចុះ (ពី៥ ទៅ ៤ ឯកសារ)។ ចំនួនថ្ងៃសរុបសម្រាប់ការសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មនៅមន្ទីរពាណិជ្ជកម្មខេត្ត ក៏បានថយចុះផងដែរ (ពី២០ ទៅ ១៦,៧៥ ថ្ងៃ) ហើយពេលវេលាចាំបាច់ក្នុងការបង់ពន្ធប៉ាតង់សម្រាប់អាជីវកម្មខ្នាតតូច ក៏ថយចុះគួរឱ្យកត់សម្គាល់ផងដែរ (ពី១៥ ទៅ ១២,២៥ថ្ងៃ)។ ប៉ុន្តែមានករណីលើកលែងមួយគឺ អាជីវករត្រូវចំណាយពេលរង់ចាំយូរជាងមុនដើម្បីទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មរយៈពេល១ឆ្នាំ។ ចំណាយសម្រាប់ឯកសារធ្វើអាជីវកម្ម ក៏កើនឡើងផងដែរ ប៉ុន្តែការកើនឡើងទាំងនេះមានកម្រិតទាបជាខ្លាំង បើធៀបនឹងអត្រាអតិផរណា ក្នុងរយៈពេលដូចគ្នានេះ។ [១០]

*ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ:* បទបញ្ញត្តិមួយចំនួន បង្ហាញអំពីសញ្ញានៃភាពងាយស្រួល។ ទោះបីជាក្រុមហ៊ុនបានរាយការណ៍ពីការចំណាយរបស់ខ្លួនកាន់តែច្រើនទៅលើនីតិវិធីការិយាធិបតេយ្យក៏ដោយ មេដ្យាន [១១] នៃការធ្វើអធិការកិច្ចលើអាជីវកម្មបានថយចុះ (ពី ៤ មកនៅត្រឹម ២ដង ក្នុង១ឆ្នាំ) ហើយរយៈពេលរង់ចាំដើម្បីបានប័ណ្ណកម្មសិទ្ធិលើដីធ្លី សម្រាប់អាជីវកម្មកំពុងដំណើរការបានកាត់បន្ថយចំនួនពាក់កណ្តាល ពោលគឺ ពី៦០ថ្ងៃមកត្រឹម៣០ថ្ងៃប៉ុណ្ណោះ។

*រដ្ឋបាលពន្ធដារ :* រដ្ឋបាលពន្ធដារ ក៏មានការរីកចម្រើនមួយចំនួនផងដែរ។ មានអាជីវកម្មតិចជាងមុន បានចរចាអំពីការបង់ពន្ធរបស់ខ្លួនជាមួយនឹងអាជ្ញាធរមូលដ្ឋាន (ជាមធ្យម ៦៤ភាគរយនៅឆ្នាំ២០០៦ មកត្រឹម៥៤ភាគរយនៅឆ្នាំ២០០៩) ហើយ ជាលទ្ធផលមានម្ចាស់អាជីវកម្មកាន់តែតិចដែលមានការមិនពេញចិត្តចំពោះបញ្ហាផ្តល់សំណូកដើម្បីបន្ថយបន្ទុកពន្ធ (ពី៨០ភាគរយ មកនៅត្រឹម៧៥ភាគរយ)។ តាមពិតរដ្ឋបាលពន្ធដារទាំងនេះ មានការរីកចម្រើនតិចតួចប៉ុណ្ណោះ។ អាជីវកម្ម ៧៥ភាគរយ នៅតែគិតថា ការផ្តល់សំណូកទៅឱ្យអាជ្ញាធរពន្ធដារ គឺជាឧបសគ្គដល់ការធ្វើអាជីវកម្មរបស់ខ្លួន

---

១០ ចំណាយលើឯកសារធ្វើអាជីវកម្ម រួមបញ្ចូលថ្លៃចំណាយផ្លូវការ និងមិនផ្លូវការដែល អាជីវករបានបង់ ដើម្បីទទួលបានឯកសារផ្លូវការដើម្បីចាប់ផ្តើមអាជីវកម្ម

១១ មេដ្យានគឺជាតម្លៃកណ្តាលនៃរបាយតួលេខ

ហើយនេះជាភាគរយដ៏ខ្ពស់ ។ លើសពីនេះទៀត អាជីវកម្មកាន់តែច្រើន បានបង្ហាញនូវការមិនពេញចិត្តចំពោះអត្រាបង់ពន្ធ និងរដ្ឋបាលពន្ធដារបើគិតតាមស្តង់ដារអន្តរជាតិ ។ ទាំងនេះបង្ហាញថា គេត្រូវធ្វើកិច្ចការជាច្រើនទៀតដើម្បីបង្កើតប្រព័ន្ធពន្ធត្រឹមត្រូវ និងប្រកបដោយសមធម៌ ដែលតម្រូវឱ្យអាជីវកម្មបង់ពន្ធសមស្រប សម្រាប់ទ្រទ្រង់និងលើកកម្ពស់សេវាសាធារណៈរបស់រដ្ឋាភិបាល ។ ប៉ុន្តែការណ៍នេះមិនរាំងស្ទះ នឹងបង្កឱ្យមានឧបសគ្គដល់ការប្រកបអាជីវកម្មនោះទេ ។ គួរកត់សម្គាល់ថា អាជីវកម្មដែលមិនបង់ពន្ធទាល់តែសោះ មានចំនួនកើនឡើងជិតទ្វេរដងក្នុងរយៈពេល ២ឆ្នាំកន្លងទៅនេះ ។ នេះអាចជាការឆ្លុះបញ្ចាំងឱ្យឃើញពីភាពថ្មីថ្មោង និងដំណើរការមិនផ្លូវការនៃអាជីវកម្មថ្មីៗ ប៉ុន្តែក៏ជាផ្នែកមួយនៃការឆ្លុះបញ្ចាំងពីប្រតិកម្មរបស់អាជីវកម្មទាំងនោះចំពោះប្រព័ន្ធពន្ធដារ ដែលម្ចាស់អាជីវកម្មជាច្រើនជឿជាក់ថាជាប្រព័ន្ធមិនត្រឹមត្រូវ ។ ការណ៍នេះនាំមកនូវផលវិបាកអវិជ្ជមានចំពោះរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ខេត្ត ពីព្រោះវាអាចធ្វើឱ្យបាត់បង់ចំណូលសំខាន់ សម្រាប់យកមកប្រើដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ ។

### ៤.៥.២ ការអន់ថយក្នុងវិស័យសំខាន់ៗ

PBES ឆ្នាំ២០០៩ ក៏រកឃើញការអន់ថយមួយចំនួននៃបរិយាកាសអាជីវកម្មផងដែរ ។ សូចនាករមួយចំនួនក្នុងចំណោមសូចនាករទាំងនេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ហើយអាចទាក់ទាញចំណាប់អារម្មណ៍របស់មន្ត្រីមូលដ្ឋានថ្នាក់ខេត្ត ស្រុក និង ថ្នាក់ជាតិបានភ្លាមៗ ។

*អាជីវកម្មផ្លូវការ:* អ្វីដែលគួរឱ្យកត់សម្គាល់ខ្លាំងបំផុត គឺការកើនឡើងនូវភាគរយនៃការធ្វើអាជីវកម្មក្រៅផ្លូវការ ដូចមានបង្ហាញក្នុងតារាងទី៤ ។នៅឆ្នាំ២០០៦ អ្នកផ្តល់ចម្លើយរបស់ PBES ៣ ភាគរយ បានចុះបញ្ជីថ្នាក់ជាតិជាផ្លូវការនៅក្រសួងពាណិជ្ជកម្ម ហើយអាជីវកម្ម ៣៨ ភាគរយផ្សេងទៀតបានសុំលិខិតអនុញ្ញាតបើកអាជីវកម្ម នៅមន្ទីរពាណិជ្ជកម្មខេត្តឬក្រុង ។ អាជីវកម្មផ្សេងទៀតភាគច្រើន ទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មរយៈពេល ១ឆ្នាំ ពីក្រសួងពាក់ព័ន្ធ ឬបានបង់ពន្ធធម្មតាទៅអាជ្ញាធរពន្ធដារមូលដ្ឋាន (ហៅថាពន្ធប៉ាតង់) ។ មានក្រុមហ៊ុនតែ ១៦ភាគរយប៉ុណ្ណោះ ដែលគ្មានឯកសារអ្វីទាំងអស់ ។ ស្រដៀងគ្នានេះដែរ អាជីវកម្មចំនួន ១១ភាគរយ បង់ពន្ធតាមរបបពិត ដូច្នេះអាជីវកម្មទាំងនោះត្រូវបង់ពន្ធលើចំណូលអាជីវកម្មសរុប ។

នៅឆ្នាំ២០០៩ មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា ការចុះបញ្ជីពាណិជ្ជកម្មបានធ្លាក់ចុះយ៉ាងច្រើន ។ ថ្វីបើចំនួនអាជីវកម្មដែលបានចុះបញ្ជីនៅថ្នាក់ជាតិ បានកើនឡើងដល់ ១៤.៤ ភាគរយក៏ដោយ ក៏ចំនួនអាជីវកម្មដែលបានបំពេញនីតិវិធីចុះបញ្ជីពាណិជ្ជកម្មនៅថ្នាក់ខេត្ត ថយចុះមកត្រឹម ១៣.៣ ភាគរយ នៅខេត្តទាំង ១០ ដែលបានជ្រើសរើសសំរាប់ PBES លើកមុន ។ នាពេលបច្ចុប្បន្ននេះ ការធ្វើអាជីវកម្មជាង ៤០ភាគរយ មិនមានឯកសារអាជីវកម្មអ្វីទាំងអស់ ។ ស្រដៀងគ្នានេះដែរ អាជីវកម្មតែ ៤.៣ ភាគរយប៉ុណ្ណោះ កំពុងបង់ពន្ធតាមរបបពិត ។

ទំហំអាជីវកម្ម មានសារៈសំខាន់ណាស់ព្រោះវាពាក់ព័ន្ធនឹងភាពផ្លូវការរបស់អាជីវកម្ម ។ ៥០ភាគរយ នៃអ្នកផ្តល់ចម្លើយដែលមានទុនវិនិយោគលើសពី ១០០ ០០០ ដុល្លាសហរដ្ឋអាមេរិក ចុះបញ្ជីអាជីវកម្មនៅថ្នាក់ជាតិ ឬថ្នាក់ខេត្ត ។ អាជីវកម្មដែលចុះបញ្ជីបែបនេះមាន ចំនួន ២៥ ភាគរយ ដែលមានទុនវិនិយោគតិចជាង ១០០ ០០០ ដុល្លាសហរដ្ឋអាមេរិក ។ ទោះបីជាយ៉ាងនេះក៏ដោយ ទាំងនេះមិនអាចពន្យល់អំពីការថយចុះនៅឆ្នាំ២០០៩ បានឡើយ ដូចក្នុងតារាងទី១ បង្ហាញថា អាជីវកម្មធំៗក្នុង PBES ឆ្នាំ២០០៩ មានចំនួន ច្រើនជាង PBES ឆ្នាំ២០០៦ ។

## តារាងទី៤ ៖ កម្រិតនៃការចុះបញ្ជីពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា

| កម្រិត | ការអធិប្បាយ | ឯកសារគន្លឹះដែលត្រូវការ | តំណាងសំណាកសហគ្រាស PBES | | |
|---|---|---|---|---|---|
| | | | ឆ្នាំ២០០៩ គ្រប់ខេត្ត | ឆ្នាំ២០០៩ ខេត្តទាំង១០ ដែលបានជ្រើសរើសក្នុងការអង្កេតលើកមុន | ឆ្នាំ២០០៦ គ្រប់ខេត្ត |
| 1 | ផ្លូវការទាំងស្រុង-ថ្នាក់ជាតិ | ការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម | ១៣,៣% | ១៤,៤% | ៣,0% |
| | | អាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មរយៈពេល ៣ឆ្នាំចេញដោយក្រសួងពាក់ព័ន្ធ † | | | |
| | | ការចុះបញ្ជីពន្ធប៉ាតង់ នៅអាជ្ញាធរពន្ធដារ ថ្នាក់ជាតិ ᴪ | | | |
| | | មានលេខសម្គាល់អត្តសញ្ញាណពន្ធលើតម្លៃបន្ថែម (VAT) ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | | |
| | | បង់ពន្ធលើប្រាក់ចំណេញទៅតាមរបបពន្ធពិត | | | |
| | | លិខិតអនុញ្ញាតការងារ ដែលបញ្ជាក់ពីការ ឯកភាពលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនសម្រាប់សហគ្រាសដែលមាននិយោជិតលើសពី ៨នាក់ | | | |
| | | លិខិតអនុញ្ញាតការងារ ដែលបញ្ជាក់ពីការ ឯកភាពលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនសម្រាប់សហគ្រាសដែលមាននិយោជិតលើសពី ៨នាក់ | | | |
| | | អាជ្ញាប័ណ្ណផ្សេងទៀត ទៅតាមករណីសមស្រប‡ | | | |
| 2 | ផ្លូវការទាំងស្រុង-ថ្នាក់ខេត្ត | អាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មចេញដោយមន្ទីរពាណិជ្ជកម្មខេត្តក្រុង* | ១៣,៩% | ១៣,៣% | ៣៨,0% |
| | | អាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មរយៈពេលមួយឆ្នាំ ចេញដោយ មន្ទីរនៅថ្នាក់ខេត្ត† | | | |
| | | ការចុះបញ្ជីពន្ធប៉ាតង់ជាមួយអាជ្ញាធរពន្ធដារខេត្តក្រុង ᴪ | | | |
| | | បង់ពន្ធតាមការប៉ាន់ប្រមាណ ប្រសិនបើប្រាក់ចំណេញប្រចាំឆ្នាំ តិចជាង ១.៥00 ដុល្លាសហរដ្ឋអាមេរិក | | | |
| | | អាជ្ញាប័ណ្ណផ្សេងទៀត រួមទាំង លិខិត អនុញ្ញាតការងារ និងវិញ្ញាបនបត្របរិស្ថាន ទៅតាមករណីសមស្រប‡ | | | |
| 3 | មិនចុះបញ្ជីស្របច្បាប់តែមានអាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្ម | អាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មរយៈពេលមួយឆ្នាំ ចេញដោយ មន្ទីរនៅថ្នាក់ខេត† | ១៣,៥% | ១២,៤% | ២១,0% |
| | | ការចុះបញ្ជីពន្ធប៉ាតង់ ដោយអាជ្ញាធរពន្ធដារ ខេត្តក្រុង ᴪ | | | |
| | | អាជ្ញាប័ណ្ណផ្សេងទៀត រួមទាំង លិខិតអនុញ្ញាតការងារ និងវិញ្ញាបនបត្របរិស្ថាន ទៅតាមករណីសមស្រប‡ | | | |
| 4 | ពន្ធប៉ាតង់ | ការចុះបញ្ជីពន្ធប៉ាតង់ ដោយអាជ្ញាធរពន្ធដារ ខេត្តក្រុង ᴪ | ២៣,៧% | ១៩,៦% | ២២,0% |
| 5 | មិនផ្លូវការទាំង ស្រុង | គ្មានឯកសារផ្លូវការទេ | ៣៩,៧% | ៤0,៣% | ១៦,0% |

ឆ្នាំ២០០៩ គ្រប់ខេត្ត ៖ ការជ្រើសរើសសំណាកសហគ្រាស PBES ដោយចៃដន្យតាមប្រភេទសហគ្រាស ដើម្បីឆ្លុះបញ្ចាំងពីចំនួនសហគ្រាសក្នុងបណ្ដាខេត្តក្រុងទាំង ២៤។
ឆ្នាំ២០០៩ ខេត្តទាំង១០ ដែលបានជ្រើសរើសសំណាកសហគ្រាសពីការអង្កេតលើកមុន ៖ ការវិភាគធ្វើឡើងចំពោះតែខេត្តទាំង១០ ដែលបានសិក្សាកាលពីឆ្នាំ២០០៦។

ឆ្នាំ២០០៦ គ្រប់ខេត្ត ៖ សំណាកសហគ្រាស PBES ឆ្នាំ២០០៦ ដែលចូលរួមដោយខេត្តចំនួនតែ ១០ ប៉ុណ្ណោះ។

+អាជ្ញាប័ណ្ណទូទៅបំផុតមាន៤ គឺ ១. អាជ្ញាប័ណ្ណដំណើរការរោងចក្រសម្រាប់សហគ្រាសឧស្សាហកម្មចេញដោយនាយកដ្ឋានឧស្សាហកម្មធុនធ្ងន់ នៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ២. អាជ្ញាប័ណ្ណដំណើរការសិប្បកម្មចេញដោយនាយកដ្ឋានសិប្បកម្ម និងឧស្សាហកម្មធុនស្រាលនៃក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល ៣. អាជ្ញាប័ណ្ណដំណើរការវិស័យសេវាកម្មចេញដោយក្រសួងទេសចរណ៍ ៤. អាជ្ញាប័ណ្ណធ្វើកសិកម្ម ព្រៃឈើ និងជលផល ចេញដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

≠ឯកសារទាំងនេះ រួមមាន លិខិតអនុញ្ញាតការសាងសង់ ចេញដោយក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ លិខិតអនុញ្ញាតសាងសង់ផ្លូវថ្នល់ ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន លិខិតអនុញ្ញាតផ្នែកប្រព័ន្ធអនាម័យ ចេញដោយក្រសួងសុខាភិបាល និងអាជ្ញាប័ណ្ណ នីហរ័ណ-អាហរ័ណ ចេញដោយអាជ្ញាធរគយ។

ᴪ ពន្ធប៉ាតង់ គឺជាការចុះបញ្ជីប្រចាំឆ្នាំ (ឬអាជ្ញាប័ណ្ណ) ដែលត្រូវបង់កម្រៃសម្រាប់គ្រប់អាជីវកម្ម ឧស្សាហកម្ម និងជំនាញឯកទេស លើកលែងតែកសិករ។ ពន្ធនេះផ្អែកលើប្រាក់ចំណូលកាលពីឆ្នាំមុន។ អាជីវកម្មថ្មីត្រូវចុះបញ្ជីជាមួយអាជ្ញាធរពន្ធដារ នៅក្នុងរយៈពេល ១៥ថ្ងៃ ក្រោយចាប់ផ្ដើម សកម្មភាពសេដ្ឋកិច្ច (ច្បាប់ពន្ធដារ ឆ្នាំ១៩៩៩)។ ពន្ធប៉ាតង់លើកដំបូងត្រូវបានប៉ាន់ប្រមាណអាស្រ័យទៅតាមដំណើរការរបស់សហគ្រាស ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ក្រុមហ៊ុនណាដែលគ្មានបំណងនាំចេញ អាចចុះឈ្មោះនៅមន្ទីរពាណិជ្ជកម្មខេត្តក្រុង (យោងតាមប្រកាសលេខ ៧៨ របស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០២)។

* ក្រុមហ៊ុនដែលគ្មានបំណងធ្វើការនាំចេញ និងពុំមានលក្ខណៈសមស្របក្នុងការបង់ពន្ធលើប្រាក់ចំណេញទៅតាម "របបពិត" ដោយសារមានប្រាក់ចំណេញប្រចាំឆ្នាំទាបជាង ១ ៥00ដុល្លាអាមេរិក (មាត្រា ១២ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និងការចុះបញ្ជីការ) អាចធ្វើការចុះបញ្ជីនៅ ឯមន្ទីរពាណិជ្ជកម្មខេត្តក្រុង ដោយអនុលោមតាមប្រកាសលេខ ៧៨ របស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០២ ប៉ុន្តែក្រុមហ៊ុនទាំងនេះពុំត្រូវបានចាត់ទុកជានីតិបុគ្គលនោះឡើយ។ ក្រុមហ៊ុនដែលគ្មានបំណងចង់នាំចេញ អាចចុះឈ្មោះនៅមន្ទីរពាណិជ្ជកម្មខេត្តក្រុង (យោងតាមប្រកាស លេខ៧៨ របស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០០២)។

ភាគច្រើន ការថយចុះនៃការិតផ្លូវការ បណ្តាលមកពីភាពក្មេងខ្ចីរបស់អាជីវកម្មថ្មី។ អាជីវកម្មចំនួន ៤២ ភាគរយទើបបានចាប់ផ្តើមឡើងនៅឆ្នាំ ២០០៦។ អាជីវកម្មថ្មីៗទាំងនោះជាសូចនាករនៃកំណើនសេដ្ឋកិច្ចនាពេលកន្លងទៅថ្មីៗនៅកម្ពុជា ហើយពួកគេអាចនឹងគ្មានពេលវេលាដើម្បីបំពេញតាមនីតិវិធីដើម្បីឱ្យមានលក្ខណៈផ្លូវការនៅឡើយទេ។ ក្នុងចំណោមអាជីវកម្មគ្រប់ប្រភេទ ដែលបានបង្កើតឡើងតាំងពី ឆ្នាំ២០០៦ មក មានអាជីវកម្មតែ ១៧,៣ភាគរយ ប៉ុណ្ណោះដែលមានលក្ខណៈផ្លូវការពេញលេញ (៨,៩ ភាគរយនៅថ្នាក់ជាតិ និង ៨,៤ភាគរយនៅថ្នាក់ខេត្ត)។ ជាការពិតណាស់នៅពេលយើងផ្តោតការយកចិត្តទុកដាក់លើពាណិជ្ជកម្ម ដែលបានជ្រើសរើសសម្រាប់ការអង្កេតនេះ (អាជីវកម្មដែលបានយល់ព្រមចូលរួម ក្នុងការអង្កេតទាំងនៅឆ្នាំ២០០៦ និង ឆ្នាំ ២០០៩) យើងអាចមើលឃើញថា អាជីវកម្មដែលកំពុងតែដំណើរការ កាន់តែមានលក្ខណៈផ្លូវការច្រើនជាងក្នុងរយៈកន្លងទៅ។ នាពេលបច្ចុប្បន្ននេះ ២៦ ភាគរយនៃអាជីវកម្មដែលបានជ្រើសរើសមកសិក្សា បានចុះបញ្ជីនៅថ្នាក់ជាតិ។

ទោះបីជាអាយុកាលរបស់អាជីវកម្មជាកត្តាកំណត់ចម្បងលើភាពផ្លូវការក៏ដោយ ក៏ការផ្តោតយកចិត្តទុកដាក់លើសូចនាករនេះ គួរធ្វើឡើងពីរយៈពេលមួយ ទៅរយៈពេលមួយទៀត ដើម្បីបញ្ជាក់ថាតើកត្តាផ្សេងៗអាចមានតួនាទីក្នុងការធ្វើឱ្យអាជីវកម្មបន្តធ្វើសកម្មភាពផ្លូវការដែរ ឬយ៉ាងណា។

*ចំណាយក្រៅផ្លូវការ:* សន្ទស្សន៍ចំណាយក្រៅផ្លូវការក៏បានបង្កឧបសគ្គបន្ថែមដល់អាជីវកម្មបន្តិចបន្តួចដែរ។ នៅឆ្នាំ២០០៩ មានអាជីវកម្មតែ ៥២ ភាគរយប៉ុណ្ណោះ ដែលបដិសេធមិនផ្តល់សំណូកដល់មន្ត្រីមូលដ្ឋាន ដែលចំនួននេះកាលពីឆ្នាំ ២០០៦ មានដល់ទៅ ៥៦ ភាគរយ។ លើសពីនោះទៀត អាជីវកម្មដែលបានរាយការណ៍ថា អំពើពុករលួយជាឧបសគ្គដល់អាជីវកម្មរបស់ខ្លួន បានកើនឡើងចំនួន ៨ភាគរយ (នាពេលបច្ចុប្បន្ននេះ ចំនួននេះកើនឡើងដល់ ៤២ភាគរយ ក្នុងខេត្តដែលទទួលបានពិន្ទុកណ្តាល)។ អ្វីដែលគួរឱ្យកត់សម្គាល់បំផុតនោះ អាជីវកម្មចំនួន ៣១ ភាគរយរាយការណ៍ថា ប្រសិនបើខ្លួនផ្តល់សំណូកដល់ស្ថាប័នណាមួយនោះ ស្ថាប័នផ្សេងទៀតអាចនឹងមកពិនិត្យមើលអាជីវកម្មរបស់ខ្លួន ហើយស្នើឱ្យខ្លួនផ្តល់សំណូកដល់ពួកគេជាមិនខាន។ នៅឆ្នាំ២០០៦ មានអាជីវកម្មតែ ១៧ ភាគរយ ប៉ុណ្ណោះក្នុងខេត្តដែលបានពិន្ទុកណ្តាលលើសន្ទស្សន៍ចំណាយក្រៅផ្លូវការបានរាយការណ៍ថា ការផ្តល់សំណូកនេះមានផលប៉ះពាល់ជាច្រើនដល់ការធ្វើអាជីវកម្ម។ ទោះជាបីជាលទ្ធកម្មសាធារណៈមានការរីកចម្រើនតែបន្តិចបន្តួចក្តី ក៏ទាមទារឱ្យមានការកែលម្អជាច្រើនបន្ថែមទៀតដែរ។ អាជីវកម្មត្រឹមតែ ១៩ភាគរយតាមខេត្តដែលទទួលពិន្ទុកណ្តាលលើសន្ទស្សន៍ចំណាយក្រៅផ្លូវការ មានការជឿជាក់ថា ព័ត៌មានស្តីពីកិច្ចសន្យាលទ្ធកម្មសាធារណៈមានលក្ខណៈគ្រប់គ្រាន់ និងប្រកបដោយតម្លាភាព រីឯអាជីវកម្ម៦២ភាគរយជឿជាក់ថាទំនាក់ទំនងបុគ្គលជាភាពចាំបាច់ក្នុងការទទួលបានការដេញថ្លៃ។ លើសពីនោះទៀត អាជីវកម្មចំនួន ៧៥ ភាគរយជឿជាក់ថា "ការផ្តល់ប្រាក់សគុណមិនស្របច្បាប់" គឺជាតម្រូវការចាំបាច់ជាប្រចាំដើម្បីដេញថ្លៃឈ្នះកិច្ចសន្យាលទ្ធកម្មពីរដ្ឋាភិបាល។

*តម្លាភាព:* តម្លាភាពនៃឯកសារអាជីវកម្មក៏បានអន់ថយផងដែរ។ មានអាជីវកម្មតែ ២០ភាគរយប៉ុណ្ណោះក្នុងខេត្តដែលបានទទួលពិន្ទុកណ្តាលបានយល់ដឹងអំពីអ្វីជាថវិកាខេត្ត។ អាជីវកម្មចំនួន៧៣ភាគរយ បញ្ជាក់អះអាងថាខ្លួនមិនទទួលបានដំណឹងអំពីការផ្លាស់ប្តូរច្បាប់ ដែលធ្វើឱ្យប៉ះពាល់ជាក់ស្តែងដល់អាជីវកម្មរបស់ខ្លួនឡើយ។ ៥៥ ភាគរយនៃអាជីវកម្មតាមខេត្តដែលទទួលបានពិន្ទុកណ្តាលលើសន្ទស្សន៍តម្លាភាពជឿជាក់ថា ទំនាក់ទំនងមួយចំនួនជាមួយអាជ្ញាធរ

មូលដ្ឋានមានភាពចាំបាច់ ដើម្បីឱ្យខ្លួនទទួលបានឯកសារអាជីវកម្មទាំងនោះ។ ម្យ៉ាងវិញទៀត អាជីវកម្មចំនួន ៤៧ ភាគរយ ជឿជាក់ថាមានការទទួលបានភាពអនុគ្រោះជាចំហរចំពោះក្រុមហ៊ុន ដែលមានទំនាក់ទំនងផ្អែកនយោបាយ។

តាមការបង្ហាញកាលពីលើកមុន ដែលជាការលើកឡើងដដែលៗ : តម្លាភាពមានសារៈសំខាន់សម្រាប់អាជីវកម្មខ្នាតតូច។ ប្រសិនបើអាជីវកម្មទាំងនោះទទួលបានព័ត៌មានកាន់តែច្រើន ពួកគេអាចប្រមើលមើលអំពីទិសដៅ និងហានិភ័យរបស់អាជីវកម្មរបស់ខ្លួន នាពេលអនាគតបានកាន់តែប្រសើរ។ ការទទួលបានព័ត៌មាននេះ ធ្វើឱ្យអាជីវកម្មទាំងនោះអាចធ្វើការសម្រេចចិត្ត ដោយវៃឆ្លាតក្នុងការវិនិយោគ និងការពង្រីកអាជីវកម្មរបស់ខ្លួន។ ប្រសិនបើអាជីវកម្មទាំងនោះមិនទទួលបានព័ត៌មានទាំងនេះទេ ពួកគេមិនហ៊ានពង្រីកអាជីវកម្មរបស់ខ្លួនទេ ដោយសារគេធ្លាប់ជួបប្រទះនឹងបញ្ហាមិនច្បាស់លាស់ដែលបណ្តាលមកពី ការផ្លាស់ប្តូរច្បាប់ និងកត្តាផ្សេងៗដែលប៉ះពាល់ដល់បរិយាកាសអាជីវកម្ម។ ការទទួលបានព័ត៌មានច្បាស់លាស់ និងអាចជឿទុកចិត្តបានស្តីពីបទបញ្ញត្តិ ចំណាយផ្លូវច្បាប់ និងពន្ធ មិនត្រឹមតែធ្វើឱ្យម្ចាស់អាជីវកម្មកាន់តែមានការទទួលខុសត្រូវប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យអាជីវកម្មទាំងនោះមិនសូវរងគ្រោះ ដោយសារតែការសម្រេចចិត្តពុំត្រឹមត្រូវរបស់មន្ត្រីអនុវត្តច្បាប់។ ម្យ៉ាងវិញទៀត តម្លាភាពជាជម្រើសមួយក្នុងចំណោមជម្រើសគោលនយោបាយ ដែលងាយស្រួលក្នុងការអនុវត្តន៍។ ការបង្កើនលទ្ធភាពទទួលបានព័ត៌មាន មានភាពងាយស្រួលច្រើនជាងការកែលម្អស្ថាប័នមូលដ្ឋាន។ មន្ត្រីថ្នាក់ខេត្តដែលកំពុងព្យាយាមឱ្យខេត្តរបស់ខ្លួនកើនពិន្ទុ PBES ក្នុងរយៈពេលខ្លីនឹងទទួលបានផលប្រយោជន៍យ៉ាងងាយស្រួល ដោយគ្រាន់តែផ្តល់ព័ត៌មាននៅក្នុងស្ថាប័នមូលដ្ឋានរបស់ខ្លួនដែលជាទីកន្លែងដែលម្ចាស់អាជីវកម្មស្វែងរកព័ត៌មាន។

*ការដោះស្រាយជម្លោះ:* គុណភាពនៃការដោះស្រាយជម្លោះក៏មានការអន់ថយផងដែរ។ សំខាន់ជាងនេះទៀត សហគ្រិនជាច្រើនរាយការណ៍អំពីការមិនសូវមានទំនុកចិត្តលើស្ថាប័នរដ្ឋ។ មានអាជីវកម្មតែ២២ភាគរយប៉ុណ្ណោះ នៅក្នុងខេត្តដែលទទួលបានពិន្ទុកណ្តាលលើសន្ទស្សន៍ដោះស្រាយជម្លោះ ជឿជាក់ថា ប្រព័ន្ធច្បាប់នឹងជួយការពារកម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួន ដែលកាលពីឆ្នាំ២០០៦ ចំនួននេះមានរហូតដល់ ៣៤ ភាគរយ។ ស្រដៀងគ្នានេះដែរ មានអ្នកផ្តល់ចម្លើយតែ ៤១ ភាគរយប៉ុណ្ណោះ បានពេញចិត្តចំពោះដំណោះស្រាយជម្លោះកិច្ចសន្យាកាលពីឆ្នាំកន្លងទៅនេះ ហើយអាជីវកម្មចំនួន ៦៥ ភាគរយ មិនអាចទទួលបានប្រាក់ដែលអតិថិជនជំពាក់ខ្លួនវិញឡើយ។ នៅឆ្នាំ២០០៦ អាជីវកម្មចំនួន ៥៣ ភាគរយទទួលបរាជ័យក្នុងការទាមទារប្រាក់ពីអ្នកជំពាក់មកវិញ។ លទ្ធផលរកឃើញទាំងនេះ គឺជាកង្វល់មួយ។ ទីមួយ ទឹកប្រាក់មិនទាន់ទូទាត់មានតម្លៃ ២.៨ ភាគរយនៃការលក់សរុប ដូច្នេះគុណភាពមិនល្អនៃដំណោះស្រាយជម្លោះកំពុងធ្វើឱ្យអាជីវកម្មខាតបង់ប្រាក់អស់ជាច្រើន។ ទីពីរ ដោយសារអាជីវកម្មកាន់តែច្រើនចូលប្រឡូកក្នុងទីផ្សារ ហើយប្រទេសកម្ពុជាបន្តធ្វើសមាហរណកម្មជាមួយទីផ្សារអន្តរជាតិ មធ្យោបាយផ្លូវការសម្រាប់ដោះស្រាយជម្លោះ នឹងកាន់តែមានភាពចាំបាច់ខ្លាំងឡើង។ អាជីវកម្មទាំងនោះនឹងមិនអាចបន្តពឹងផ្អែកទៅលើទំនាក់ទំនងសង្គម ជនមានមុខមាត់នៅតាមមូលដ្ឋាន និងវិធានការមិនផ្លូវការផ្សេងទៀត ដើម្បីអនុវត្តកិច្ចសន្យាតទៅទៀតបានឡើយ ដោយសារអាជីវកម្មទាំងនោះនឹងធ្វើអាជីវកម្មក្នុងទ្រង់ទ្រាយធំ ជាមួយក្រុមហ៊ុននៅក្រៅបណ្តាញសង្គមរបស់ខ្លួន។ កង្វះទំនុកចិត្តលើមធ្យោបាយដោះស្រាយជម្លោះផ្លូវការ បង្កឱ្យមានហានិភ័យដល់ការធ្វើអាជីវកម្មទាំងនោះ ហើយវាអាចរាំងដល់ការពង្រីក និងកំណើនអាជីវកម្ម។

# ៥. សេចក្តីសន្និដ្ឋាន

PBES ផ្តល់ព័ត៌មានដ៏មានតម្លៃថាតើម្ចាស់អាជីវកម្មក្នុងមូលដ្ឋានយល់ឃើញ និងយល់ដឹងពីបរិយាកាសអាជីវកម្មក្នុងខេត្តរបស់ខ្លួនយ៉ាងដូចម្តេច ថាតើម្ចាស់អាជីវកម្មជួបនឹងឧបសគ្គអ្វីខ្លះ ហើយគេមានការយល់ឃើញបែបណាចំពោះការអនុវត្តន៍ការងាររបស់មន្ត្រីបម្រើការក្នុងវិស័យសាធារណៈ នៅក្នុងទិដ្ឋភាពខុសៗគ្នានៃអភិបាលកិច្ចសេដ្ឋកិច្ច។ PBES ក៏បង្ហាញពីភាពខុសៗគ្នា ក្នុងចំណោមខេត្តនានា ព្រមទាំងបង្ហាញថា ខេត្តខ្លះអនុវត្តការងារលើវិស័យមួយចំនួនបានប្រសើរជាង ខេត្តមួយចំនួនទៀត។ ដូច្នេះ PBES គឺជាឧបករណ៍មួយដ៏មានប្រយោជន៍សម្រាប់ជួយមន្ត្រីមូលដ្ឋាន វិស័យឯកជន និង ភាគីពាក់ព័ន្ធផ្សេងៗទៀត អាចប្រៀបធៀបការអនុវត្តន៍ការងាររបស់ខេត្តខ្លួនជាមួយនឹងខេត្តផ្សេងទៀត។ ឧបករណ៍នេះ ក៏អាចជួយមន្ត្រីឱ្យរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយនៃបរិយាកាសអាជីវកម្មក្នុងខេត្តរបស់ខ្លួន។ ដូច្នេះ PBES ជាឧបករណ៍មួយដ៏មានប្រយោជន៍សម្រាប់ឱ្យមន្ត្រីថ្នាក់ខេត្ត យកទៅប្រើប្រាស់សម្រាប់បង្កើតរបៀបវារៈនៃគោលនយោបាយ ដែលអាចអនុវត្តបាន ដោយពិគ្រោះយោបល់ជាមួយផ្នែកឯកជន។

ការវិភាគដ៏ស៊ីជម្រៅពីលទ្ធផល PBES នឹងជួយដល់មន្ត្រីមូលដ្ឋាន និងអាជីវករ ក្នុងការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រ រវាងវិស័យសាធារណៈ និងឯកជន ដើម្បីកែលម្អទំនាក់ទំនងដែលមានភាពទន់ខ្សោយ និងពង្រឹងការអនុវត្តន៍ឱ្យកាន់តែប្រសើរឡើង។ លើសពីនេះ អ្វីដែលសំខាន់ជាងការប្រៀបធៀបចំណាត់ថ្នាក់រួមរវាងខេត្តមួយ និងខេត្តផ្សេងទៀតនោះ គឺថា ខេត្តក្រុងមានឱកាសយ៉ាងច្រើន ដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក និងចែករំលែកការអនុវត្តន៍និងមេរៀនល្អៗ តាមរយៈការសិក្សាអំពី របៀបនៃការអនុវត្តន៍ការងារ តាមសន្ទស្សន៍នីមួយៗ ថាតើមានភាពខុសគ្នាពីខេត្តក្រុងមួយទៅខេត្តក្រុងមួយទៀតដូចម្តេចខ្លះ។

បើគិតទៅលើការផ្តល់អាទិភាព មន្ត្រីថ្នាក់ខេត្តអាចផ្តោតការយកចិត្តទុកដាក់រៀនសូត្រ និងអនុវត្តសកម្មភាពកំណែទម្រង់ របស់ខ្លួនទៅលើវិស័យចាំបាច់មួយចំនួន ដូចជាការកាត់បន្ថយចំណាយក្រៅផ្លូវការ បទឧក្រិដ្ឋ ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ និងរដ្ឋបាលពន្ធដារ។ សន្ទស្សន៍ទាំងនេះមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងទិសដៅអនាគតក្នុងការពង្រីកអាជីវកម្ម។ យន្តការសម្រាប់ប្រមូលយោបល់ពីម្ចាស់អាជីវកម្ម និងជួយឱ្យអាជីវករចូលរួមក្នុងការផ្លាស់ប្តូរគោលនយោបាយមូលដ្ឋានមានសារៈសំខាន់ចាំបាច់ក្នុងការធ្វើឱ្យសម្រេចគោលដៅលើកកម្ពស់អភិបាលកិច្ចជារួម។

# ឧបសម្ព័ន្ធ ក១ ~ វិធីសាស្ត្រ

ផ្នែកនេះបង្ហាញពីសេចក្ដីសង្ខេប អំពីវិធីសាស្ត្រអង្កេតរបស់ PBES ។ សម្រាប់ព័ត៌មានលំអិត សូមមើលរបាយការណ៍ បច្ចេកទេសឆ្នាំ២០០៦ និងឆ្នាំ២០០៩ ។

### *ក១.១: ការជ្រើសរើសសំណាកសហគ្រាស*

វិធីសាស្ត្រជ្រើសរើសសំណាកសហគ្រាសក្នុងការស្រាវជ្រាវ PBES ឆ្នាំ២០០៩ មានបីជំហានសំខាន់ៗ ។ ជំហានទី ១ ស្ថិតិអាជីវកម្ម MSME ទាំងអស់ ត្រូវបានស្រង់ដោយក្រុមអ្នកស្រាវជ្រាវ PBES ក្នុងបរិវេណ៣គីឡូម៉ែត្រជុំវិញទីរួមខេត្តក្រុងនីមួយៗ និងស្រុកមួយផ្សេងទៀតក្នុងខេត្តក្រុងចំនួន ១០ ដែលមានសកម្មភាពសេដ្ឋកិច្ចសស្រាក់សស្រាំ ។ស្ថិតិអាជីវកម្ម និងព័ត៌មានអំពីអាជីវកម្មត្រូវបានយកមកប្រើដើម្បីជ្រើសរើសសំណាកសហគ្រាសដោយចៃដន្យសម្រាប់ការសម្ភាសន៍ផ្ទាល់ជាមួយម្ចាស់អាជីវកម្ម ។ ជំហានទី ២ ការសម្ភាសន៍ផ្ទាល់ជាមួយម្ចាស់អាជីវកម្ម គឺដើម្បីប្រមូលការយល់ឃើញរបស់ម្ចាស់អាជីវកម្មទាំងអស់អំពីទិដ្ឋភាពសំខាន់ៗនៃអភិបាលកិច្ចសេដ្ឋកិច្ចតាមខេត្តក្រុង ។ ជំហានទី ៣ លទ្ធផលដែលបានពីការពិភាក្សាតាមក្រុម និងទិន្នន័យដែលប្រមូលបានពីឯកសារបោះផ្សាយជាសាធារណៈ ទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចត្រូវដាក់រួមបញ្ចូលគ្នា ដើម្បីបំពេញបន្ថែមទៅនឹងការយល់ឃើញរបស់អ្នកផ្ដល់ចម្លើយសម្រាប់ការអង្កេតនេះ ។

ជំហានទី ៣ នេះគឺ ជា "ការប្រមូលទិន្នន័យរឹង" ។

### *ក១.២ : ស្ថិតិលម្អិតនៃអាជីវកម្មកំពុងប្រតិបត្តិការ*

ក្រុមអ្នកស្រាវជ្រាវបានចុះទៅកាន់ខេត្តក្រុងនីមួយៗ ដើម្បីស្រង់ស្ថិតិអាជីវកម្មទាំងអស់ ដែលមានទីតាំងស្ថិតក្នុងបរិវេណ ៣ គីឡូម៉ែត ជុំវិញទីរួមខេត្តក្រុង និងស្រុក១០ក្នុងខេត្តដែលមានសកម្មភាពសេដ្ឋកិច្ចសស្រាក់សស្រាំ ។ យើងបានស្រង់ស្ថិតិអាជីវកម្មផ្លូវការ និងមិនផ្លូវការទាំងអស់ដែលមានទីតាំងជាក់លាក់មួយ រួមទាំងព័ត៌មានមូលដ្ឋាននៃអាជីវកម្មទាំងនោះដូចជា ទីតាំងអាជីវកម្ម សកម្មភាព ភេទនៃម្ចាស់អាជីវកម្ម និងចំនួននិយោជិត ។ល ។ ក្រុមអ្នកស្រាវជ្រាវ ស្រង់បានចំនួនអាជីវកម្មសរុប ៦៣ ៥០៧ នៅក្នុងខេត្តក្រុងទាំង ២៤ ក្នុងប្រទេសកម្ពុជា ។ ការស្រង់ស្ថិតិអាជីវកម្មនេះ គឺជាការចាំបាច់ដោយសារប្រទេសកម្ពុជាខ្វះខាតទិន្នន័យថ្មីៗអំពី MSME ក្នុងបណ្ដាខេត្តក្រុងនានា ។ ស្ថិតិឈ្មោះអាជីវកម្មនេះអាចចាត់ទុកជាទិន្នន័យតំណាង ដែលគួរឱ្យទុកចិត្តបានដោយសារតែអត្រានៃការឆ្លើយសំណួរមានកម្រិតខ្ពស់រហូតដល់ ៩៥.៥ ភាគរយ ។ គ្មានខេត្តណាមួយ ដែលមានអត្រាឆ្លើយសំណួរទាបជាង៩០ភាគរយទេ ។ ជាងនេះទៅទៀតជាមធ្យម អត្រាឆ្លើយសំណួរក្នុងខេត្តក្រុងមាន ៩៨.៩ ភាគរយ ហើយមានកម្រិតប្រែប្រួល ២.២ ភាគរយដែលនេះបង្ហាញថា ភាពលំអៀងដោយសារការមិនផ្ដល់ចម្លើយ មិនបានជះឥទ្ធិពលដល់ខេត្តណាមួយឡើយ ។

## ក១.២ : ការអង្កេត

បន្ទាប់មកយើងជ្រើសរើសសំណាកសហគ្រាសដោយចៃដន្យចំនួន ១០៨២ ពីស្ថិតិអាជីវកម្មទាំងនេះសម្រាប់ខេត្តក្រុងទាំងអស់ដោយបែងចែកតាមវិស័យ និងចំនួននិយោជិតរបស់អាជីវកម្ម ។ ដើម្បីឆ្លើយតបនឹងគោលបំណងនៃការសិក្សានេះ យើងបានធ្វើការវិភាគដោយផ្តោតការយកចិត្តទុកដាក់ទៅលើអាជីវកម្មដែលមានសក្តានុពលរីកចម្រើន មិនមែនអាជីវកម្មដែលសម្រាប់តែអាចទ្រទ្រង់ដល់ប្រតិបត្តិការឡើយ ។ ដូច្នេះ យើងមិនបានរាប់បញ្ចូលអាជីវកម្មទាំងឡាយណាដែលម្ចាស់អាជីវកម្មជានិយោជិតអចិន្ត្រៃយ៍ឡើយ [១២] ។ ជាមធ្យមអត្រានៃការឆ្លើយតបក្នុងពេលជួបប្រាស្រ័យលើកដំបូងជាមួយអាជីវកម្មមាន ៦០ភាគរយ [១៣] ។ នៅពេលអាជីវកម្មណាមួយបដិសេធមិនចូលរួមឆ្លើយសំណួរអង្កេត យើងបានជ្រើសរើសអាជីវកម្មមួយផ្សេងទៀតមកជំនួស ដោយជ្រើសចេញពីស្ថិតិអាជីវកម្មដើម្បីបង្គ្រប់ចំនួនសម្រាប់ខេត្តក្រុងនីមួយៗ ។ បណ្តាខេត្តក្រុងទាំងអស់មានអ្នកផ្តល់ចម្លើយយ៉ាងតិច ៣៩ នាក់ ប៉ុន្តែដើម្បីធានាឱ្យមានតំណាងសមស្រប ខេត្តក្រុងដែលមានប្រជាជនច្រើនអ្នកផ្តល់ចម្លើយដែលត្រូវបានជ្រើសរើសក៏មានចំនួនច្រើនដែរ ដូចជា ភ្នំពេញមាន ១១១ នាក់ ខេត្តបាត់ដំបង មាន ៦៥ នាក់ និងខេត្តសៀមរាប មាន ៦៦ នាក់ ។ ដោយយោងតាមការអនុវត្តន៍ទូទៅសំរាប់គណនាកំរិតលំអៀងនៃការជ្រើសរើសសំណាកសហគ្រាស យើងអាចសន្និដ្ឋានថាកម្រិតលំអៀងមានប្រហែល៤ ភាគរយនៃចម្លើយសរុប ។

យើងបានសំភាសដោយផ្ទាល់ជាមួយសំណាកម្ចាស់អាជីវកម្មជាង ៦០សំណួរ ទាក់ទងនឹងការយល់ដឹងរបស់គេអំពីបរិយាកាសអាជីវកម្ម ។សំណួរសម្រាប់សន្ទស្សន៍ទាំង ១០ នោះរួមមាន ពេលវេលាដែលម្ចាស់អាជីវកម្មត្រូវចំណាយទៅលើការងាររដ្ឋបាលប្រភេទអាជ្ញាប័ណ្ណដែលទទួលបានភាពងាយស្រួល ឬការលំបាកចំពោះនីតិវិធីដើម្បីទទួលបានអាជ្ញាប័ណ្ណទាំងនោះ ពេលវេលា និងទឹកប្រាក់ដែលត្រូវចំណាយទៅលើនីតិវិធីផ្សេងៗ ការយល់ដឹងរបស់អ្នកឆ្លើយសំនួរអំពីបទបញ្ញត្តិ និងការទទួលបានឯកសារអាជីវកម្ម ឆន្ទៈ និងការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំខេត្ត ក្នុងការជួយដល់អាជីវកម្មក្នុងមូលដ្ឋាន ចំណាយក្រៅផ្លូវការ និងការបង់ប្រាក់ការពារ ជម្លោះរវាងអាជីវកម្ម ហើយជម្លោះនោះត្រូវបានដោះស្រាយបែបណា ថាតើពួកគេនឹងមានការផ្លាស់ប្តូរយោបល់ជាប្រចាំជាមួយមន្ត្រីរាជការដែរឬទេ យើងក៏បានសួរសំណួរទាក់ទងទៅនឹងកិច្ចប្រតិបត្តិការអាជីវកម្ម និងផែនការអាជីវកម្មនាពេលអនាគតផងដែរ ។

ក្រៅពីការសម្ភាសន៍ជាមួយក្រុមហ៊ុនចំនួន ១០៨២ ក្នុងដំណាក់កាលទី២ យើងក៏បានសម្ភាសឡើងវិញជាមួយអាជីវកម្ម ចំនួន ១៥២ ដែលបានផ្តល់បទសម្ភាសក្នុង PBES ឆ្នាំ២០០៦ដែលដោយប្រើប្រាស់ប្រើប្រាស់កម្រងសំណួរដូចគ្នា ។ ការអង្កេតលើអាជីវកម្មទាំងនេះ ពិតជាមានសារៈសំខាន់ចាំបាច់ សម្រាប់ការវាយតម្លៃការវិវត្តន៏បរិយាកាសអាជីវកម្មនៅចន្លោះឆ្នាំ ២០០៦ និងឆ្នាំ ២០០៩ ទៅតាមការយល់ឃើញរបស់អាជីវករក្នុងខេត្តក្រុងទាំង១០ ដែលបានចូលរួមក្នុង PBES លើកដំបូង ។ ការជ្រើសរើសអាជីវកម្មទាំងនេះធ្វើឡើងដោយចៃដន្យ ដោយជ្រើសចេញពីការអង្កេត PBES ឆ្នាំ២០០៦ ។ការអង្កេតលើអាជីវកម្មទាំងនេះមានសារៈសំខាន់

---

១២ ការជ្រើសរើសសំណាកសហគ្រាសដែលមានសក្តានុពលរីកចម្រើននៅខេត្តស្ទឹងត្រែង ឧត្តរមានជ័យ និងព្រះវិហារ ពុំបានគ្រប់គ្រាន់ទេដើម្បីអាចតំណាងឱ្យខេត្តពីព្រោះនៅខេត្តទាំងនោះអាជីវកម្មមានចំនួនតិចពេក ។ ក្នុងករណីនេះ យើងបានជ្រើសយកក្រុមហ៊ុនមួយចំនួនដែលមានតែម្ចាស់អាជីវកម្មមកសម្ភាសន៍ ។ ដើម្បីឱ្យគេអាចប្រៀបធៀបជាមួយខេត្តផ្សេងទៀតបាន យើងបានជ្រើសសំណាកសហគ្រាសជំនួសដោយផ្អែកលើទំហំ និងទីតាំងអាជីវកម្ម ការធ្វើដូច្នេះអាចផ្តល់ឱកាសច្រើនសម្រាប់អាជីវកម្ម ដែលធំជាងគេក្នុងការជ្រើសរើសមកសម្ភាសន៍ ។

១៣ ចម្លើយនេះមិនទាន់ល្អឥតខ្ចោះនៅឡើយទេ ប៉ុន្តែវាមានកម្រិតខ្ពស់សម្រាប់ការអង្កេតអាជីវកម្មទូទៅ ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍន៍ ។ ដោយសារតែវិធីសាស្ត្រក្នុងការអង្កេត និងក្រុមហ៊ុនភាគច្រើនដែលឆ្លើយសំណួរទាំងនោះជាលើកដំបូង នាំឱ្យអត្រាឆ្លើយសំណួរដែលយើងទទួលបានមានលក្ខណៈល្អ ។ ទោះជា យ៉ាងនេះក៏ដោយ អត្រាឆ្លើយសំណួរបានថយចុះយ៉ាងខ្លាំងនៅតាមខេត្ត ដែលទទួលរងផលប៉ះពាល់ ដោយសារតែជម្លោះតាមព្រំដែនក្នុងខេត្តព្រះវិហារ ។ ខេត្ត បន្ទាយមានជ័យ (៣៣ ភាគរយ) ខេត្តបាត់ដំបង (៤៣ ភាគរយ) ខេត្តឧត្តរមានជ័យ (៣៩ ភាគរយ) និងខេត្តព្រះវិហារ (២៩ ភាគរយ) បានទទួលចម្លើយក្រោម កម្រិតមធ្យម ។ ការធ្វើតែសច្បាស់លាស់បានចង្អុលបង្ហាញថា អត្រាឆ្លើយតបក្នុងកម្រិតទាបមិនបានប៉ះពាល់ដល់ចំណាត់ថ្នាក់ PBESឡើយ ។

### តារាង ក១ ៖ តើអ្នកណាជាអ្នកឆ្លើយសំណួរសម្រាប់ការអង្កេតរបស់ PBES ឆ្នាំ២០០៩ ?

| | សំណាកសហគ្រាស ខេត្តនីមួយៗ (១) | ខេត្តដំបូង ទាំង ១០ (២) | ក្រុមអ្នកឆ្លើយសំណួរ ដែលជ្រើសរើស ចេញពីឆ្នាំ២០០៦ (៣) | សំណាកសហគ្រាស តំណាងថ្នាក់ជាតិ (៤) |
|---|---|---|---|---|
| ការអង្កេត | ១ ២៣៤ | ៦៧៥ | ១៥២ | ១ ២៣៤ |
| **មុខដំណែងរបស់អ្នកឆ្លើយសំណួរ ក្នុងអាជីវកម្ម** | | | | |
| ម្ចាស់អាជីវកម្ម និងនាយកគ្រប់គ្រង | ៨៨,២ % | ៨៦,៤ % | ៩២,៨ % | ៨៣,២ % |
| ម្ចាស់អាជីវកម្ម ដែលមិនទទួលខុសត្រូវគ្រប់គ្រង | ១,៣០ % | ០,៧៤ % | ១,៣ % | ២,៥ % |
| នាយកគ្រប់គ្រងទូទៅ | ៦,១៦ % | ៧,៧០ % | ២,៦ % | ១០,២ % |
| និយោជិត | ១,៣០ % | ២,៣៧ % | ៣,៣ % | ២,៥៣ % |
| សាច់ញាតិរបស់ម្ចាស់អាជីវកម្ម | ៤,១៦ % | ២,៨២ % | | ១,៦ % |
| **ឆ្នាំបង្កើតអាជីវកម្ម** | | | | |
| មុនឆ្នាំ១៩៩១ | ៦,២ % | ៧,៩ % | ៧,៩ % | ៨,២ % |
| ចន្លោះពីឆ្នាំ១៩៩១ និងឆ្នាំ១៩៩៦ | ១៣,៧ % | ១៥,៦ % | ២៣,៧ % | ១៥,៦ % |
| ចន្លោះពីឆ្នាំ១៩៩៧ និងឆ្នាំ២០០២ | ២៣,៦ % | ២៣,៦ % | ៣០,៣ % | ១៨,០ % |
| ក្រោយឆ្នាំ២០០២ | ៥៦,៥ % | ៥៣,០ % | ៣៨,២ % | ៥៨,១ % |
| **ទំហំអាជីវកម្ម (តាមចំនួនយោជិត)** | | | | |
| ២ ឬតិចជាង២នាក់ | ៦២,២ % | ៥៨,១ % | ៥៤,៦ % | ៥២,៣ % |
| ចន្លោះពី ៣ និង ៥នាក់ | ២៤,១ % | ២៥,៣ % | ២៧,០ % | ២៦,១ % |
| ចន្លោះពី ៦ និង ១០នាក់ | ៨,៨ % | ៩,៨ % | ១២,៥ % | ១២,៧ % |
| ចន្លោះពី ១១ និង ៣០នាក់ | ៤,៤ % | ៥,៩ % | ៥,៩ % | ៧,៧ % |
| ច្រើនជាង ៣០នាក់ | ០,៦ % | ០,៩ % | ០,០ % | ១,៣ % |
| ភាគរយនៃការជួលនិយោជិតតាមរដូវកាល | ៤,៥ % | ៤,៩ % | ៥,២ % | ៣,៨ % |
| **ទំហំអាជីវកម្ម (តាមទំហំវិនិយោគ)** | | | | |
| ១០ ០០០ ដុល្លាសហរដ្ឋ អាមេរិក ឬតិចជាងនេះ | ៥៧,១ % | ៥៤,៨ % | ៥០,៧ % | ៥៥,៨ % |
| ចន្លោះពី ១០ ០០០ និង ៥០ ០០០ ដុល្លាសហរដ្ឋ អាមេរិក | ២៩,២ % | ៣០,៤ % | ៣៤,២ % | ៣០,៩ % |
| ចន្លោះពី ៥០ ០០០ និង ១០០ ០០០ ដុល្លាសហរដ្ឋ អាមេរិក | ៦,០ % | ៥,៩ % | ៥,៣ % | ៥,២ % |
| ច្រើនជាង ១០០ ០០០ ដុល្លាសហរដ្ឋអាមេរិក | ៧,៧ % | ៨,៩ % | ៩,៩ % | ៨,១ % |
| **វិស័យសំខាន់ៗ** | | | | |
| កម្មន្តសាល | ៩,១ % | ៨,៦ % | ៧,៩ % | ៩,០ % |
| សំណង់ | ០,២ % | ០,៤ % | ០,០ % | ០,១ % |
| សេវាកម្ម/ពាណិជ្ជកម្ម | ៩០,៤ % | ៩០,៥ % | ៩០,៨ % | ៩០,៧ % |
| កសិកម្ម/វារីវប្បកម្ម | ០,២ % | ០,៤ % | ១,៣ % | ០,១ % |
| **ទីតាំងលក់សំខាន់ៗ** | | | | |
| ក្នុងខេត្តរបស់ខ្លួន | ៨៩,៤ % | ៩០,៥ % | ៩៨,០ % | ៨៦,១ % |
| ក្នុងខេត្តដទៃ | ០,៧ % | ១,០ % | ១,៣ % | ០,៩ % |
| នាំចេញទៅក្រៅប្រទេស | ៩,៩ % | ៨,៤ % | ០,៧ % | ១៣,១ % |
| **ផែនការសម្រាប់២ឆ្នាំក្រោម** | | | | |
| បង្កើនការធ្វើអាជីវកម្មច្រើន | ១៨,៩ % | ១៩,៣ % | ១៩,១ % | ១៧,១ % |
| បង្កើនការធ្វើអាជីវកម្ម | ៤១,១ % | ៣៨,២ % | ៣២,៩ % | ៣២,៨ % |
| ធ្វើអាជីវកម្មធម្មតា | ៣៦,២ % | ៣៨,២ % | ៤១,៥ % | ៤៥,៥ % |
| បន្ថយការធ្វើអាជីវកម្ម | ១,៩ % | ២,១ % | ៣,៣ % | ១,១ % |
| បន្ថយការធ្វើអាជីវកម្មច្រើន | ០,៥ % | ០,៤ % | ០,៧ % | ០,៦ % |
| គ្រោងបិតឈប់ធ្វើអាជីវកម្ម | ១,៤ % | ១,៨ % | ២,៦ % | ២,៩ % |

១. PBES ឆ្នាំ២០០៩ជ្រើសរើសសំណាកសហគ្រាសដោយចៃដន្យ ដោយផ្អែកលើចំនួននយោជិតនៅក្នុងខេត្តក្រុងទាំង២៤។

២. ការវិភាគដែលក៏រិតតែក្នុងខេត្តទាំង ១០ ដែលបានធ្វើការសិក្សានៅឆ្នាំ ២០០៦ ។

៣. ការអង្កេតឆ្នាំ២០០៩នេះ រាប់បញ្ចូលតែសំណាកសហគ្រាសចំនួន ១៥២ ដែលបានធ្វើអង្កេតនៅឆ្នាំ២០០៦ប៉ុណ្ណោះ។

៤. សំណាកសហគ្រាសក្នុង PBES ដែលបានសម្រួលដើម្បីឆ្លុះបញ្ចាំងពីសមាមាត្រអាជីវកម្មថ្នាក់ជាតិ នៅក្នុងខេត្តក្រុងនីមួយៗ។

ជាពិសេស ពីព្រោះការយល់ឃើញរបស់ពួកគេអាចកាត់បន្ថយភាពខុសឆ្គងក្នុងការជ្រើសរើសសំណាកសហគ្រាស។ អ្នកឆ្លើយសំណួរទាំងនេះមានបទពិសោធន៍ យល់ដឹងអំពីបរិយាកាសអាជីវកម្មក្នុងឆ្នាំ ២០០៦ ដែលអាចអោយគេប្រៀបធៀបនឹងស្ថានភាពបច្ចុប្បន្ន។

តារាងទី ក១ មានបង្ហាញព័ត៌មានលំអិតរបស់អ្នកឆ្លើយសំណួរក្នុងការអង្កេត។ សំណាកសហគ្រាសចំនួន ៤ ត្រូវបានប្រៀបធៀប ។ជួរឈរទី១វាយតម្លៃលើសំណាកសហគ្រាសចំនួន ១ ២៣៤ នៅឆ្នាំ២០០៩ ដោយមិនមានការសម្រួលចំនួនអាជីវកម្មតាមទំហំខេត្តទេ។ ទិន្នន័យទាំងនេះ ឆ្លុះបញ្ចាំងពីបរិយាកាសអាជីវកម្មក្នុងខេត្តក្រុងនីមួយៗយ៉ាងត្រឹមត្រូវ ប៉ុន្តែមិនអាចយកមកប្រើសម្រាប់ធ្វើការវិភាគថ្នាក់ជាតិបានឡើយ។ តាមរយៈការជ្រើសរើសសំណាកសហគ្រាសថ្នាក់ខេត្ត ដូច្នេះទិន្នន័យ PBES ទំនងជាមិនតំណាងអោយគ្រប់ជ្រុងជ្រោយចំពោះខេត្តក្រុងធំៗ ដូចជាទីក្រុងភ្នំពេញ និងខេត្តបាត់ដំបង។ ដើម្បីធ្វើការសន្និដ្ឋានសម្រាប់ថ្នាក់ជាតិ ដោយផ្អែកលើការអង្កេតរបស់ PBES តារាងទី ក១ មានផ្តល់សមាមាត្រថ្មីនៃចំនួនអាជីវកម្មសរុបតាមខេត្តនីមួយៗនៃប្រទេសកម្ពុជា។ ធ្វើដូចនេះ គឺដើម្បីឆ្លុះបញ្ចាំងឱ្យកាត់តែសុក្រឹត ពីមុខងារដ៏សំខាន់របស់ទីក្រុងភ្នំពេញចំពោះ សេដ្ឋកិច្ចកម្ពុជា។ សមាមាត្រទាំងនេះគឺដូចគ្នានឹងតួលេខដែលបានបង្ហាញក្នុងរូបទី២ខាងលើដែរ។ស្ថិតិលំអិតពីការកំណត់កម្រិតថ្នាក់ជាតិនេះ មានបង្ហាញក្នុងជួរឈរទី៤។ សម្រាប់ធ្វើការប្រៀបធៀបទិន្នន័យអាជីវកម្ម ក្នុងខេត្តទាំង១០ ដែលបានអង្កេតក្នុងឆ្នាំ ២០០៦ ស្ថិតិលំអិត ត្រូវបានបង្ហាញ (ជួរឈរទី២) និងទិន្នន័យ នៃអ្នកឆ្លើយតបសំណួរទាំង ១៩២ (ជួរទីឈរ ៣)។

### *ក១.៣ : ករណីសិក្សា*

ក្រៅពីការអង្កេតតាមរយៈកម្រងសំណួរ យើងបានធ្វើការសម្ភាសន៍ជាមួយអាជីវកម្មចំនួន ៨៥ ដើម្បីចងក្រងជាករណីសិក្សា និងដកស្រង់សំដីជាក់ស្តែង សម្រាប់បញ្ចូលក្នុងការបោះពុម្ពផ្សាយពេលនេះ និងពេលក្រោយទៀត។

# ឧបសម្ព័ន្ធ ក២ : ការបង្កើត PBES

### *ក ២.១ ការជ្រើសរើសសន្ទស្សន៍ និងការដាក់ពិន្ទុ*

នៅពេលប្រមូលទិន្នន័យនៃការអង្កេតបានរួចហើយ គេបានដាក់ចម្លើយរបស់ម្ចាស់អាជីវកម្មទាំងនោះបញ្ចូលគ្នាតាមខេត្តក្រុងនីមួយៗ។ គេជ្រើសរើសសូចនាករនៅថ្នាក់ខេត្តក្រុង ដើម្បីឆ្លុះបញ្ចាំងអំពីវិស័យសំខាន់ៗនៃអភិបាលកិច្ចសេដ្ឋកិច្ច សម្រាប់ការអភិវឌ្ឍវិស័យឯកជន។

### *ដំណោះស្រាយចំពោះភាពលំអៀងក្នុងការយល់ឃើញរបស់ក្រុមហ៊ុន*

ដោយសារអាជីវករចំនួន ៩០ភាគរយ ធ្វើសកម្មភាពតែក្នុងខេត្តក្រុងដែលពួកគេរស់នៅ ដូច្នេះអាចមានភាពលំអៀង ក្នុងការយល់ឃើញរបស់អាជីវករ។ ម្ចាស់អាជីវកម្មមានការលំបាកក្នុងការផ្តល់ចំណាត់ថ្នាក់ដល់ថ្នាក់ដឹកនាំក្នុងខេត្តក្រុងរបស់ខ្លួន ដោយយុត្តិធម៌ឡើយ នៅពេលដែលពួកមិនដឹងគេថាតើ បរិយាកាសអាជីវកម្មក្នុងខេត្តក្រុងដទៃទៀតយ៉ាងណានោះ។ យើងដោះស្រាយការលំបាកនេះតាមមធ្យោបាយពីរយ៉ាង។ ទីមួយ សំណួរអង្កេតសម្រាប់សន្ទស្សន៍នេះ គឺផ្អែកទៅលើការយល់ឃើញជាក់ស្តែង (ជាញឹកញាប់សកម្មភាពអាចរាប់បាន) ដូចជា "តើអាជីវកម្មរបស់អ្នកធ្លាប់ត្រូវបានចុះធ្វើអធិការកិច្ចប៉ុន្មានដងកាលពីខែមុន?" ដែលផ្ទុយពីសំណួរបែបអរូបិយ ដូចជា "សូមផ្តល់ចំណាត់ថ្នាក់ដល់បន្ទុកអធិការកិច្ចដោយប្រើមាត្រដ្ឋានពិន្ទុពី ១ ដល់ ៥"។ ក្នុងករណីខ្លះ សំណួរបែបអរូបិយត្រូវបានប្រើ ដើម្បីឆ្លុះបញ្ចាំងពីបរិយាកាសអាជីវកម្មជាក់ស្តែងក្នុងពេលអង្កេត។ ដោយទទួលស្គាល់ថា ភាពលំអៀងទៅលើការយល់ឃើញរបស់ម្ចាស់អាជីវកម្ម អាចប៉ះពាល់ដល់ចំណាត់ថ្នាក់ យើងបញ្ចូលទិន្នន័យ "រឹង" ទៅក្នុងសន្ទស្សន៍ ដើម្បីកែតម្រូវភាពលំអៀង។ ឧទាហរណ៍ ក្នុងសន្ទស្សន៍តម្លាភាព យើងមិនអាចពឹងផ្អែកទាំងស្រុង ទៅលើការយល់ឃើញរបស់ម្ចាស់អាជីវកម្ម ក្នុងការទទួលបានព័ត៌មានស្តីពីអាជីវកម្មឡើយ ដូចនេះយើង បានបញ្ជូនក្រុមអ្នកស្រាវជ្រាវរបស់យើងទៅកាន់មន្ទីរពាក់ព័ន្ធនៅតាមខេត្តក្រុងនីមួយៗដើម្បីធ្វើការសង្កេតថាតើពួកគេអាចទទួលបានឯកសារចាំបាច់សម្រាប់ចុះបញ្ជីអាជីវកម្ម និងធ្វើអាជីវកម្មក្នុងខេត្តក្រុង ដោយងាយស្រួលឬយ៉ាងណា។ទិន្នន័យ"រឹង" ពីរប្រភេទ ត្រូវបានប្រើប្រាស់ ពោលគឺទិន្នន័យមកពីប្រភពបោះពុម្ពផ្សាយផ្សេងៗ និងទិន្នន័យ បានពីការសង្កេតដោយក្រុមស្រាវជ្រាវផ្ទាល់តាមរយៈ ការចុះសង្កេតដល់គ្រប់ខេត្តក្រុងនីមួយៗ ដើម្បីពិនិត្យភាពជាក់ស្តែងពីការអនុវត្តន៍នីតិវិធីទាំងនេះ។

### *ការកំណត់ស្តង់ដាសូចនាករ*

តារាង ក២ ខាងក្រោមបង្ហាញអំពីសន្ទស្សន៍ និងសូចនាករទាំងអស់។ តារាងនោះក៏មានបង្ហាញអំពី ព័ត៌មានសម្រាប់សូចនាករនីមួយៗ ដែលអាចឱ្យយើងធ្វើការប្រៀបធៀបក្នុងរយៈពេលមួយបាន។ មាត្រដ្ឋានពិន្ទុ ១០ សម្រាប់កំណត់ស្តង់ដារសូចនាករក្នុងសន្ទស្សន៍នីមួយៗត្រូវ

បានប្រើប្រាស់ដោយពិន្ទុ ១០ តំណាងឱ្យពិន្ទុខ្ពស់ជាងគេ ហើយពិន្ទុ ១ តំណាងឱ្យពិន្ទុទាបជាងគេ។ ខេត្តក្រុងទាំងនេះត្រូវមានពិន្ទុនៅចន្លោះពីពិន្ទុខ្ពស់បំផុត និងទាបបំផុតនេះ។

### *ការបង្កើតសន្ទស្សន៍*

ការបង្កើតសន្ទស្សន៍ ធ្វើឡើងដោយផ្អែកទៅលើទស្សនៈទូលំទូលាយ ដែលមានការពិភាក្សាជាលក្ខណៈអន្តរជាតិក្នុងចំណោមសេដ្ឋវិទូ និងផ្អែកទៅលើឧបសគ្គជាក់លាក់ដែលជាបញ្ហាប្រឈមសម្រាប់អាជីវកម្មនៅប្រទេសកម្ពុជា។ ដោយផ្អែកលើក្របខ័ណ្ឌទ្រឹស្តី គេបានប្រើប្រាស់សូចនាករពិសេសមួយចំនួន សម្រាប់ជាតំណាងឱ្យការយល់ឃើញក្នុងសន្ទស្សន៍នីមួយៗ។ យើងគណនាសន្ទស្សន៍ទាំងនោះដោយប្រើមធ្យមភាគនៃសូចនាករនីមួយៗ។ ជាលទ្ធផល សន្ទស្សន៍ទាំងនេះក៏មានមាត្រដ្ឋានពិន្ទុ ១០ ដែរ។ នៅពេលដែលដាក់បញ្ចូលទិន្នន័យ "រឹង" ទៅក្នុងសន្ទស្សន៍នីមួយៗ យើងប្រើរបៀបគណនាមួយដែលអាចធានាបាននូវចំណែកទិន្នន័យ "រឹង" ៤០ភាគរយ នៃពិន្ទុរបស់សន្ទស្សន៍នោះ។ ការធ្វើដូចនេះ គឺមានលក្ខណៈគ្រប់គ្រាន់សម្រាប់កាត់បន្ថយភាពលំអៀងនៃការយល់ឃើញ ប៉ុន្តែមិនគ្រប់គ្រាន់ សម្រាប់អោយមានភាពលើសលុបលើទស្សនៈរបស់អ្នកឆ្លើយសំណួរឡើយ។

### *ការដាក់បញ្ចូលគ្នានូវពិន្ទុ PBES ចុងក្រោយ*

បន្ទាប់ពីបង្កើតសន្ទស្សន៍រួចហើយ គេអាចផ្តល់ពិន្ទុ PBES បានដោយបូកបញ្ចូលគ្នានូវពិន្ទុសន្ទស្សន៍ទាំងអស់។ វិធីសាស្ត្រនៃការគណនាពិន្ទុអាចប្រើប្រាស់បានតាមរបៀបខុសៗគ្នា។ នៅឆ្នាំ២០០៦ ចំនួនខេត្តដែលបានជ្រើសរើសសម្រាប់ការអង្កេត មានចំនួនតិចពេករហូតមិនអាចប្រើវិធីសាស្ត្រផ្សេងៗគ្នាបានសម្រាប់ជាប្រយោជន៍ដល់អ្នកបង្កើតគោលនយោបាយ (ចំនួនអាជីវកម្ម កំណើនវិនិយោគ និងផលចំណេញ) ដោយកំណត់ផលប៉ះពាល់នៃសន្ទស្សន៍នីមួយៗទៅលើផ្នែកនានា តាមរយៈការវិភាគបែបរីគ្រេស្យុង (regression) បានទេ។ ប៉ុន្តែដោយមានទិន្នន័យកាន់តែច្រើននៅឆ្នាំ២០០៩ យើងអាចធ្វើការវិភាគតាមវិធីសាស្ត្របែបនេះបាន។ ទោះបីជាយ៉ាងនេះក៏ដោយ សំរាប់សន្ទស្សន៍នីមួយៗ យើងនៅតែរក្សាវិធីសាស្ត្រដែលមិនបានកំណត់សមាមាត្រ ដើម្បីសំរួលដល់ការប្រៀបធៀបក្នុងរយៈពេលកន្លងមក។ តារាងទី ៣ បង្ហាញអំពីការវិភាគនៃសន្ទស្សន៍ដែលមានសារៈសំខាន់បំផុត។ អ្នកប្រើប្រាស់ដែលមានចំណាប់អារម្មណ៍អាចប្រើមេគុណផ្ទាល់ខ្លួន ប្រសិនបើគិតថាការប្រើនោះមានភាពសមស្រប។

### *ក ២.៣ ផលប្រយោជន៍នៃវិធីសាស្ត្រ*

វិធីសាស្ត្រ PBES មានលក្ខណៈបីយ៉ាងគួរឱ្យកត់សម្គាល់។ ទីមួយ ពិន្ទុទាំងអស់បានមកពីការប្រៀបធៀបរវាងខេត្តក្រុងនីមួយៗ ទៅនឹងខេត្តប្រសើរបំផុត និងខេត្តអន់បំផុត ដោយផ្អែកលើទៅលើសូចនាករជាក់លាក់មួយ។ ដោយផ្តល់ពិន្ទុសម្រាប់អភិបាលកិច្ចសេដ្ឋកិច្ច ដោយផ្អែកលើស្ថានភាពដែលមានរួចហើយប្រសើរបំផុតក្នុងប្រទេសកម្ពុជា ហើយមិនប្រៀបធៀបជាមួយនឹងស្តង់ដាអភិបាលកិច្ចល្អឥតខ្ចោះមួយដែលមិនអាចសម្រេចបាននោះ PBES លើកទឹកចិត្តរដ្ឋាភិបាលថ្នាក់ខេត្ត ឱ្យកែលម្អការអនុវត្តន៍ការងាររបស់ខ្លួន។ នៅក្នុងសូចនាករនីមួយៗ ឬខេត្តក្រុងដែលប្រសើរបំផុត អាចសម្គាល់បាន ហើយខេត្តក្រុងណា ក៏អាចទទួលបានពិន្ទុល្អឥតខ្ចោះចំនួន ១០០ ដោយគ្រាន់តែអនុវត្តតាមគំរូល្អទាំងនេះ។

ទីពីរ PBES ជាការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ច និងគោលនយោបាយបទបញ្ញត្តិប៉ុណ្ណោះ។ PBES មិនវាយតម្លៃលើលក្ខខណ្ឌដែលមានស្រាប់សម្រាប់ការអភិវឌ្ឍឡើយ (មានន័យថាការពិនិត្យលើកត្តាសំខាន់ៗ ដែលអាចជួយដល់

កំណើនសេដ្ឋកិច្ចក្នុងខេត្តក្រុង ប៉ុន្តែកត្តាទាំងនោះមិនអាចដោះស្រាយក្នុងរយៈពេលខ្លីបានឡើយ ដូចជា ទីតាំងហេដ្ឋារចនាសម្ព័ន្ធ ទំហំទីផ្សារក្នុងស្រុក និងធនធានមនុស្ស) ។ ដូច្នេះ PBES ផ្ដល់ចំណាត់ថ្នាក់ខេត្តក្រុងទាំងអស់ ដោយឈរលើមូលដ្ឋានស្មើភាពមួយ ដោយមិនលំអៀងចំពោះ ទីតាំងដែលមានលក្ខណៈអំណោយផលល្អស្រាប់ ។ ដូច្នេះមិនគួរមានការភាន់ច្រលំរវាង PBES និងការវាស់ស្ទង់បរិយាកាសវិនិយោគរួម ដែលមានអភិបាលកិច្ច និងភាពអំណោយផលដែលមានស្រាប់ (ឬហៅថាលក្ខខណ្ឌរចនាសម្ព័ន្ធនោះទេ) ។

ទីបី សូចនាករ PBES អាចយកមកអនុវត្តបានដោយសារតែសូចនាករទាំងនោះ មានលក្ខណៈជាក់លាក់ដែលអាចឱ្យមន្ត្រីថ្នាក់ខេត្តក្រុង កំណត់គោលដៅ និងពិនិត្យតាមដានលើការរីកចម្រើនបាន ហើយសូចនាករទាំងនោះ មានប្រយោជន៍ដើម្បីយកទៅអនុវត្ត ដោយសារសូចនាការទាំងនោះ បង្ហាញអំពីគោលនយោបាយដែលមានសារៈសំខាន់សម្រាប់អាជីវកម្ម ក្នុងការទទួលបានជោគជ័យ និងអាចកំណត់បានតាមរយៈការស្រាវជ្រាវលើកមុនដែលថាសូចនាករទាំងនោះមានឥទ្ធិពលដល់ការធ្វើអាជីវកម្ម ។

សន្ទស្សន៍ចំនួន ១០ ដែលបានប្រើរួចមកហើយក្នុង PBES ឆ្នាំ ២០០៦ ត្រូវបានយកមកប្រើប្រាស់នៅឆ្នាំ ២០០៩ សម្រាប់ ប្រៀបធៀបក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ។ សន្ទស្សន៍ទាំងនេះបង្កើតឡើងដើម្បីបង្ហាញអំពីអាទិភាពរបស់វិស័យឯកជន នឹងផ្ដោតទៅលើបញ្ហានានា ដែលអាចទទួលឥទ្ធិពលពីរដ្ឋាភិបាលមូលដ្ឋាន ។

# ឧបសម្ព័ន្ធ ក៣ ៖ ទំនាក់ទំនងរវាងលទ្ធផល PBES ឆ្នាំ២០០៦ និង PBES ឆ្នាំ២០០៩

ចំពោះការផ្តល់ចំណាត់ថ្នាក់សម្រាប់ធ្វើការប្រៀបធៀប PBES ការសំខាន់ត្រូវបង្ហាញថា ចំណាត់ថ្នាក់ទាំងនេះមិនមានការប្រែប្រួលច្រើនទេពីមួយឆ្នាំទៅមួយឆ្នាំ។ ភាពមិនសូវប្រែប្រួលនេះមានផលប៉ះពាល់សំខាន់ខាងផ្នែកគោលនយោបាយ និងវិធីសាស្ត្រ។ វិធីសាស្ត្រចំពោះគោលនយោបាយ ស្ថិរភាពនៃចំណាត់ថ្នាក់បង្ហាញថា កំណែទម្រង់នៅថ្នាក់ខេត្តមានឥទ្ធិពលក្នុងរយៈពេលវែង។ កំណែទម្រង់ទាំងនេះ មិនកើតឡើងភ្លាមៗនោះទេ ដូច្នេះអាជីវកម្ម នឹងបន្តទទួលបានអត្ថប្រយោជន៍ពីកំណែទម្រង់ទាំងនោះ ហើយអាច យល់ដឹង ពីឥទ្ធិពលនៃកំណែទម្រង់ទាំងនោះនៅពេលមានការអង្កេតម្តងៗ។

តាមវិធីសាស្ត្រ ការទំនាក់ទំនងខ្លាំងជាមួយការធ្វើចំណាត់ថ្នាក់ PBES ឆ្នាំ២០០៦ បង្ហាញថា ការចំណាត់ថ្នាក់ខេត្តក្រុង ដោយប្រៀបធៀបគ្នាពីខេត្តមួយទៅខេត្តមួយទៀត ទទួលបានលទ្ធផលល្អ។PBES អាចកត់សំគាល់បាននូវខេត្តដែលមានបរិយាកាសអាជីវកម្មល្អបំផុត និងអាចកំណត់បានដែរថាខេត្តដែលមានពិន្ទុទាបត្រូវធ្វើអ្វីបានខ្លះដើម្បីកែលំអពិន្ទុនៅពេលអនាគត។ ស្ថិរភាពបែបនេះ គឺជាការឆ្លុះបញ្ចាំងឱ្យឃើញថា វិធីសាស្ត្រនេះផ្តល់នូវការវាស់ស្ទង់អភិបាលកិច្ចសេដ្ឋកិច្ចថ្នាក់ខេត្ត ក្នុងរយៈពេលកន្លងទៅបានត្រឹមត្រូវ។

រូបទី១០ បង្ហាញពីទំនាក់ទំនងរវាងពិន្ទុរបស់ PBES ឆ្នាំ២០០៦ និងឆ្នាំ២០០៩ សម្រាប់ខេត្តដដែលទាំង១០។ ចំណុចទីមួយដែលគួរឱ្យចាប់អារម្មណ៍ក្នុងការអនុវត្តន៍កន្លងមកមានសារៈសំខាន់សម្រាប់អភិបាលកិច្ចនាពេលអនាគត ។ ក្រាហ្វិកនេះបង្ហាញថាការអនុវត្តន៍ក្នុងពេលកន្លងមកជាកត្តាកំណត់ដ៏សំខាន់សម្រាប់កំណត់គុណភាពអភិបាលកិច្ចនាពេលអនាគត[១៤]។ ដោយផ្អែកលើពិន្ទុក្នុង ឆ្នាំ២០០៦ ខ្សែបន្ទាត់បង្ហាញអំពីពិន្ទុដែលខេត្តនីមួយៗគួរទទួលបានក្នុងឆ្នាំ២០០៩។

កត្តាសំខាន់ត្រូវសម្គាល់ថា "ស្ថិរភាព" របស់ពិន្ទុពុំមានន័យថា ពិន្ទុគ្មានការប្រែប្រួលនោះទេ។ ក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ ខេត្តមួយចំនួនបានកើនពិន្ទុតាមលំដាប់ថ្នាក់របស់ PBES។ ខេត្តទាំងនេះមានបង្ហាញនៅក្នុងរូបទី ៧ ពីព្រោះពិន្ទុពិតប្រាកដ របស់ PBES ឆ្នាំ២០០៩ មានកម្រិតខ្ពស់ជាងបន្ទាត់ក្រាហ្វិក ដែលបានប៉ាន់ស្មានជាមុន។

១៤ មេគុណទំនាក់ទំនង ដែលជាការវាស់ស្ទង់ វ៉ារ្យង់ស្តង់ដាររវាង PBES ឆ្នាំ២០០៦ និងឆ្នាំ២០០៩ ស្មើ 0,៤៩ និងអាចប្រែប្រួលក្នុងកម្រិត 0.0៥។

**រូបទី ១០ ៖ ទំនាក់ទំនងរវាងចំណាត់ថ្នាក់ ឆ្នាំ២០០៦ និងឆ្នាំ២០០៩** [១៥]




[១៥] ចំណុចស្រមោលៗ បង្ហាញអំពីកម្រិតដែលជឿជាក់បាន ចំនួន៩៥ភាគរយនៅជុំវិញបន្ទាត់នោះ ។ កម្រិតជឿជាក់បាន មានន័យថាប្រសិនបើយើងអនុវត្ត PBES ឡើងវិញ និងជ្រើសរើសសំណាកសហគ្រាសថ្មីមួយចំនួន ៩៥ភាគរយនៃទំនាក់ទំនងរវាងពិន្ទុក្នុងឆ្នាំ២០០៦ និងពិន្ទុក្នុងឆ្នាំ២០០៩ នឹងនៅតែស្ថិតនៅក្នុង ចំណុចទាំងនេះ ។ ទំនាក់ទំនងនេះប្រហែលជាមិនអាចដូចគ្នាទាំងស្រុងទេ ប៉ុន្តែយើងអាចនិយាយដោយប្រាកដក្នុងចិត្តថាការអនុវត្តកន្លងទៅនឹងនៅតែជាការកត្តាកំណត់ដ៏សំខាន់ និង វិជ្ជមានសម្រាប់អភិបាលកិច្ចនាពេលអនាគត ។

## តារាង ក២: សេចក្តីអធិប្បាយលំអិតអំពីសន្ទស្សន៍ និងសូចនាករដែលជាសមាសភាគនានា

### ១. ចំណាយដើម្បីចាប់ផ្តើមអាជីវកម្ម

- %អាជីវកម្មដែលបានចុះបញ្ជីពាណិជ្ជកម្ម ជាមួយក្រសួងពាណិជ្ជកម្ម ឬមន្ទីរពាណិជ្ជកម្ម
- ចំនួនសរុបនៃវិញ្ញាបនប័ត្រចុះបញ្ជីចុះបញ្ជី អាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតដែលអាជីវកម្មមួយត្រូវការជាចាំបាច់ ដើម្បីអាចធ្វើសកម្មភាពអាជីវកម្មបាន( មេដ្យាន ចំនួនថ្ងៃ)
- រយៈពេលរង់ចាំវិញ្ញាបនប័ត្រចុះបញ្ជីពីមន្ទីរពាណិជ្ជកម្មខេត្តក្រុង ( មេដ្យានចំនួនថ្ងៃ)
- ចំណាយផ្លូវការលើវិញ្ញាបនប័ត្រចុះបញ្ជី ពីមន្ទីរពាណិជ្ជកម្មខេត្តក្រុង(មេដ្យាន ដុល្លា)
- រយៈពេលរង់ចាំដើម្បីទទួលបានអាជ្ញាប័ណ្ណធ្វើអាជីវកម្មរយៈពេលមួយឆ្នាំ ( មេដ្យានចំនួនថ្ងៃ)
- ចំណាយផ្លូវការដើម្បីទទួលបានអាជ្ញាប័ណ្ណ សម្រាប់ធ្វើអាជីវកម្មរយៈពេលមួយឆ្នាំ ( មេដ្យាន ដុល្លា)
- រយៈពេលរង់ចាំដើម្បីទទួលបានប័ណ្ណប៉ាតង់ពីអាជ្ញាធរពន្ធដារមូលដ្ឋាន ( មេដ្យានចំនួនថ្ងៃ)
- ចំណាយផ្លូវការលើពន្ធប៉ាតង់ ដែលត្រូវបង់ទៅអោយអាជ្ញាធរពន្ធដារក្នុងមូលដ្ឋាន ( មេដ្យាន ដុល្លា)
- ចំណូលរបស់រដ្ឋបាលខេត្តពីពន្ធប៉ាតង់+
- ចំណូលរបស់រដ្ឋបាលខេត្តពីវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម+

### ២. កម្មសិទ្ធិដី និងកម្មសិទ្ធិលើទ្រព្យសម្បត្តិ

- %អាជីវកម្មដែលមានឯកសារកាន់កាប់ដី
- %អាជីវកម្មដែលមានប្លង់រឹងលើកម្មសិទ្ធិដីត្រឹមត្រូវ
- %អាជីវកម្មដែលបារម្ភថា ប្រឈមនឹងហានិភ័យដែលគេដកហូតយកដី
- %អាជីវកម្មដែលយល់ថា ការផ្លាស់ប្តូរលើកខណ្ឌជួលដីធ្លី គឺជាហានិភ័យ
- ថ្លៃដីជាក់ស្តែង (កែតម្រូវទៅតាមភាពខុសគ្នារវាងការផ្គត់ផ្គង់ និងតម្រូវការ) ++ ( មេដ្យាន ដុល្លា)

### ៣. តម្លាភាព

- តម្លាភាព និងការទទួលព័ត៌មានអំពីការកសាងផែនការនៅមូលដ្ឋាន និងក្រិត្យ/សេចក្តីសំរេច (ឯកសារចំនួន ១០/មាត្រដ្ឋាន ៥ពិន្ទុ)
- % អាជីវកម្មដែលមិនដឹងពីថវិកាខេត្ត
- ទំនាក់ទំនងជាមួយមន្ត្រីនៅតាមខេត្តជាការចាំបាច់ដើម្បីទទួលបានឯកសារពីរដ្ឋបាលថ្នាក់ខេត្ត ( % ជានិច្ចកាល ឬញឹកញាប់)
- % អាជីវកម្មដែលយល់ថា ការអនុគ្រោះដល់អាជីវកម្មដែលមានទំនាក់ទំនងជាមួយអ្នកនយោបាយគឺជាឧបសគ្គចំពោះការធ្វើអាជីវកម្ម
- ភាពទៀងទាត់ដែលតំណាងពីខុទ្ទកាល័យអភិបាលខេត្តជួបជាមួយអាជីវកម្មដើម្បីពិភាក្សាការផ្លាស់ប្តូរច្បាប់ និងគោលនយោបាយនានា(%កម្រ ឬមិនដែល)
- អាជីវកម្មត្រូវបានផ្តល់ព័ត៌មានអំពីបទបញ្ញត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុថ្មី ដែលពាក់ព័ន្ធនិងអាជីវកម្មរបស់ពួកគេ ( % មិនដែល ឬផ្តល់ព័ត៌មានតិចតួចបំផុត)
- ភាពទៀងទាត់ដែលអាជីវកម្មមួយទទួលដំណឹងជាមុន ពីរដ្ឋាភិបាលថ្នាក់ជាតិអំពីច្បាប់ថ្មីៗ ឬការផ្លាស់ប្តូរច្បាប់ (%កម្រ ឬមិនដែល)
- ការស្នើសុំទៅមន្ទីរពាណិជ្ជកម្មខេត្តក្រុង+ ( មាត្រដ្ឋាន ៥ ពិន្ទុ)
- ការស្នើសុំទៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល+ ( មាត្រដ្ឋាន ៥ ពិន្ទុ)
- ការដាក់បង្ហាញផែនទីហេដ្ឋារចនាសម្ព័ន្ធ+ (ចំនួនការិយាល័យដែលដាក់បង្ហាញផែនទីទាំងនេះ)

### ៤. ពេលវេលាចំណាយដើម្បីគោរពតាមបទបញ្ញត្តិ

- ពេលវេលារបស់អ្នកគ្រប់គ្រងដែលបានចំណាយ ដើម្បីធ្វើតាមលក្ខខណ្ឌដែលតម្រូវដោយបទបញ្ញត្តិរបស់រដ្ឋាភិបាល ( % អាជីវកម្មចំណាយពេលតិចជាង ១៦ថ្ងៃ)
- ចំនួនសរុបនៃការធ្វើអធិការកិច្ចក្នុងមួយឆ្នាំ ( មេដ្យាន)
- រយៈពេលដែលអាជីវកម្មត្រូវចំណាយដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដី ( មេដ្យានចំនួនថ្ងៃ)

### ៥. ចំណាយក្រៅផ្លូវការ

- ជូនកាលការជូនអំណោយទៅមន្ត្រីរដ្ឋាភិបាលគឺជាការចាំបាច់ដើម្បីអាចឆ្លងផុតការត្រួតពិនិត្យគយ ទទួលបានអាជ្ញាប័ណ្ណ ទទួលបានសេវាសាធារណៈ ឬដើម្បីបំពេញតាមលក្ខខ័ណ្ឌពន្ធ ( % ទេ)
- អំពើពុករលួយគឺជាឧបសគ្គ (% នៃឧបសគ្គភាគច្រើន ឬធ្ងន់ធ្ងរ)
- ព័ត៌មានទាក់ទងនឹងកិច្ចសន្យាលទ្ធកម្មសាធារណៈមានតម្លាភាព (%ជានិច្ចកាល ឬជាញឹកញាប់)
- សារៈសំខាន់នៃទំនាក់ទំងជិតស្និទ្ធជាមួយរដ្ឋាភិបាល ដើម្បីឈ្នះនៅក្នុងការដេញថ្លៃលើកិច្ចសន្យាលទ្ធកម្មសាធារណៈ(%កម្រ ឬមិនដែល)
- អាជីវកម្មជឿថា អាជីវកម្មនានានៅក្នុងឧស្សាហកម្មរបស់ខ្លួន ត្រូវបង់កម្រៃជើងសារជាញឹកញាប់នៅពេលធ្វើជំនួញជាមួយរដ្ឋាភិបាល (%កម្រ ឬមិនដែល)
- ស្ថាប័នរដ្ឋដទៃស្នើសុំការបង់ប្រាក់បន្ថែម ( % បាទ/ចាស)
- ជាធម្មតា អាជីវកម្មដឹងអំពីកម្រៃបន្ថែមដែលខ្លួនត្រូវបង់ក្នុងឧស្សាហកម្មរបស់ខ្លួន ( % យល់ស្រប)
- ភាពទៀងទាត់ដែលគេផ្តល់សេវាឱ្យដូចដែលបានរំពឹងទុកនៅពេលដែលអាជីវកម្មមួយបង់ប្រាក់បន្ថែម ( % ភាពទៀងទាត់ ឬជានិច្ចកាល)
- ប្រាក់សំណូកមានប្រយោជន៍សំរាប់ការធ្វើអាជីវកម្ម ( % យល់ស្រប)

### ៦. ការចូលរួម

- % អាជីវកម្មដែលយល់ថា រដ្ឋាភិបាលថ្នាក់ខេត្តស្នើសុំយោបល់ពីក្រុមហ៊ុន ដែលស្ថិតក្រោមឥទ្ធិពលនៃច្បាប់ បទញ្ញា បទបញ្ញត្តិ និងក្រឹត្យថ្មីៗ
- មានសមាគម ឬក្លឹបអាជីវកម្មក្នុងខេត្ត (%បាទ/ចាស)
- % អាជីវកម្មដែលជាសមាជិករបស់សមាគម ឬក្លឹបអាជីវកម្មណាមួយនៅក្នុងខេត្ត
- ចំនួនសមាគមអាជីវកម្មក្នុង ១០ ០០០ អាជីវកម្ម នៅក្នុងខេត្ត++
- វេទិកាអាជីវកម្មដែលបានរៀបចំឡើងក្នុងឆ្នាំ ២០០៧
- ភ័ស្តុតាងនៃការដាក់បង្ហាញប្រអប់សំបុត្រសំណូមពរនៅមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ឬមន្ទីរពាណិជ្ជកម្ម ឬរបៀបប្រមូលបណ្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ នៅឯមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ឬមន្ទីរពាណិជ្ជកម្ម (គ្មានភស្តុតាងបង្ហាញពីរបៀបទាំងនេះទេ)

### ៧. ការទប់ស្កាត់បទឧក្រិដ្ឋកម្ម

- %អាជីវកម្មដែលធ្លាប់រងការខាតបង់ដោយសារអំពើលួចប្លន់ សកម្មភាពបំផ្លាញ ឬអគ្គីភ័យនៅក្នុងឆ្នាំកន្លងទៅ ( % ទេ)
- តម្លៃជាសាច់ប្រាក់ដែលអាជីវកម្មបាត់បង់ ដោយសារបទឧក្រិដ្ឋ ( មេដ្យាន ដុល្លា)
- %អាជីវកម្មនៅក្នុងវិស័យរបស់ខ្លួន ដែលបង់ថ្លៃការពារទៅអោយនគរបាល
- %អាជីវកម្មដែលបានបង់ថ្លៃការពារទៅឱ្យអ្នកដទៃទៀត

## តារាង ក២: សេចក្តីអធិប្បាយលំអិតអំពីសន្ទស្សន៍ និងសូចនាករដែលជាសមាសភាគនានា

### ៨. រដ្ឋបាលពន្ធដារ និងបន្ទុកពន្ធ

- %អាជីវកម្មដែលជឿថា ការផ្តល់សំណូកទៅអោយមន្ត្រីរដ្ឋាភិបាល ដើម្បីគេចវេសពីការបង់ពន្ធដារ និងបទបញ្ញតិនានាគឺជាឧបសគ្គយ៉ាងសំខាន់នៅក្នុងអាជីវកម្ម
- %អាជីវកម្មដែលមិនបង់ពន្ធ
- %អាជីវកម្មដែលជឿថា ការចរចាជាមួយអាជ្ញាធរពន្ធដារគឺជាផ្នែកមួយនៃជំនួញ
- រដ្ឋបាលពន្ធជាឧបសគ្គ (%)
- អត្រាពន្ធជាឧបសគ្គ (%)

### ៩. កិច្ចប្រឹងប្រែងរបស់អ្នកដឹកនាំថ្នាក់ខេត្ត

- អាកប្បកិរិយារបស់មន្ត្រីរដ្ឋាភិបាលខេត្ត ចំពោះអាជីវកម្មឯកជន (% វិជ្ជមាន)
- មន្ទីរខេត្តក្រុង បកស្រាយបទបញ្ញត្តិដើម្បីជួយអាជីវកម្ម នៅពេលដែលអត្ថន័យបទបញ្ញត្តិមិនច្បាស់លាស់
- រដ្ឋាភិបាលនៅខេត្តធ្វើការបានល្អនៅក្នុងក្របខ័ណ្ឌនៃច្បាប់ថ្នាក់ជាតិ ក្នុងការបង្កើតបរិយាកាសអាជីវកម្មដែលផ្តល់ផលចំណេញ (% យល់ស្រប)
- រដ្ឋាភិបាលនៅតាមខេត្តមានគំនិតបង្កើតថ្មី និងវាងវៃក្នុងការដោះស្រាយបញ្ហាអាជីវកម្មថ្មីៗ (% យល់ស្រប)
- រដ្ឋាភិបាលនៅតាមខេត្តហ៊ានប្រឈមនឹងទណ្ឌកម្មពីរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការធ្វើសេចក្តីសម្រេចនានា ដែលជួយដល់អាជីវកម្មនៅក្នុងមូលដ្ឋាន (% យល់ស្រប)
- ពុំមានគំនិតផ្តួចផ្តើមនៅថ្នាក់ខេត្តទេ (% )

### ១០. ការដោះស្រាយជម្លោះ

- %អាជីវកម្មដែលជឿជាក់ថា ប្រព័ន្ធច្បាប់នឹងធានាឱ្យមានការគោរពកិច្ចសន្យា និងកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃជំលោះ
- សមត្ថភាពរបស់អាជីវកម្មដើម្បីទាក់ទងមន្ត្រីផ្សេងទៀត ដើម្បីដោះស្រាយប្រកបដោយជោគជ័យនូវបញ្ហាបានដោះស្រាយដោយមិនត្រឹមត្រូវ (%កម្រ ឬមិនដែល)
- % នៃការលក់បានសរុបប្រចាំខែក្នុងឆ្នាំ ២០០៨ ដែលអតិថិជនមិនសងទៅតាមរយៈពេលដែលសន្យា (មេដ្យាននៃចំណូលពីការលក់)
- %នៃការលក់បានប្រចាំខែ ដែលអតិថិជនមិនសងនៅក្នុងឆ្នាំ២០០៨ (មេដ្យាននៃចំណូលពីការលក់)
- %អាជីវកម្មដែលពេញចិត្តចំពោះដំណោះស្រាយចំពោះជំលោះនានានៅក្នុងខេត្ត
- ជោគជ័យរបស់អាជីវកម្មក្នុងការទទួលបានប្រាក់ដែលគេជំពាក់មកវិញ (% នៃជោគជ័យ)
- % អាជីវកម្មដែលជឿថា មានការដោះស្រាយជម្លោះកិច្ចសន្យាដ៏យុត្តិធម៌ក្នុងខេត្ត

សំគាល់: +មានន័យថា សមាសភាគនេះប្រើប្រាស់ទិន្នន័យរឹង ++មានន័យថាសមាសភាគនេះ បានមកពីការវិភាគកត្តានានា។ ចំណែកសូចនាករផ្សេងទៀតទាំងអស់បានពីការគណនាទិន្នន័យដែលបានពីការយល់ឃើញ។

IFC International Finance Corporation
World Bank Group

The Asia Foundation

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) ដែលជាសមាជិករបស់ក្រុមធនាគារពិភពលោក បង្កើតកាលានុវត្តភាព ដើម្បីអោយប្រជាជនចាកផុតពីភាពក្រីក្រ និងបង្កើនជីវភាពរបស់ពួកគេ។ ពួកយើងជួយជំរុញសេដ្ឋកិច្ច នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានាអោយលូតលាស់ប្រកបដោយនិរន្តរភាព តាមរយៈការគាំទ្រដល់ការអភិវឌ្ឍន៍វិស័យឯកជន កៀងគ និងបែងចែក មូលធនឯកជនផ្តល់សេវាប្រឹក្សាយោបល់ និង សេវាសម្រាលហានិភ័យដល់អាជីវកម្ម និងរដ្ឋាភិបាល។ ទុនវិនិយោគសរុប បច្ចុប្បន្នរបស់យើងមានចំនួន ១៦,២ ពាន់លានដុល្លាអាមេរិកនៅក្នុងឆ្នាំ ២០០៨ ដែលកើនឡើងលើសឆ្នាំមុន ៣៤% ។

នៅក្នុងប្រទេសកម្ពុជា សេវាប្រឹក្សាយោបល់របស់ IFC ត្រូវបានផ្តល់ឱ្យ ដោយមានកិច្ចសហប្រតិបត្តិការជាមួយ អូស្ត្រាលី កាណាដា សហគមអឺរ៉ុប ហ្វាំងឡង់ អៀកឡង់ ជប៉ុន ណូវែលសេឡង់ ហូឡង់ ណរវេស ស៊ុយអែត និង ស្វីស។ យុទ្ធសាស្ត្រប្រឹក្សាយោបល់របស់យើង ត្រូវបានបង្កើតចេញពីការវិភាគនៃ តំរូវការសំរាប់ការអភិវឌ្ឍន៍ក្នុងស្រុក និងក្នុងតំបន់ និង មានកម្មវិធីសំខាន់ចំនួន ៥ ដែលបទពិសោធន៍ ១ទស្សវត្សរ៍កន្លងមក បានបង្ហាញថា កម្មវិធីទាំងនេះ ជួយឱ្យបរិយាកាសវិនិយោគប្រសើរឡើង និងជួយអភិវឌ្ឍសហគ្រាស។ កម្មវិធីទាំងនោះរួមមាន

- កែលំអបរិយោកាសអាជីវកម្ម
- បង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ
- កែលំអនិរន្តភាពបរិស្ថាន និងសង្គម
- បង្កើនតម្លៃបន្ថែមនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់
- បង្កើនលទ្ធភាពប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ

សំរាប់ព័ត៌មានបន្ថែម

សូមមើលគេហទំព័រ www.ifc.org/mekong

មូលនិធិអាស៊ីជាអង្គការក្រៅរដ្ឋាភិបាល មិនរកប្រាក់ចំណេញដែលមានការប្តេជ្ញាក្នុងការបង្កើតនូវសន្តិភាព ការរីកចំរើន យុត្តិធម៌ និងបើកចំហរនៅក្នុងតំបន់អាស៊ីប៉ាស៊ីភិច។ មូលនិធិអាស៊ី គាំទ្រនូវកម្មវិធីជាច្រើននៅអាស៊ី ដែលជួយដល់ការលើកកំពស់អភិបាលកិច្ចច្បាប់ និងសង្គមស៊ីវិល ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី កំណែទម្រង់សេដ្ឋកិច្ច និងការអភិវឌ្ឍ និងទំនាក់ទំនងអន្តរជាតិ។ ដោយមានបទពិសោធន៍ជាង៥០ឆ្នាំនៅអាស៊ី មូលនិធិអាស៊ីបានធ្វើការសហការណ៍ជាមួយដៃគូឯកជន និងសាធារណៈ ដើម្បីគាំទ្រការដឹកនាំ និងអភិវឌ្ឍន៍ស្ថាប័ន ការផ្លាស់ប្តូរបទ ពិសោធន៍ និងការសិក្សាស្រាវជ្រាវគោលនយោបាយ។

ដោយមានការិយាល័យទូទាំងអាស៊ី និងការិយាល័យមួយនៅទីក្រុង Washington, D.C. និង ការិយាល័យធំនៅទីក្រុង San Francisco មូលនិធិអាស៊ី ធ្វើកិច្ចការទាំងនេះទាំងក្នុងកម្រិតតំបន់ និងអន្តរជាតិ។ នៅឆ្នាំ ២០០៨ មូលនិធិអាស៊ីបានផ្តល់ទឹកប្រាក់ជាង ៨៧ លានដុល្លារសហរដ្ឋអាមេរិក ក្នុងការទ្រទ្រង់ដល់កម្មវិធីនានា និង បានចែកចាយសៀវភៅ ចំនួនជាងមួយលានក្បាលព្រមទាំងសម្ភារៈសិក្សាផ្សេងៗ ដែលមានតម្លៃប្រមាណ ៤១ លានដុល្លារសហរដ្ឋអាមេរិក នៅទូទាំងអាស៊ី។

មូលនិធិអាស៊ីបានទទួលនូវជំនួយហិរញ្ញវត្ថុពី មូលនិធិពហុម្ចាស់ជំនួយដើម្បីទ្រទ្រង់ជីវភាពរស់នៅ (MDLF) ដើម្បីអនុវត្តកម្មវិធី ការវាយតម្លៃបរិយាកាសអាជីវកម្មតាមខេត្តនៃប្រទេសកម្ពុជា ជាលើកទី២។ មូលនិធិ MDLF ដែលមានទីតាំងនៅក្នុងស្ថានទូតព្រះរាជាណាចក្រដាណឺមាក ប្រចាំនៅទីក្រុងភ្នំពេញបានផ្តល់ជំនួយ ហិរញ្ញវត្ថុចំនួន ៦៥ លានដុល្លារ ដែលបានមកពី DANIDA ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់អង់គ្លេស (DFID) និង ជំនួយរបស់ប្រទេសណូវែលហ្សឺឡង់ (NZAID) ទៅឱ្យកម្មវិធីគ្រប់គ្រងធនធានធម្មជាតិ និង ទ្រទ្រង់ ជីវភាពរស់នៅ (NRMLP)។ កម្មវិធី NRMLP (២០០៦-២០១០) មានគោលដៅកាត់បន្ថយភាពក្រីក្រ និង កែរលំអការគ្រប់គ្រង់ធនធានធម្មជាតិ ដោយផ្តោតទៅលើខេត្តចំនួន ១៤ នៅក្នុងប្រទេសកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមមើលក្នុងគេហទំព័ររបស់អង្គការមូលនិធិអាស៊ី: www.asiafoundation.org